ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៧ លេខ ៤ | ខែធ្នូ ឆ្នាំ២០១៣ | តម្លៃ ១.៥០០៛

# តួនាទីស្ត្រី និង ឧបសគ្គ ក្នុងអភិបាលកិច្ចទឹក ក្រោមបរិបទនៃការប្រែប្រួលអាកាសធាតុ[១]



ស្ត្រី និងកុមារងាយរងគ្រោះជាងគេអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាពិសេសទឹកជំនន់ និងគ្រោះរាំងស្ងួត (ខេត្តព្រៃវែង ខែតុលា ២០១១)

## សេចក្តីផ្តើម

ស្ត្រីកម្ពុជា គឺជាកសិករដ៏សកម្មជាយូរលង់ណាស់មកហើយ និងបានចូលរួមដ៏ធំធេងជាមួយបណ្តាកសិករជាបុរស ក្នុងការអភិវឌ្ឍដីកសិកម្ម និងប្រព័ន្ធគ្រប់គ្រងទឹក (Kumar *et al.* 2000; Ross and Savada 1989; Khmer View 2013; Nang2013)។កំណើនប្រេកង់នៃគ្រោះរាំងស្ងួត និងទឹកជំនន់ធ្ងន់ធ្ងរនៅកម្ពុជា ដែលមួយភាគធំបណ្តាលមកពីការប្រែប្រួលអាកាសធាតុនោះបានប៉ះពាល់យ៉ាងខ្លាំងទៅលើសន្តិសុខទឹក ផលិតកម្មកសិកម្ម និងស្ថិរភាពប្រព័ន្ធស្បៀងអាហារ។ តួយ៉ាងទឹកជំនន់ដ៏ធំក្នុងឆ្នាំ ២០០៩ និង ២០១១ បានបំផ្លាញដំណាំកសិកម្ម សត្វពាហនៈ ប្រព័ន្ធអេកូឡូស៊ី ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សុខភាពមនុស្ស និងលំនៅស្ថាន ព្រមទាំងអាយុជីវិតមនុស្សអស់ជាច្រើន។ ក្នុងបរិបទបែបនេះ ភាគច្រើនស្ត្រី និងកុមារ (ជាពិសេសស្ត្រីដែលជាមេគ្រួសារ និងកុមារកំព្រា) តែងតែងាយរងគ្រោះជាងបុរសដោយសារពួកគេពឹងផ្អែកលើធនធានធម្មជាតិ ជាចម្បងសម្រាប់ជីវភាពរស់នៅ ហើយក៏ត្រូវប្រឈមមុខនឹងឧបសគ្គផ្នែកសង្គម និងសេដ្ឋកិច្ច ដែលដាក់កំហិតលើសមត្ថភាពបន្សាំរបស់ពួកគេ ម្យ៉ាងទៀតពួកគេមានកាយសម្បទាខ្សោយជាងបុរស ដែលនាំអោយងាយឆ្លងជម្ងឺថែមទៀតផង (WEN 2010)។

ប្រទេសកម្ពុជាសម្បូរទៅដោយធនធានទឹក ប៉ុន្តែការផ្គត់ផ្គង់ទឹកសម្រាប់វិស័យកសិកម្មនាពេលបច្ចុប្បន្ន នៅតែពឹងផ្អែកយ៉ាងខ្លាំងលើទឹកភ្លៀង និងទឹកលើដីដែលទទួលបានដោយផ្ទាល់ ឬតាមរយៈប្រព័ន្ធធារាសាស្ត្រនិងអាងស្តុកទឹកនានា។ ស្រូវវស្សានៅតែជាផ្នែកដ៏សំខាន់បំផុតនៃផលិតកម្មកសិកម្ម និងជាប្រភពចំណូលចម្បងសម្រាប់ជីវភាពរស់នៅរបស់កសិករ នៅតាមតំបន់ជនបទ។ ដោយទទួលស្គាល់ពីតម្រូវការ នៃការចូលរួមកាន់តែច្រើនពីសំណាក់អ្នកពាក់ព័ន្ធ (បុរស និងស្ត្រីនៅតាមមូលដ្ឋាន) ក្នុងការគ្រប់គ្រងទឹកសម្រាប់កសិកម្មនោះ ប្រទេសកម្ពុជាបានដាក់បញ្ចូលគោលការណ៍ការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍ (PIMD) ទៅក្នុងផែនការ និងយុទ្ធសាស្ត្រជាតិ ដើម្បីកែលំអដំណើរការប្រព័ន្ធធារាសាស្ត្រ បង្កើនផលិតកម្មស្រូវ ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងកសាងភាពធន់ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (MOWRAM 2005; MOWRAM 2007a)។

ទោះបីស្ត្រីមានស្ថានភាពលំបាក និងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេពីការប្រែប្រួលអាកាសធាតុក្តីក៏ពួកគេនៅមានតួនាទីជាភ្នាក់ងារដ៏សំខាន់ ដែលជម្រុញឲ្យមានការផ្លាស់ប្តូរប្រកបដោយ

[១] អត្ថបទនេះរៀបរៀងដោយ ណាំង ភិរុណ ជាអ្នកស្រាវជ្រាវ និង អ៊ូច ឈួង ជាជំនួយការក្នុងកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថាន CDRI។

## មាតិកា

តួនាទីស្ត្រី និងឧបសគ្គ ក្នុងអភិបាលកិច្ចទឹកក្រោមបរិបទនៃការប្រែប្រួលអាកាសធាតុ .......... ១
ការសិក្សាតាមដានបន្តពីផលប៉ះពាល់នៃអង្គការកសិករទៅលើផលិតភាពស្រូវ និងផលិតកម្មសត្វចញ្ចឹម ...... ៨
ទំនាក់ទំនងរវាងការងារ នឹងភាពក្រីក្រ នៅប្រទេសកម្ពុជា ..... ១៤
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស .......... ១៧
— ស្ថានភាពក្នុងប្រទេស .......... ២០
— សូចនាករ .......... ២២
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI .......... ២៨

ប្រសិទ្ធភាពនៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយ និងបន្សាំទៅនឹងគ្រោះមហន្តរាយ។ កត្តាទាំងនេះស្តែងអោយឃើញថា ស្ត្រីមិនត្រឹមតែជាអ្នកពាក់ព័ន្ធដ៏សំខាន់នៅក្នុងវិស័យកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រឹងប្រែងលើកកម្ពស់ការគ្រប់គ្រងធនធានទាំងនោះទៀតផង ជាពិសេសការគ្រប់គ្រង និងអភិវឌ្ឍធនធានទឹកសម្រាប់វិស័យកសិកម្ម (UN Women Watch 2009)។

ការសិក្សានេះធ្វើការវិភាគ ពីការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងទឹកព្រមទាំងតម្រូវការ និងឧបសគ្គផ្សេងៗរបស់ស្ត្រីក្នុងការងារផ្នែកកសិកម្ម អភិបាលកិច្ចធនធានទឹក សេវាទ្រទ្រង់នានា និងគោលនយោបាយបន្សាំក្រោមបរិបទនៃការប្រែប្រួលអាកាសធាតុ។ ការសិក្សានេះ ក៏បានវាយតម្លៃផងដែរពីធនធានចាំបាច់ផ្សេងៗ សម្រាប់ជម្រុញឲ្យស្ត្រីចូលរួមកាន់តែសកម្មក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានទឹកប្រកបដោយចីរភាព សម្រាប់វិស័យកសិកម្ម និងការកាត់បន្ថយភាពក្រីក្រ និងការងារអាទិភាពនានា ដើម្បីការកាត់បន្ថយជាអតិបរមានូវឧបសគ្គនានា។

## ការប្រមូលទិន្នន័យនិងការវិភាគ

ការសិក្សាបានកំណត់យកប្រព័ន្ធធារាសាស្ត្រចំនួន១០ ក្នុងបីខេត្ត គឺកំពង់ឆ្នាំង (KCH) កំពង់ធំ (KTH) និងពោធិ៍សាត់ (PST) (រូបភាព១)។ ប្រព័ន្ធធារាសាស្ត្រនីមួយៗមានសហគមន៍កសិករប្រើប្រាស់ទឹក(សកបទ)[២] រៀងៗខ្លួនដែលមន្ទីរធនធានទឹក និងឧតុនិយមខេត្ត (PDWRAM) បានបង្កើតឡើង និងបានទទួលស្គាល់ជាផ្លូវការ។ ដើម្បីប្រមូលព័ត៌មាន ក្រុមស្រាវជ្រាវបានធ្វើការពិភាក្សាតាមក្រុមស្នូល (FGD) នៅតាមប្រព័ន្ធធារាសាស្ត្រទាំងនោះ។ ក្នុង FGD នីមួយៗមានសមាជិកពី ៥ ទៅ ៧នាក់ រួមមានកសិករជាស្ត្រី ២នាក់, គណៈកម្មាធិការសកបទ ២ ឬ ៣ នាក់ និងសមាជិកក្រុមប្រឹក្សាឃុំ ២នាក់។ លើសពីនេះទៀតមានការធ្វើសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KII) ចំនួន ១១លើក

[២] សហគមន៍ទាំងនោះគឺត្រពាំងត្របែក, តាំងក្រសាំង, ស្វាយចេកនិងប៉ុកប៉ែនក្នុងខេត្តកំពង់ឆ្នាំង; វត្តលាប, កំប៉ាងនិងដំណាក់អំពិលក្នុងខេត្តពោធិ៍សាត់និងអូរស្វាយ, ស្ទឹងជីនិតនិងរលួសក្នុងខេត្តកំពង់ធំ។

រូបភាព ១៖ តំបន់សិក្សា




ប្រភព៖ Nang and Chhuoch 2014

ជាមួយអ្នកពាក់ព័ន្ធដូចជា ប្រធាន សកបទ, កសិករ, មេភូមិ, សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់, ព្រមទាំងមន្ត្រីមកពី មន្ទីរកិច្ចការនារី (PDWA), មន្ទីរធនធានទឹក និងឧត្តុនិយម (PDWRAM), មន្ទីរបរិស្ថាន(PDE) និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (PDAFF)។

ទិន្នន័យប្រមូលបាន ត្រូវបានសង្ខេបក្នុងតារាងម៉ាទ្រីសមួយ ដើម្បីបង្ហាញនូវភាពខុសគ្នា និងវិសមភាពផ្សេងៗផ្នែកយេនឌ័រ ក្នុងនេះមានជាអាទិ៍ ព័ត៌មានស្តីពីលទ្ធភាពអាចប្រើប្រាស់បាន និងគ្រប់គ្រងលើធនធាននានា, តួនាទី និងទំនួលខុសត្រូវក្នុងសង្គម ឬសហគមន៍, តម្រូវការជាចាំបាច់ និងជាយុទ្ធសាស្ត្ររបស់យេនឌ័រ ព្រមទាំងឧបសគ្គ និងអត្ថប្រយោជន៍ផ្សេងៗ។

## តួនាទីស្ត្រី និងឧបសគ្គ

*លទ្ធភាពចូលរួមការងារសាធារណៈ ឬសហគមន៍*

ស្ត្រីមានការយល់ដឹងច្រើន ពីបញ្ហាពាក់ព័ន្ធនឹងអភិបាលកិច្ចធនធានទឹកនាពេលបច្ចុប្បន្ន (ដូចជា ការកំណត់ និងប្រមូលថ្លៃសេវាស្រោចស្រព, ផលប្រយោជន៍នៃប្រាក់សន្សំរួមគ្នា និងតម្រូវការការថែទាំប្រឡាយ និងទំនប់ទឹក) ហើយមានពេលខ្លះស្ត្រីមានរបៀបដោះស្រាយបញ្ហាទាំងនោះ បានល្អជាងបុរសថែមទៀតផង។ មន្ត្រីជំនាញម្នាក់ក្នុងខេត្តពោធិ៍សាត់បានអោយដឹងថា៖ "ស្ត្រីមានការយល់ដឹងប្រសើរជាងមុនពីតួនាទីរបស់ខ្លួនក្នុងវិស័យកសិកម្ម និងក្នុងការគ្រប់គ្រងទឹក។ ពួកគេបានផ្លាស់ប្តូរឥរិយាបថពីការស្នើឲ្យបុរសទទួលខុសត្រូវលើការបែងចែកទឹក ដោយទៅធ្វើកិច្ចការនេះដោយខ្លួនឯង ឬជាមួយបុរសវិញ"។

ក៏ប៉ុន្តែបច្ចុប្បន្នចំនួនស្ត្រីដែលមានតួនាទី និងទំនួលខុសត្រូវនៅក្នុងគណៈកម្មាធិការសកបទ, ក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ទីរខេត្តនៅមានកម្រិតទាបនៅឡើយ។ មានកត្តាជាច្រើនដែលរារាំងដល់ការចូលរួមយ៉ាងពេញលេញរបស់ស្ត្រី នៅក្នុងការងារសាធារណៈ និងការសម្រេចចិត្ត។ តួយ៉ាងស្ត្រីត្រូវធ្វើការងារផ្ទះជាច្រើនមុខជាបន្ថែម លើការគ្រប់គ្រងអាជីវកម្មរបស់គ្រួសារ និងការងារស្រែចំការ។ សាធារណជនខ្លះសំដែងនូវកង្វះទំនុកចិត្តទៅលើ សកបទ ដោយសារពួកគេឆ្លើយតបយឺតយ៉ាវនៅពេលត្រូវដោះស្រាយបញ្ហាមួយចំនួនដូចជា៖ កសិករខ្លះបានធ្វើការបិទ ឬបើកទ្វារទឹកដោយគ្មានការអនុញ្ញាត កសិករខ្លះបដិសេធមិនបង់ថ្លៃសេវាស្រោចស្រពជាដើម ទាំងនេះគឺជាកត្តាចម្បងដែលធ្វើឱ្យស្ត្រី មិនសូវចង់ទទួលយកនូវតួនាទីនានាក្នុងការងារសាធារណៈ។ កត្តារាំងស្ទះមួយទៀតគឺការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធស្រោចស្រព ដែលជាការងារមួយដែលទាមទារនូវកម្លាំងកាយច្រើន។ សមត្ថភាពមានកម្រិតរបស់ស្ត្រី (សមាជិកសកបទ ខ្លះនិយាយថាជាកង្វះបទពិសោធន៍ ឬជំនាញ) នៅក្នុងវិស័យទឹក គឺជាឧបសគ្គមួយគួរអោយកត់សំគាល់ដែរ។ ម៉្យាងវិញទៀត ការចូលរួមចំណែកអោយបានពេញលេញក៏ទាមទារនូវការប្តេជ្ញាចិត្តខ្ពស់ និងបទពិសោធន៍សំបូរបែបនៃបញ្ហាពាក់ព័ន្ធដូចជាការគ្រប់គ្រងទឹក និងប្រព័ន្ធស្រោចស្រព, កសិកម្ម, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, បញ្ហាយេនឌ័រ, ការគ្រប់គ្រងនិងកាត់បន្ថយហានិភ័យ រួមមានគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុជាដើម។ ការបោះឆ្នោតនៅថ្នាក់មូលដ្ឋាន បានផ្តល់ឱកាសឲ្យស្ត្រីដើម្បីទទួលបានតួនាទីជាអ្នកដឹកនាំ។ ប៉ុន្តែជាទូទៅ ដោយសារតែឈ្មោះ ស្ត្រីដែលឈរឈ្មោះបោះឆ្នោត តែងត្រូវបានគេដាក់នៅលេខរៀងក្រោមគេក្នុងបញ្ជីបេក្ខជនដែលឈរឈ្មោះបោះឆ្នោត ដូច្នេះស្ត្រីកម្រមានឱកាសត្រូវបានជ្រើសរើស (ជាប់ឆ្នោត) អោយបំពេញតួនាទីជាអ្នកដឹកនាំណាស់។ តែទោះជាយ៉ាងនេះក្តី ការចូលរួមរបស់ស្ត្រីក្នុងការងារសាធារណៈ នៅតែទទួលបានការស្វាគមន៍ដដែល។

*អភិបាលកិច្ចធនធានទឹក*

ទាំងបុរស និងស្ត្រីមានភារកិច្ចពាក់ព័ន្ធនឹងការដោះស្រាយទឹកសម្រាប់ការងារកសិកម្មកិច្ចដំណើរការ និងការថែទាំប្រព័ន្ធស្រោចស្រព, ការចែកចាយ និងផ្សព្វផ្សាយព័ត៌មានស្តីពីធនធានទឹក និងការដាំដុះ, ក៏ដូចជាការប្រមូល និងគ្រប់គ្រងប្រាក់កម្រៃលើសេវាស្រោចស្រព។ ភារកិច្ចផ្សេងទៀតរួមមានការពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍ នឹងអ្នកភូមិ អំពីការបែងចែកទឹក និងការចូលរួមក្នុងគម្រោងអភិវឌ្ឍវិស័យកសិកម្ម, ផែនការគ្រប់គ្រងទឹក និងការគ្រប់គ្រង និងថែទាំប្រព័ន្ធស្រោចស្រព។ ដោយសារកសិករកាន់តែច្រើន មានឱកាសបង្កើនផលិតកម្មកសិកម្ម តាមរយៈការដាំស្រូវពីរដងក្នុងមួយឆ្នាំ វាធ្វើឲ្យតម្រូវការទឹកបានកើនឡើង។ ដូច្នេះមានការដណ្តើមទឹកគ្នាកាន់តែខ្លាំងរវាងអ្នកប្រើប្រាស់ទឹកធ្វើកសិកម្ម នឹងអ្នកប្រើប្រាស់ទឹកក្នុងគោលបំណងផ្សេងៗទៀត ហើយនិងរវាងសហគមន៍ធ្វើកសិកម្មនៅតំបន់ខ្សែទឹកខាងលើ និងសហគមន៍នៅតំបន់ខ្សែទឹកខាងក្រោម។ នៅពេលមានកង្វះទឹក ការដណ្តើមទឹកគ្នានេះនាំឱ្យមានជម្លោះជាញឹកញាប់លើការប្រើប្រាស់ និងបែងចែកទឹកក្នុងរដូវដាំដុះ។ ស្ត្រីបានចូលរួមជួយបុរសច្រើនជាងមុនក្នុងការផ្សះផ្សាជម្លោះទាំងនេះ ព្រោះពួកគេអាចរកឃើញដំណោះស្រាយ ប្រកបដោយសន្តិវិធី។ ចំណុចនេះបង្ហាញឲ្យឃើញអំពី តួនាទីដ៏សំខាន់ដូចបុរសដែរក្នុងផ្នែកសង្គម និងបរិស្ថានរបស់ស្ត្រី។ ទិន្នន័យអង្កេតក៏បង្ហាញផងដែរពីភាពខុសគ្នាផ្នែកយេនឌ័រ គឺបុរសហាក់ផ្តោតខ្លាំងលើការងារមានផលិតភាពដូចជាការដាំដំណាំ ការគ្រប់គ្រង និងបែងចែកទឹក ឬការលក់កំលាំងពលកម្ម។ ផ្ទុយទៅវិញក្រៅពីការរកប្រាក់ចំណូលតាមរយៈអាជីវកម្មខ្នាតតូច និងតួនាទីមានផលិតភាពផ្សេងៗដែលរួមដៃគ្នាជាមួយបុរសនោះ ស្ត្រីភាគច្រើនបានចូលរួមធ្វើការងារមិនមានប្រាក់កម្រៃដូចជា មើលថែកូន, ការរៀបចំម្ហូបអាហារ រកអុស និងដងទឹកជាដើម។

គោលការណ៍ IWRM និង PIMD ត្រូវបានដាក់បញ្ចូលក្នុងគោលនយោបាយជាតិ និងជាយុទ្ធសាស្ត្រស្នូល ដើម្បីជម្រុញការចូលរួមរបស់ប្រជាជនមូលដ្ឋាន ក្នុងការគ្រប់គ្រងទឹកសម្រាប់កសិកម្ម។ សកបទ ដែលជាអង្គការផ្អែកលើសហគមន៍ និងគ្រប់គ្រងដោយគណៈកម្មាធិការ (មានទាំងបុរស និងស្ត្រី) ជាប់ឆ្នោតក្នុងមូលដ្ឋានត្រូវបានបង្កើតឡើង។ ក៏ប៉ុន្តែស្ត្រីក្នុងតំណែងដែលអាចធ្វើសេចក្តីសម្រេចចិត្តបាននៅក្នុង គណៈកម្មាធិការសកបទ នៅមានចំនួនតិចនៅឡើយ។ រូបភាព ២ បង្ហាញថា ក្នុង

រូបភាព ២៖ តួនាទីផ្នែកយេនឌ័រក្នុងសហគមន៍កសិករប្រើប្រាស់ទឹក




ប្រភព៖ ការគណនារបស់អ្នកនិពន្ធ

ចំណោមសមាជិកគណៈកម្មាធិការ សកបទ ទាំង ៤៣នាក់ នៃសកបទ ក្នុងការសិក្សានេះមានស្ត្រីតែ ៩ នាក់ប៉ុណ្ណោះ។ មុខតំណែងដឹកនាំសំខាន់ៗក្នុង សកបទ ភាគច្រើន កាន់កាប់ដោយបុរស៖ ស្ត្រីភាគច្រើនកាន់មុខតំណែងជាហិរញ្ញិក និងគណនេយ្យករ ហើយបុរសច្រើនកាន់កាប់លើតួនាទីគ្រប់គ្រងទូទៅ។

បុរសក៏ជាអ្នកផ្តល់គំនិតផ្នែកបច្ចេកទេស និងធ្វើការសម្រេចចិត្តចុងក្រោយដែរ។ ចំនួនសមាជិកភាព និងទំនាក់ទំនងអំណាចមិនស្មើគ្នាទាំងនេះ បានរុញច្រានស្ត្រីឲ្យទទួលតួនាទីដែលស្ថិតក្រោមបង្គាប់ និងអកម្មហើយក៏មិនបានចូលរួមដោយផ្ទាល់ និងឲ្យបានពេញលេញក្នុងការគ្រប់គ្រងប្រព័ន្ធស្រោចស្រពឡើយ។

### *ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងសមត្ថភាពបន្សាំ*

*ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ*

កសិករក្នុងខេត្តទាំងបីបានកត់សម្គាល់ថា ពួកគេកំពុងប្រឈមមុខនឹងគ្រោះធម្មជាតិ និងផលប៉ះពាល់ផ្សេងទៀតទាក់ទងនឹងអាកាសធាតុកាន់តែច្រើនៗជាពិសេស ទឹកជំនន់, ខ្យល់ព្យុះ, សីតុណ្ហភាពខ្ពស់, ជំងឺឆ្លងតាមកត្តាចម្លងផ្សេងៗ និងគ្រោះរាំងស្ងួត (សូមមើលតារាង១)។ សីតុណ្ហភាពខ្ពស់បណ្តាលឲ្យកើនចំនួនសត្វចង្រៃដូចជា ដង្កូវ កណ្តុរ ជាដើម។ ការកើតរាលដាលសត្វចង្រៃអាចបំផ្លាញស្រូវអស់ច្រើនហិកតាក្នុងពេលតែមួយយប់។ ក្រៅពីការកាត់បន្ថយការលូតលាស់ និងទិន្នផលដំណាំ សីតុណ្ហភាពខ្ពស់ក៏ជាប់ទាក់ទងនឹងកំណើនអត្រាប្រេវ៉ាឡង់ និងហ្វ្រុកង់ជំងឺកុមារផងដែរ។ ស្ត្រីនៅក្នុងប្រព័ន្ធធារាសាស្ត្រមួយនៃការសិក្សានេះ បានប្រាប់ថាក្នុងឆ្នាំ ២០១២ កុមារមួយចំនួនបានឆ្លងជម្ងឺគ្រុនឈាម ហើយក្នុងនោះមានពីរនាក់បានស្លាប់។ កសិករម្នាក់បាននិយាយពីសោកនាដកម្មមួយទៀត ដែលបានកើតឡើងនៅឆ្នាំ ២០១១៖ "ខ្យល់ព្យុះខ្លាំងមួយបានបោកបក់មកលើឃុំ។ កុមារបីនាក់ក្នុងគ្រួសារមួយ បានស្លាប់ក្នុងអំឡុងពេលទឹកជំនន់ គឺ ពីរនាក់លង់ទឹកទន្លេស្លាប់ និងម្នាក់ទៀតដែលបានជិះទូកកាត់ភូមិហើយបានលង់ទឹកស្លាប់នៅពេលមានខ្យល់ខ្លាំងធ្វើឲ្យក្រឡាប់ទូក"។ ប្រជាជននៅជនបទយល់ថាទឹកជំនន់ជាបញ្ហាអាកាសធាតុធ្ងន់ធ្ងរជាងគេ ហើយបន្ទាប់មកគឺខ្យល់ព្យុះ និងគ្រោះរាំងស្ងួត។ កសិករនៅក្នុងគម្រោងស្រោចស្រព មួយផ្សេងទៀត បានពិចារណាពីគ្រោះមហន្តរាយ ក្នុងពេលកន្លងមកដូច្នេះថា៖ "តំបន់របស់យើងបានជួបទឹកជំនន់ធំៗ នៅឆ្នាំ ២០០០ និង ២០០១ ប៉ុន្តែវានៅតូចជាងទឹកជំនន់ ក្នុងឆ្នាំ២០០៩ និង ២០១១"។ កសិករផ្សេងទៀតបានលើកឡើងថាបរិមាណ ភាពញឹកញាប់ និងរយៈពេលភ្លៀងធ្លាក់បានផ្លាស់ប្តូរ ពោលគឺរយៈពេលភ្លៀងធ្លាក់ជួនខ្លី ជួនវែង ជួនកាលយឺតយ៉ាវ។ នៅតំបន់ផ្សេងទៀតគ្រោះរាំងស្ងួត អូសបន្លាយពីមួយខែទៅបីខែ ក្នុងឆ្នាំ ២០១២ មានន័យថាគ្មានភ្លៀងធ្លាក់សោះពីពាក់កណ្តាលខែឧសភា ដល់ពាក់កណ្តាលខែសីហា។ ដំណាំស្រូវត្រូវខូចខាត ឬងាប់អស់, ស្ពឹង អូរ ចាប់ផ្តើមរីងស្ងួត ហើយស្មៅ (សម្រាប់ឲ្យសត្វស៊ី) ត្រូវស្វិតក្រៀមអស់។ កសិករនៅក្នុងខេត្តពោធិ៍សាត់បានអធិប្បាយថា៖ "កាលពីប្រាំ ឬ ដប់ឆ្នាំមុនថ្មើរនេះ [ខែសីហា] អូរតែងមានទឹក ប៉ុន្តែឆ្នាំនេះ [២០១២] ក្នុងអូរ ស្ទើរតែគ្មានទឹកសោះ និងគ្មានត្រីទេ ព្រោះកម្ពស់ទឹកទាបខ្លាំងពេក"។

កសិករផ្សេងទៀតនិយាយថា ពេលខ្លះភ្លៀងហាក់ដូចជាប្រុងនឹងធ្លាក់ (មានពពកខ្មៅ និងខ្យល់បក់ខ្លាំង) ប៉ុន្តែបែរជាមិនធ្លាក់មកសោះ។ គ្រោះរាំងស្ងួតបង្កបញ្ហាធ្ងន់ធ្ងរណាស់ដល់ប្រជាជនរស់នៅឆ្ងាយពីប្រព័ន្ធស្រោចស្រព ព្រោះទឹកក្នុងប្រឡាយ ឬប្រព័ន្ធរំដោះទឹក វាមានមិនគ្រប់គ្រាន់។ កសិករត្រូវចំណាយប្រាក់អស់ច្រើនលើការបូមទឹក (ថ្លៃជួលម៉ាស៊ីនបូមទឹក និងថ្លៃប្រេងឥន្ធនៈ) សម្រាប់ស្រែរបស់ពួកគេប៉ុន្តែកសិករមួយចំនួនគ្មានបរិក្ខារគ្រប់គ្រាន់ ហើយដំណាំស្រូវពួកគេក៏ត្រូវខូចខាត។ អ្នកងាយរងគ្រោះបំផុតគឺប្រជាជនក្រីក្រ កុមារ គ្រួសារមានស្ត្រីជាមេគ្រួសារ និងស្ត្រីមេម៉ាយ។

អង្កេតដល់កន្លែង បង្ហាញថាគ្រោះមហន្តរាយធម្មជាតិប៉ះពាល់ដល់បុរស និងស្ត្រីស្ទើរតែស្មើគ្នា (តារាង១)។ ប៉ុន្តែស្ត្រីហាក់ដូចជាមានសមត្ថភាពបន្សាំតិចជាងបុរសជាពិសេសក្នុងការបន្សាំទៅនឹងកំណើនសីតុណ្ហភាព។

តារាង ១៖ ការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ និងផលប៉ះពាល់លើបុរស និងស្ត្រី

| ការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ | កម្រិតនៃផលប៉ះពាល់ | |
|---|---|---|
| | ស្ត្រី | បុរស |
| ទឹកជំនន់ | ធ្ងន់ធ្ងរ | ធ្ងន់ធ្ងរ |
| គ្រោះរាំងស្ងួត | ធ្ងន់ធ្ងរ | ធ្ងន់ធ្ងរ |
| កំណើនសីតុណ្ហភាព | ធ្ងន់ធ្ងរ | មធ្យម |
| ជម្ងឺឆ្លងពីសត្វល្អិត (ទៅមនុស្ស) | ធ្ងន់ធ្ងរ | ធ្ងន់ធ្ងរ |
| ជម្ងឺឆ្លងតាមកត្តាចម្លងផ្សេងៗ (សត្វពាហណៈ) | ធ្ងន់ធ្ងរ | ធ្ងន់ធ្ងរ |
| សត្វល្អិតចង្រៃ | ធ្ងន់ធ្ងរ | ធ្ងន់ធ្ងរ |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធ

*ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ*

មន្ទីរកិច្ចការនារីខេត្ត (PDWA) ដើរតួនាទីសំខាន់ក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រ និងផ្ដល់សិទ្ធិអំណាចដល់ស្ត្រី។ ការចូលរួមរបស់ស្ត្រីនៅក្នុងក្រុមក្នុងសហគមន៍ និងការងារជាសាធារណៈ បាននឹងកំពុងកើនឡើង។ ក្រុមអ្នកស្ម័គ្រចិត្តក្នុងភូមិ (មានបុរស និងស្ត្រី) និងក្រុមជួយគ្នារបស់ស្ត្រី ត្រូវបានបង្កើតឡើងដើម្បីជួយដល់ក្រុមងាយរងគ្រោះ និងក្រុមដែលមានស្ថានភាពលំបាកជាងគេ ក្នុងនោះមានទាំងស្ត្រីផងដែរ និងដើម្បីធានាថា បញ្ហាទាក់ទងនឹងសិទ្ធិ និងការលំបាកផ្សេងៗរបស់ស្ត្រីត្រូវបានដោះស្រាយ។ នៅក្នុងឃុំ/សង្កាត់ និងភូមិគេបានបង្កើតគណៈកម្មាធិការស្ត្រី និងកុមារ (WCC) ហើយនៅថ្នាក់ស្រុក និងខេត្ត គឺមានគណៈកម្មាធិការពិគ្រោះយោបល់របស់ស្ត្រី និងកុមារ (WCCC)។ គណៈកម្មាធិការទាំងពីរធ្វើការដើម្បីលើកកំពស់ និងផ្ដល់សិទ្ធិអំណាចដល់ស្ត្រី ហើយបាននិងកំពុងដំណើរការយ៉ាងល្អ ក្នុងសកម្មភាពបំផុសការយល់ដឹងនានាដោយផ្ដោតលើបញ្ហាសំខាន់ៗមួយចំនួនដូចជា ការគ្រប់គ្រងទឹក, ការរៀបចំផែនការវិនិយោគក្នុងភូមិ និងឃុំ, ការអភិវឌ្ឍកសិកម្ម និងបញ្ហាអាកាសធាតុផ្សេងៗ។ ស្ត្រីនៅក្នុងគណៈកម្មាធិការទាំងពីរបានជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមក និងលើកទឹកចិត្តស្ត្រីផ្សេងទៀតឲ្យធ្វើការស្មើដៃគ្នាជាមួយបុរស។ ឧទាហរណ៍ តួយ៉ាងនៅក្នុងឃុំ ២ ក្នុងខេត្តកំពង់ធំ ស្ត្រីមកពីគ្រប់ភូមិបានចូលរួមក្នុងក្រុមអ្នកស្ម័គ្រចិត្ត[៣] ឬក្រុមទ្រទ្រង់ភូមិ[៤] ដើម្បីជួយដល់ប្រជាជនក្នុងឃុំក្នុងពេលមានគ្រោះធម្មជាតិ ជាពិសេសទឹកជំនន់ និងគ្រោះរាំងស្ងួត។ សកម្មភាពនេះបានបង្ហាញផងដែរពីការចូលរួមចំណែកដ៏សំខាន់របស់ស្ត្រី ទាំងក្នុងការកែលំអជីវភាព និងសន្តិសុខស្បៀង និងក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

[៣] ពួកគេទទួលបានជំនួយទ្រទ្រង់ពីកាកបាទក្រហមខេត្ត ហើយធ្វើការជិតស្និទ្ធជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក ដើម្បីជួយប្រជាជនក្នុងអំឡុងពេលមានគ្រោះធម្មជាតិ។

[៤] ក្រុមទាំងនេះត្រូវបានបង្កើតឡើងក្នុងភូមិនីមួយៗ ដោយក្នុងមួយក្រុមមានបុរសពីរនាក់ និងស្ត្រីម្នាក់។ ប៉ុន្តែក្នុងភូមិខ្លះ គឺមានសមាជិកជាបុរសទាំងអស់ និងដឹកនាំដោយមេភូមិ។

ប៉ុន្តែពេលវេលា ចូលរួមក្នុងកិច្ចការសាធារណៈ សមត្ថភាព និងបទពិសោធន៍របស់ស្ត្រី ព្រមទាំងការលើកទឹកចិត្តនិងការគាំទ្រដែលពួកគេទទួលបានពីបុរស គឺនៅមានកម្រិតនៅឡើយ។ មន្ត្រីមន្ទីរកិច្ចការនារី និងមន្ទីរធនធានទឹក នៅខេត្តកំពង់ធំនិយាយថា៖ "ស្ត្រីចង់ចូលរួមក្នុងកិច្ចការសាធារណៈទាំងអស់នេះ។ ប៉ុន្តែដោយសារតែសមត្ថភាពបទពិសោធន៍ និងភារកិច្ចក្នុងគ្រួសាររបស់ពួកគេ គឺមានតែស្ត្រីមួយចំនួនតូចប៉ុណ្ណោះដែលអាចចូលរួមយ៉ាងសកម្ម។ ស្ត្រីមួយចំនួននៅតែភ័យខ្លាចក្នុងការទទួលខុសត្រូវលើការងារ ប្រសិនបើប្រជាជនបោះឆ្នោតជ្រើសតាំងគាត់ជាប្រធានគណៈកម្មាធិការ"។ ដូចនេះទោះបីរបាំងវប្បធម៌ និងការយល់ឃើញបែបបុរាណមានការធ្លាក់ចុះក្ដី ក៏បុរសនៅតែត្រូវបានគេចាត់ទុកជា អ្នកដែលគួរដើរតួនាទីសំខាន់ក្នុងសកម្មភាពសាធារណៈ និងគ្រួសារ។ ម្យ៉ាងទៀត ទោះបីជាឥទ្ធិពលនៃការយល់ឃើញបែបនេះមានការប្រែប្រួលក៏ដោយ ប៉ុន្តែវានៅតែអាចរារាំងស្ត្រីក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ។

## ធនធានចាំបាច់សម្រាប់កាត់បន្ថយឧបសគ្គនានា

ទិន្នន័យបានពីការស្រាវជ្រាវជាក់ស្ដែងបង្ហាញថាលទ្ធភាពបានប្រើប្រាស់ និងគ្រប់គ្រងលើធនធានសម្រាប់ចិញ្ចឹមជីវិត (មនុស្ស ធម្មជាតិ រូបវន្ត ហិរញ្ញវត្ថុ និងសង្គម) ជាគន្លឹះដ៏សំខាន់ (តារាង២) សម្រាប់ដាក់បញ្ចូលយ៉ាងពេញលេញនូវការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងវិស័យកសិកម្ម ជលផល ព្រៃឈើ សន្តិសុខស្បៀង និងទឹក ដើម្បីធានាជីវភាពរស់នៅក្នុងមូលដ្ឋាន។

បុរស និងស្ត្រីមានសិទ្ធិ និងលទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់ធនធាន ប៉ុន្តែធនធានរូបវន្ត និងធនធានធម្មជាតិ (ដី ទឹក និងប្រព័ន្ធស្រោចស្រព) ត្រូវតែប្រើប្រាស់ និងគ្រប់គ្រងឲ្យបានកាន់តែប្រសើរដោយត្រូវគិតគូរដល់ស្ត្រី កុមារ និងក្រុមងាយរងគ្រោះផ្សេងៗ។ ដើម្បីអភិវឌ្ឍន៍គ្រប់គ្រង និងថែទាំប្រព័ន្ធស្រោចស្រព អាងស្ដុកទឹក ទំនប់ការពារទឹកជំនន់ និងហេដ្ឋារចនាសម្ព័ន្ធនៅជនបទ គឺត្រូវមានធនធានហិរញ្ញវត្ថុ និងធនធានមនុស្សគ្រប់គ្រាន់ដើម្បីជួយទ្រទ្រង់ និងផ្ដល់ការណែនាំផ្នែកបច្ចេកទេសឲ្យចំគោលដៅ និងទាន់ពេលវេលា និងដើម្បីពិនិត្យតាមដាន និងលើកកំពស់ការយល់ដឹងការចូលរួមតំណាងស្ត្រី សមត្ថភាព និងភាពធន់របស់ស្ត្រី។ មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរខេត្តបានដើរតួនាទីដ៏សំខាន់ក្នុងការជួយគាំទ្រស្ត្រី ឲ្យយល់ដឹងពីសិទ្ធិរបស់ស្ត្រី និងពង្រីកតួនាទីរបស់ពួកគេក្នុងកិច្ចការសាធារណៈ។

នៅថ្នាក់ក្រោមជាតិ បណ្ដាញស្ត្រីគឺជាយន្តការឆ្លើយតប ដែលអាចគាំទ្រ និងទ្រទ្រង់ស្ត្រីនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា។ តួយ៉ាងមន្ទីរកិច្ចការនារីពឹងលើបណ្ដាញរបស់ពួកគេផ្ទាល់នៅក្នុងភូមិ (ក្រុមជួយគ្នារបស់ស្ត្រី) ដើម្បីជួយទ្រទ្រង់ស្ត្រីក្នុងភូមិ ឬឃុំ ដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ ពីព្រោះការឆ្លើយតបរបស់ថ្នាក់ស្រុក ជួនកាលមិនទាន់ពេលវេលាឬនៅឆ្ងាយពេក។ ក្រុមជួយគ្នារបស់ស្ត្រីក្នុងឃុំ ឬភូមិ អាចជួយទ្រទ្រង់ និងគាំទ្រស្ត្រីក្នុងមូលដ្ឋានគ្រប់ពេលវេលាបានយ៉ាងល្អ។ ពួកគេឆ្លើយតបបានរហ័ស និងចេះលើកទឹកចិត្តស្ត្រីក្នុងមូលដ្ឋានឲ្យទៅទទួលការសិក្សា និងបណ្ដុះបណ្ដាល។

តារាង ២៖ ធនធានត្រូវការអាទិភាពនិងឧបសគ្គផ្សេងៗ

| ប្រភេទ | ធនធានត្រូវការ | អាទិភាព | ឧបសគ្គ |
|---|---|---|---|
| ធនធានធម្មជាតិ | ទឹក, ដី, បឹង, ស្ទឹង, ព្រៃឈើ, ត្រីនិងទឹកភ្លៀង | ការអភិវឌ្ឍវិស័យកសិកម្ម និងចំណាយប្រើប្រាស់ប្រចាំថ្ងៃ<br>ការកែលំអការគ្រប់គ្រងធនធានធម្មជាតិ និងអភិបាលកិច្ច | ការប្រែប្រួលអាកាសធាតុ<br>ភូមិសាស្ត្រ<br>ប្រព័ន្ធស្រោចស្រព<br>អភិបាលកិច្ចធនធានធម្មជាតិ |
| ធនធានរូបវន្ត | ទំនប់បង្ហៀរ, ទំនប់ទឹក, ប្រឡាយ និងប្រព័ន្ធរំដោះទឹក<br>ស្ថានីយ៍បូមទឹក, ម៉ាស៊ីនបូមទឹក, ផ្លូវថ្នល់ , ទ្វារទឹក និងស្ពាន | ការពង្រីកប្រព័ន្ធស្រោចស្រព<br>ការដឹកជញ្ជូន<br>ការពង្រឹងការគ្រប់គ្រងដី និងទឹក | មូលនិធិមានកំណត់ (សម្រាប់ការសាងសង់, ប្រតិបត្តិការ និងការថែទាំ)<br>អភិបាលកិច្ចធនធានទ្រព្យរួម |
| ធនធាន ហិរញ្ញវត្ថុ | មូលនិធិគ្រួសារ ធនាគារ<br>ថ្លៃសេវាស្រោចស្រព<br>ធនាគារស្រូវ<br>ក្រុមសន្សំប្រាក់<br>ទីផ្សារ | អាហារប្រចាំថ្ងៃ និងអាហារូបត្ថម្ភ<br>សុខភាព និងថាមពលរាងកាយ<br>ការកែលំអប្រព័ន្ធស្រោចស្រព<br>ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្ម | ការសងប្រាក់កម្ចី<br>ការប្រមូលនិងគ្រប់គ្រងថ្លៃសេវាស្រោចស្រព<br>ថ្លៃទីផ្សារសម្រាប់ផលិតផលកសិកម្ម គ្មានស្ថិរភាព និងគ្រប់គ្រងមិនបាន |
| ធនធានមនុស្ស | មន្ទីរធនធានទឹក, មន្ទីរកសិកម្ម, មន្ទីរបរិស្ថាន, មន្ទីរកិច្ចការនារី និងមន្ទីរពាក់ព័ន្ធ ឯទៀត<br>អាជ្ញាធរមូលដ្ឋាន និងក្រុមក្នុងភូមិ | បច្ចេកទេសកសិកម្ម,<br>អភិបាលកិច្ចទឹក និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ<br>បច្ចេកទេសសាបព្រួស និងដាំដុះ<br>ការកែច្នៃ និងការរក្សាផលិតផលកសិកម្ម<br>ការអប់រំ និងការបញ្ជ្រាបយេនឌ័រ<br>ការពង្រឹងសិទ្ធិអំណាច, ចំណេះដឹង និងសមត្ថភាពរបស់ស្ត្រី<br>ការបង្កើនប្រាក់ចំណូល និងការចូលរួមរបស់ស្ត្រី | សមត្ថភាពផ្ដល់ការអប់រំផ្នែកកសិកម្ម,<br>សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម,<br>ការស្រាវជ្រាវ និងការបង្ហាញតវិយាបថ និងចំណេះដឹងរបស់កសិករអំពីការជ្រើសរើសពូជស្រូវ និងបច្ចេកទេសកសិកម្ម<br>ការអប់រំ, ការយល់ឃើញ និងការអនុវត្តជាក់ស្ដែងដោយកសិករ |
| ធនធានសង្គម | សកបទ<br>អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ<br>កាកបាទក្រហម និង<br>គណៈកម្មាធិការ<br>ខេត្តគ្រប់គ្រងគ្រោះមហន្តរាយ<br>WCCs, WCCCs, ក្រុមជួយគ្នារបស់ស្ត្រី, ក្រុមស្ម័គ្រចិត្ត<br>ក្រុមសន្សំប្រាក់<br>អង្គការមិនមែនរដ្ឋាភិបាល | ការផ្ដល់ការគាំទ្រ និងទំនុកចិត្តដល់ការចូលរួមរបស់ស្ត្រី<br>ការលើកកម្ពស់សិទ្ធិអំណាច, ការយល់ដឹង និងសមត្ថភាពរបស់ស្ត្រី<br>ការលើកកម្ពស់សិទ្ធិ និងលទ្ធភាពរបស់ស្ត្រី ក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធាននិងក្នុងការសម្រេចចិត្ត | កង្វះយន្តការជាក់ស្ដែងសម្រាប់ការបញ្ជ្រាបយេនឌ័រ និងការផ្ដល់សិទ្ធិអំណាច<br>ចំណេះដឹង និងជំនាញរបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន<br>របាំងផ្នែកអប់រំ និងវប្បធម៌<br>ការចូលរួម, ឱកាស និងការប្ដេជ្ញាចិត្តរបស់ស្ត្រី |

ប្រភព៖ ការវិភាគរបស់អ្នកនិពន្ធ

ក្នុងអំឡុងពេលមានគ្រោះធម្មជាតិ អាជ្ញាធរខេត្ត, ស្រុក និងមូលដ្ឋាន តាមរយៈគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ តែងជួយសម្របសម្រួល ដល់ការឆ្លើយតបនឹងការផ្ដល់ជំនួយបន្ទាន់ ការផ្ដល់ដំណឹងអំពីគ្រោះមហន្តរាយ និងដំណឹងចាំបាច់នានាដើម្បីជួយដល់ប្រជាជនមូលដ្ឋានទាន់ពេលវេលា។ កាកបាទក្រហមកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាល (NGO) ជាច្រើនក៏ចូលរួមជួយផងដែរ។ ជំនួយទាំងនោះមានដូចជាការកំណត់ទីតាំងសុវត្ថិភាពសម្រាប់ការជម្លៀស, ការផ្ដល់គ្រាប់ពូជ ជី ការបណ្ដុះបណ្ដាល និងការបង្ហាត់បង្ហាញជាក់ស្ដែងដើម្បីជួយកសិករស្ដារជីវភាពឡើងវិញ។ បុរស ស្ត្រី និងក្រុមដែលមានភាពលំបាកជាងគេសុទ្ធតែមានសិទ្ធិស្មើគ្នាក្នុងការទទួលបានសេវាទាំងនេះ។

ឧបសគ្គមួយផ្នែក បណ្ដាលមកពីទីតាំងភូមិសាស្ត្រមិនអំណោយផល និងកង្វះប្រព័ន្ធស្រោចស្រព បានធ្វើឲ្យកសិករមួយចំនួន ខ្វះលទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹកទៀងទាត់ និងអាចទុកចិត្តបានសម្រាប់ដាំដំណាំ ហើយបញ្ហាកង្វះខាតទឹក តែងនាំឲ្យមានជម្លោះលើការប្រើប្រាស់ទឹក និងការខូចខាតផលដំណាំ។ ក្នុងគម្រោងមួយចំនួនដែលបានសិក្សា ស្ត្រីជនបទទីទ័លក្រ និងគ្រួសារកសិករមានស្ត្រីជាមេគ្រួសារ ដែលមានដីស្រែនៅឆ្ងាយពីប្រឡាយមេ មិនអាចទប់ទល់បញ្ហាបង្កដោយគ្រោះធម្មជាតិបានទេ ទោះបីមានយន្តការផ្ដល់ជំនួយផ្សេងៗត្រូវបានបង្កើតឡើងរួចទៅហើយក្ដី (តារាង២)។ ជាទូទៅ កសិករមានដីស្រែតូចៗ និងខ្វះខាតទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ។ ទោះបីបច្ចុប្បន្នលទ្ធភាពទទួលបានឥណទានពីក្រុមហ៊ុនឯកជន ធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ បានប្រសើរឡើងជាងកាលពីមុនក្ដី ក៏វានៅតែមិនអាចដោះស្រាយបញ្ហាដែលកសិករ កំពុងប្រឈមនោះទេ ហើយកសិករនៅតែមានការរារែកក្នុងការខ្ចីប្រាក់ ពីព្រោះ

ពួកគាត់បារម្ភពីសមត្ថភាពរបស់ខ្លួន ក្នុងការសងប្រាក់នោះវិញ។ ហើយទោះបីមានយន្តការបញ្ជ្រាបយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្តី (ខ្លះអនុវត្តដោយស្ថាប័នរដ្ឋ, ក្រុមការងារសង្គមក្នុងមូលដ្ឋាន និង NGOs) ក៏កម្រិតនៃចំណេះដឹង (ជាពិសេសស្ត្រី) និងរបៀបរបបសង្គមវប្បធម៌នៅតំបន់ជនបទ នៅតែបន្តរារាំងកសិករក្នុងការទទួលយក និងអនុវត្តពេញលេញ នូវការបញ្ជ្រាបយេនឌ័រ និងការផ្តល់សិទ្ធិអំណាចឲ្យស្ត្រីនៅឡើយ។[៥]

## សេចក្តីសន្និដ្ឋាន

រដ្ឋាភិបាល បាននឹងកំពុងបញ្ជ្រាបគោលនយោបាយយេនឌ័រទៅក្នុងការងារអភិបាលកិច្ចធនធានទឹក, ការអភិវឌ្ឍកសិកម្ម និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីលើកកម្ពស់ការបែងចែកទឹក, ផលិតកម្មដំណាំ, កិច្ចការពារ និងទប់ទល់គ្រោះរាំងស្ងួត និងទឹកជំនន់ និងភាពធន់នៃជីវភាពរស់នៅរបស់កសិករ ហើយការងារនេះកំពុងវិវឌ្ឍទៅមុខគួរអោយកត់សំគាល់ (MAFF 2006; MOWRAM 2007b; MOWA 2013)។ ទោះយ៉ាងនេះក្តី ជាទូទៅ ស្ត្រីនៅមានបទពិសោធន៍ និងជំនាញតិចជាងបុរសនៅឡើយក្នុងការគ្រប់គ្រងទឹក និងប្រព័ន្ធធារាសាស្ត្រ។ ការចូលរួមរបស់ពួកគេក្នុងការងាររបស់ភូមិ ឃុំ ក៏នៅតែត្រូវបានរារាំងដោយតួនាទី ទាំងក្នុងការងារដែលទទួលបានប្រាក់កំរៃ និងមិនបានប្រាក់កំរៃផងដែរ។ បុរសនៅតែមានប្រៀបជាងស្ត្រីក្នុងការកាន់កាប់ លើមុខតំណែងសំខាន់ៗក្នុងគណៈកម្មាធិការ សកបទ ហើយស្ត្រីកម្របានកាន់កាប់មុខងារ និងតួនាទីដែលមានសិទ្ធិសម្រេចលើការងារសំខាន់ៗណាស់។ សរុបមក ចំនួន និងទំនាក់ទំនងអំណាចមិនស្មើគ្នា បានបន្ថយបង្អាក់ដល់ការប្តេជ្ញាចិត្តរបស់ស្ត្រីដើម្បីចូលរួមក្នុងការងារភូមិ ឃុំ និងសហគមន៍។ ស្ត្រីមានលទ្ធភាពតិចជាងបុរសក្នុងការប្រើប្រាស់ និងគ្រប់គ្រងលើធនធានចាំបាច់នានា ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ កត្តាទាំងនេះ បានបណ្តាលឲ្យសំឡេងរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច លើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ, ការសាងសង់ទំនប់ការពារទឹកជំនន់ និងគ្រោះរាំងស្ងួត និងគម្រោងអភិវឌ្ឍន៍ឃុំ ត្រូវបានមើលរំលង ហើយឧបសគ្គចំពោះស្ត្រីនានាក៏នៅតែកើតមាន។

កសិករកំពុងប្រឈមនឹងផលប៉ះពាល់ កាន់តែច្រើនឡើងដែលទាក់ទងនឹងអាកាសធាតុ។ ការកែលំអអភិបាលកិច្ចធនធានទឹក, ការពង្រីកប្រព័ន្ធធារាសាស្ត្រ និងយន្តការជួយទ្រទ្រង់កសិករនៅមូលដ្ឋាន មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ជួយដោះស្រាយបញ្ហានិងកសាងភាពធន់ក្នុងជីវភាពរបស់កសិករដែលកំពុងរស់នៅតាមជនបទ។ ដោយហេតុថា សមភាពយេនឌ័រ ការផ្តល់សិទ្ធិអំណាចឲ្យស្ត្រី និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ដូច្នេះ ត្រូវដាក់បញ្ចូលគោលគំនិតផ្នែកយេនឌ័រ ទៅក្នុងការធ្វើផែនការ និងការអនុវត្តសកម្មភាពដើម្បីឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុនៅគ្រប់កម្រិត និងគ្រប់វិស័យ។ការធ្វើបែបនេះនឹងធានាឲ្យការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការងារផ្គត់ផ្គង់ទឹក កិច្ចការពារទប់ទល់នឹងទឹកជំនន់ ការអភិវឌ្ឍកសិកម្ម និងការងារដើម្បីកំណើនសេដ្ឋកិច្ច សម្រាប់គ្រប់គ្នាមានការអភិវឌ្ឍកាន់តែល្អប្រសើរឡើង។ ការងារទាំងនេះក៏នឹងធានាថាសិទ្ធិទំនួលខុសត្រូវ ឱកាស និងអត្ថប្រយោជន៍របស់បុរស និងស្ត្រី ត្រូវបានផ្តល់ និងបែងចែកប្រកបដោយសមធម៌ ព្រមទាំងត្រូវបានការពារយ៉ាងល្អផងដែរ។ កិច្ចសហការរវាងមន្ទីរពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ អាជ្ញាធរមូលដ្ឋាន សហគមន៍ និងអង្គការសង្គមស៊ីវិលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សិទ្ធិ លទ្ធភាពប្រើប្រាស់បាន និងការគ្រប់គ្រងរបស់ស្ត្រីទៅលើធនធានចាំបាច់នានា ដើម្បីកាត់បន្ថយគ្រោះមហន្តរាយទាំងឡាយ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

## ឯកសារយោង


Khmer View (2013), "History of Cambodia", http://www.khmerview.com/History-of-Cambodia.html (accessed 20 February 2013)

Kumar, Krishna , Hannah Baldwin and Judy Benjamin (2000), *Aftermath: Women And Women's Organizations In Postconflict Cambodia,* Working Paper No. 307, http://pdf.usaid.gov/pdf_docs/pnacj327.pdf (accessed 5 February 2013)

MAFF, Ministry of Agriculture, Forestry and Fisheries (2006), *Gender Mainstreaming Policy and Strategy* (Phnom Penh: MAFF)

MOWA, Ministry of Women's Affairs (2013), *Neary Rattanak IV – Five Year Strategic Plan 2014-2018 (first outline)* (Phnom Penh: MOWA)

MOWRAM, Ministry of Water Resources and Meteorology (2005), *Cambodia IWRM strategy and Road Map,* http://www.gwpsea.org/index.php?option=com_docman&task=doc_download&gid=5&Itemid=135 (accessed 2 January 2013)

MOWRAM (2007a), *Law on Water Resources Management of the Kingdom of Cambodia*. (Phnom Penh: MOWRAM)

MOWRAM (2007b), *Gender Mainstreaming Strategy 2007-2010* (Phnom Penh: MOWRAM)

Nang Phirun (2013), *Climate Change Adaptation and Livelihoods in Inclusive Growth: A Review of Climate Change Impacts and Adaptive Capacity in Cambodia,* CDRI Working Paper Series No. 82 (Phnom Penh: CDRI)

Nang Phirun and Ouch Chhuong (2014), *Gender and Water Governance: Women's Role in Irrigation Management and Development in the Context of Climate Change,* CDRI Working Paper Series No. 89 (Phnom Penh: CDRI)

Ross, Russell R. and Andrea Matles Savada (1989),"History of Cambodia", http://motherearthtravel.com/cambodia/history.htm (accessed 20 February 2013)

WEN,Women's Environmental Network (2010), *Gender and The Climate Change Agenda: The Impacts of Climate Change on Women and Public Policy,* http://www.wen.org.uk/wp-content/uploads/Gender-and-the-climate-change-agenda-21.pdf (accessed 6 May 2012)

UN WomenWatch (2009), Women, Gender Equality and Climate Change, http://www.un.org/womenwatch/feature/climate_change/downloads/Women_and_Climate_Change_Factsheet.pdf (accessed28 January 2014)


[៥] ក្នុងអំឡុងពេលធ្វើសម្ភាសន៍នៅតំបន់មួយចំនួន កសិករខ្លះមានយោបល់ថាមកទល់បច្ចុប្បន្នរបៀបរបបសង្គមនិងវប្បធម៌ដែលនៅចាក់ឫសជ្រៅក្នុងសង្គមរួមមាន៖ ស្ត្រីគួរតែស្តាប់ ឬគោរពប្រតិបត្តិប្តី ឬថ្នាក់ដឹកនាំ និងមិនគួរនិយាយស្តីច្រើនទេក្នុងកិច្ចប្រជុំជាសាធារណៈ ហើយស្ត្រីគួរធ្វើការងារក្នុងផ្ទះ នៅតែមានក្នុងតំបន់របស់ពួកគាត់។

# ការសិក្សាតាមដានបន្តពីផលប៉ះពាល់នៃអង្គការកសិករទៅលើផលិតភាពស្រូវ និងផលិតកម្មសត្វចញ្ចឹម[១]

## សេចក្ដីផ្ដើម

ហេតុផលសំខាន់ក្នុងការបង្កើតអង្គការកសិករ (FOs) គឺការផ្ដល់សេវាទ្រទ្រង់ប្រកបដោយប្រសិទ្ធភាព និងជាសមូហភាពសម្រាប់កសិករតូចតាច ដើម្បីកាត់បន្ថយឧបសគ្គចម្បងៗ ដែលធ្វើឲ្យកិច្ចប្រឹងប្រែងផ្សេងៗ ពុំមានប្រសិទ្ធភាពក្នុងការបង្កើនផលិតភាព និងពង្រឹងសិទ្ធិអំណាចជាសមូហភាពរបស់ផលិតករខ្នាតតូច នៅក្នុងទីផ្សារធាតុចូល និងធាតុចេញ។ ផ្អែកតាមទ្រឹស្ដី FOs គួរអាចពង្រឹងអំណាចចរចារបស់កសិករ និងកាត់បន្ថយចំណាយប្រតិបត្តិការ ដែលអាចជួយបង្កើនសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ តាមការបង្កើនចំណូល និងជំរុញការអភិវឌ្ឍជនបទ និងកសិកម្មប្រកបដោយចីរភាព (Barham and Chitemi 2007; Bachke 2010)។

នៅកម្ពុជា ប្រជាជនក្រីក្រជាង ៩០% រស់នៅតំបន់ជនបទ និងពឹងផ្អែកលើកសិកម្មជាប្រភពចម្បងនៃការចិញ្ចឹមជីវិត។ វិស័យកសិកម្មកម្ពុជា មានលក្ខណៈសម្គាល់ជាការដាំដុះខ្នាតតូច៖ ប្រជាកសិករនៅជនបទប្រមាណ ៨៤% មានដីកសិកម្មតិចជាងមួយហិកតា (World Bank 2005, 2009)។ ការសិក្សាមួយចំនួនបង្ហាញថា កសិករខ្នាតតូច នឹងមិនអាចពង្រីកផលិតភាព ឬអំណាចចរចារបស់ខ្លួននៅចំពោះមុខ កសិដ្ឋានពាណិជ្ជកម្មនិងអ្នកទិញធំៗបានទេ លើកលែងតែមានបទបញ្ញត្តិច្បាប់សម្រួលឲ្យកសិករខ្នាតតូចបង្កើតជា អង្គការផលិតករនៅតាមជនបទ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ក៏មានដំណើរការដូច្នេះដែរ (Couturier *et al.* 2006; Nou 2006; Bingen *et al.* 2003; Chirwa *et al.* 2005; Peacock *et al.* 2004; Abaru *et al.* 2006; Barham and Chitemi 2007)។

ឯកសារពាក់ព័ន្ធបង្ហាញថា ចាប់តាំងពីពេលរាជរដ្ឋាភិបាលកម្ពុជាបានលើកពីសារៈសំខាន់នៃ FOs និង តួនាទីជាយុទ្ធសាស្ត្រនៃវិស័យឯកជន ក្នុងការអភិវឌ្ឍជនបទ និងកសិកម្មមក មានការសិក្សាតិចតួចណាស់ ដែលបានពិនិត្យពីឥទ្ធិពលនៃ FO ទៅលើជីវភាពនៅជនបទ។ ការសិក្សាកន្លងមក បានព្យាយាមកំណត់ពីស្ថានភាព FOs តាមការវាយតម្លៃពី ចំនួននិងប្រភេទនៃអង្គការ, ដំណើរការចុះបញ្ជីរបស់ FO, បញ្ហាធំៗ ដែល FOs កំពុងប្រឈមមុខ, កត្តាខាងក្នុង និងក្រៅ ដែលប៉ះពាល់ដល់ជោគជ័យរបស់ FOs, និងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលត្រូវមានសម្រាប់ជំរុញការអភិវឌ្ឍ FOs នៅកម្ពុជា (Couturier *et al.* 2006; Nou 2006; Ngin 2010; Chea 2010)។ ការសិក្សាទាំងអស់នេះ បានប្រើវិធីសាស្ត្របែបគុណភាព ហើយបានផ្ដល់នូវស្ថិតិបែបពណ៌នាមួយចំនួន។

អង្កេតមូលដ្ឋានមួយធ្វើឡើងដោយវិទ្យាស្ថាន CDRI នៅឆ្នាំ ២០១១ ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃ FOs ទៅលើសន្តិសុខស្បៀងរបស់ប្រជាជននៅជនបទកម្ពុជា បានបង្ហាញថា ការចូលរួមក្នុង FO មានផលប៉ះពាល់វិជ្ជមានទៅលើសន្តិសុខស្បៀងរបស់គ្រួសារនៅតាមជនបទ ឆ្លងតាមការល្អប្រសើរឡើងក្នុងផលិតភាពស្រូវ និងផលិតកម្មសត្វចិញ្ចឹម (CDRI 2012)[២]។ ការសិក្សានោះជាអង្កេតនៅចំណុចមួយនៃពេលវេលា និងមានគោលបំណងចម្បងកំណត់នូវបរិមាណនៃអថេរខ្លះ ក្នុងចំណោមប្រជាជនជាសំណាក ដោយប្រើវិធីសាស្ត្រ Propensity score matching (PSM)។ នៅឆ្នាំ២០១៣ អង្កេតតាមដានបន្តមួយបានអនុវត្តឡើងដើម្បីជួយបំពេញដល់ការសិក្សាវាយតម្លៃពីផលប៉ះពាល់។[៣] គោលបំណងនៃអង្កេតតាមដានបន្តនោះ គឺវាយតម្លៃឥទ្ធិពល FOs ទៅលើផលិតភាពរបស់កសិករខ្នាតតូច ដោយផ្អែកលើ ទិន្នផលស្រូវគិតជាគីឡូក្រាមក្នុងដីមួយហិកតាដែលបានប្រមូលផល និងប្រាក់ចំណូលពីការចិញ្ចឹមសត្វ (ជ្រូក និងមាន់)។

ការសិក្សានេះ ប្រើប្រាស់ទិន្នន័យបានពីអង្កេតតាមដានតាមពេលបន្តបន្ទាប់ ដើម្បីប៉ាន់ស្មានពីឥទ្ធិពល FOs ដោយប្រើវិធីប៉ាន់ស្មានពីភាពខុសគ្នាក្នុងភាពខុសគ្នា (Difference-in-differences (DiD) estimation)។ ដោយប្រើបច្ចេកទេសនេះ យើងអាចកំណត់ថា តើ FOs មានឥទ្ធិពលខ្លាំងលើការបង្កើនផលិតភាពស្រូវ និងសត្វចិញ្ចឹមរបស់កសិករកម្ពុជា ជាពិសេសកសិករខ្នាតតូច ដែរឬទេ។

ការសិក្សានេះរួមចំណែកបានពីរយ៉ាង ក្នុងការពង្រឹងចំណេះដឹងក្នុងផ្នែកនេះ។ ទី១ ដោយប្រើ DiD យើងបានវិភាគពីទំនាក់ទំនងរវាងសមាជិក FO នឹងផលិតភាពកសិកម្ម ។ ទី២ ដោយប្រើទិន្នន័យតាមពេលបន្តបន្ទាប់ យើងបានវិភាគពីប្រសិទ្ធភាព FOs ទៅលើជីវភាពនៅតាមជនបទកម្ពុជា ។ ការសិក្សានេះបានធ្វើការស្រាវជ្រាវបន្ថែមលើការសិក្សាពីមុនធ្វើឡើងដោយ CDRI នៅឆ្នាំ២០១១ (CDRI 2012)។ ខុសប្លែកពីទិន្នន័យលើចំណុចមួយនៃពេលវេលាដែលបានប្រើនៅក្នុងការសិក្សាពីមុន ការប្រើទិន្នន័យតាមពេលបន្តបន្ទាប់នេះ ផ្ដល់នូវការប៉ាន់ស្មានដ៏ល្អពីឥទ្ធិពលនៃ FOs (Khandker *et al.* 2010)។

---

[១] រៀបរៀងដោយ ឈឹម ឈន់ និង កែវ សុជាតិ ជាអ្នកស្រាវជ្រាវ នៃកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅ CDRI។ រិទ្ធី ឡុងឌី ជាមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃនៅនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ នៃក្រសួងអភិវឌ្ឍន៍ជនបទ។

[២] លទ្ធផលសិក្សាមួយចំនួនត្រូវបានបោះពុម្ពផ្សាយដោយ CDRI (Theng *et al.* 2011; Keo 2013), ហើយអាចរកបានក្នុង www.cdri.org.kh

[៣] អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ USAID ចំពោះការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុដ៏សប្បុរសដល់ការសិក្សាតាមដានបន្ត ដែលបានធ្វើឡើងនៅឆ្នាំ២០១៣។ អ្នកនិពន្ធសូមអរគុណផងដែរដល់ អ្នកបណ្ដុះបណ្ដាលនានា ដែលបានផ្ដល់នូវវគ្គបណ្ដុះបណ្ដាល "វគ្គខ្លីស្ដីពីការវាយតម្លៃកម្មវិធីសម្រាប់អ្នកវិជ្ជាជីវៈនៅពាក់កណ្ដាលអាជីពផ្នែកកសិកម្ម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ" ជាពិសេសសាស្ត្រាចារ្យ Suvedi Murari ពី Michigan State University, USA។

តារាង១: ចំនួន FOs និងគ្រួសារត្រូវបានជ្រើសរើស គិតតាមខេត្ត

| ខេត្ត | ចំនួន FOs | | គ្រួសារត្រូវបានជ្រើសរើស | | |
|---|---|---|---|---|---|
| | សរុប | ត្រូវបានជ្រើសរើស | សមាជិក FO | មិនមែនសមាជិក FO | សរុប |
| កំពង់ធំ | 328 | 15 | 94 | 104 | 198 |
| បាត់ដំបង | 411 | 19 | 119 | 132 | 251 |
| ស្វាយរៀង | 573 | 13 | 72 | 83 | 155 |
| កំពត | 143 | 7 | 45 | 50 | 95 |
| សរុប | 1455 | 54 | 330 | 369 | 699 |

ប្រភព: CDRI 2012

## វិធីសាស្ត្រប៉ាន់ស្មាន

គោលដៅស្រាវជ្រាវរបស់យើង គឺវិភាគពីឥទ្ធិពលនៃការចូលរួមក្នុង FO ទៅលើផលិតភាពកសិកម្ម ជាពិសេសស្រូវនិងសត្វចិញ្ចឹម ដោយប្រើទិន្នន័យលើរយៈពេលពីរ បានពីអង្កេតមូលដ្ឋានក្នុងឆ្នាំ ២០១១ និង អង្កេតបន្តក្នុងឆ្នាំ២០១៣។ យើងបានបែងចែកសំណាកគំរូពីរក្រុម: ក្រុមរងប្រព្រឹត្តិកម្ម ដែលមានកសិករជាសមាជិក FO, និងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល ដែលមានកសិករមិនបានចូលរួមក្នុង FO។ ដើម្បីវាយតម្លៃឥទ្ធិពលរបស់ FO យើងបានប្រើការប៉ាន់ស្មាន DiD។

ការប៉ាន់ស្មាន DiD គណនាពី ភាពខុសគ្នាជាមធ្យមនៃលទ្ធផលបានសង្កេតឃើញតាមពេលបន្តបន្ទាប់ សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម និងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ ក្រោយបានគិតបញ្ចូលនូវភាពខុសគ្នាបន្ថែមទៀត រវាងការប្រែប្រួលជាមធ្យមក្នុងលទ្ធផលរបស់ក្រុមទាំងពីរ យើងអាចកំណត់ ប្រសិទ្ធភាពប្រព្រឹត្តិកម្មបាន ពោលគឺ ផលប៉ះពាល់ប៉ាន់ស្មាននៃបញ្ហាកំពុងយកមកវាយតម្លៃ - ក្នុងករណីនេះ គឺ ឥទ្ធិពលនៃការចូលជាសមាជិក FOs។

## ទិន្នន័យ

ការសិក្សានេះប្រើទិន្នន័យប្រមូលបានពីគ្រួសារនៅឆ្នាំ២០១១ សម្រាប់ការវាយតម្លៃផលប៉ះពាល់គោល និងទិន្នន័យមួយសំណុំទៀតប្រមូលបានពីគ្រួសារដដែលនៅឆ្នាំ២០១៣ ដែលជាអង្កេតបន្ត។ អង្កេតទាំងពីរ បានប្រមូលព័ត៌មានអំពីសមាជិក FO និងគ្រួសារមិនមែនជាសមាជិក FO ដូចជា ស្ថានភាពផ្ទះសម្បែង, ទ្រព្យសម្បត្តិជាប់លាប់, កម្មសិទ្ធិដីធ្លី, ផ្ទៃដីប្រមូលផល, ទិន្នផលស្រូវ, សត្វចិញ្ចឹម, សកម្មភាពមិនមែនកសិកម្ម, ឥណទាន និងប្រាក់កម្ចី។ យើងបានធ្វើសម្ភាសន៍ទល់មុខគ្នាជាមួយ មេគ្រួសារ ប្តីឬប្រពន្ធរបស់មេគ្រួសារ ឬ សមាជិកគ្រួសារពេញវ័យផ្សេងទៀត។

អង្កេតគោល[៤] បានធ្វើឡើងក្នុងបួនខេត្ត គឺ កំពង់ធំ, បាត់ដំបង, ស្វាយរៀង និង កំពត។ ការជ្រើសរើសសំណាក បានធ្វើឡើងជាបីជំហាន។ ជំហានទី១ គឺ ការជ្រើសរើស FOs, ជំហានទី២ គឺ ការកំណត់ស្រុកជាគោលដៅក្នុងខេត្តនីមួយៗ (បីស្រុកក្នុងខេត្តបាត់ដំបង និងពីរៗស្រុកក្នុងខេត្តបីផ្សេងទៀត) និង ជំហានទី៣ គឺ ការជ្រើសរើសគ្រួសារ (តារាង ១)។

តារាង ២: ចំនួនគ្រួសារបានធ្វើសម្ភាសន៍ក្នុងខេត្តកំពត

| លក្ខណៈគ្រួសារ | អង្កេតគោល (2011) | អង្កេតតាមដានបន្ត (2013) |
|---|---|---|
| សមាជិក | 45 | 43 |
| មិនមែនសមាជិក | 47 | 43 |
| សរុប | 92 | 86 |

ប្រភព: ការគណនារបស់អ្នកនិពន្ធ

សម្រាប់ការសិក្សាតាមដានបន្តនេះ ដោយសារធនធានមានកម្រិត យើងបានជ្រើសយកតែខេត្តកំពតមួយប៉ុណ្ណោះ។ អង្កេតគោលឆ្នាំ២០១១ បានប្រើ Propensity score matching (PSM) ដើម្បីប្រៀបធៀប អថេរផលប្រយោជន៍ រវាងក្រុមរងប្រព្រឹត្តិកម្ម នឹងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ វិធីសាស្ត្រនេះជ្រើសរើសក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល ដោយធ្វើការផ្គូរផ្គងអ្នកចូលរួម និងអ្នកមិនចូលរួម ផ្អែកលើមូលដ្ឋាននៃភាពស្រដៀងគ្នាក្នុងលក្ខណៈសំគាល់ដែលបានសង្កេតឃើញ។ ការប្រើប្រាស់ PSM គឺដើម្បីកាត់បន្ថយភាពលំអៀង និងការប្រែប្រួលខុសភាពដើមផ្សេងៗដែលអាចកើតមាន។ អថេរនានាបានជ្រើសយកមកប្រើប្រាស់ ដោយផ្អែកលើកត្តាកំណត់ផ្សេងៗនៃការចូលរួមក្នុង FOs ដែលរួមមានលក្ខណៈមេគ្រួសារ ធនធានដែលគ្រួសារមាន និងលក្ខណៈទីតាំងគ្រួសារ។ ការប្រើប្រាស់ PSM ក្នុងអង្កេតគោល ជួយធានាថា គ្រួសារក្នុងក្រុមទាំងពីរ មានលក្ខណៈអាចប្រៀបធៀបគ្នាបាន។ ដូចមានចុះក្នុង តារាង ២ យើងប្រើទិន្នន័យលើ ៩២ គ្រួសារក្នុងខេត្តកំពត ដើម្បីធ្វើវិភាគគោល ប៉ុន្តែ តំណាងរបស់ ៦ គ្រួសារ បានអវត្តមានក្នុងអំឡុងពេលធ្វើអង្កេតតាមដានបន្ត ធ្វើឱ្យយើងមានទិន្នន័យតែលើ ៨៦គ្រួសារ (៤៣គ្រួសារក្នុងមួយក្រុម)។

## លទ្ធផល

តារាង ៣ បង្ហាញនូវ លទ្ធផលស្ថិតិបែបពិពណ៌នា ពោលគឺ លក្ខណៈជាមូលដ្ឋាននៃទិន្នន័យនៃអង្កេតគោល និងអង្កេតតាមដានបន្ត។ ក្នុងចំណោមគ្រួសារត្រូវបានអង្កេត គ្រួសារមានបុរស

[៤] ដោយសារតែមិនមានបញ្ជី FOs នាបច្ចុប្បន្នភាព គេប្រើបញ្ជី FOs ដែលមានស្រាប់ក្នុងខេត្តទាំងបួន ជាគំរូសម្រាប់ ការស្ទង់មតិ (អង្កេត) ជាមូលដ្ឋាននេះ។

តារាង ៣: លក្ខណៈគ្រួសារ

| ការពិពណ៌នា | | អង្កេតគោល (2011) | | អង្កេតតាមដានបន្ត (2013) | |
|---|---|---|---|---|---|
| | | ប្រព្រឹត្តិកម្ម | ផ្ទៀងផ្ទាត់ | ប្រព្រឹត្តិកម្ម | ផ្ទៀងផ្ទាត់ |
| ភេទមេគ្រួសារ (%): | បុរស | 75.6 | 78.7 | 70.0 | 84.0 |
| | ស្ត្រី | 24.4 | 21.3 | 30.0 | 16.0 |
| អាយុមេគ្រួសារ (ឆ្នាំ) | | 47.0 | 46.0 | 50.0 | 49.0 |
| ឆ្នាំសិក្សាមេគ្រួសារ (ឆ្នាំ) | | 5.0 | 5.0 | 5.0 | 5.0 |
| ទំហំគ្រួសារ (នាក់) | | 4.0 | 5.0 | 4.0 | 5.0 |
| អត្រាអក្ខរកម្មខ្មែរ (%) | | 77.8 | 66.0 | 74.4 | 67.4 |
| ស្ថានភាពអាពាហ៍ពិពាហ៍ (%): | រៀបការ | 77.8 | 83.0 | 76.7 | 83.7 |
| | លែងលះ | 2.2 | 2.1 | 2.3 | 2.3 |
| | មេម៉ាយ/ពោះម៉ាយ | 20.0 | 14.9 | 20.9 | 14.0 |
| ប្រភពចំណូលគ្រួសារ (%): | សកម្មភាពកសិកម្ម | 77.8 | 91.5 | 65.1 | 60.5 |
| | សកម្មភាពអាជីវកម្ម | 8.9 | 0.0 | 9.3 | 7.0 |
| | ផ្សេងៗ | 13.3 | 8.5 | 25.6 | 32.6 |
| ស្ថានភាពផ្ទះសម្បែង (%): | ផ្ទះស្លឹក | 4.4 | 8.5 | 0.0 | 4.7 |
| | ផ្ទះឈើប្រក់ក្បឿង | 40.0 | 38.3 | 44.2 | 23.3 |
| | ផ្ទះឈើប្រក់ស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍ | 51.1 | 53.2 | 53.5 | 72.1 |
| | ផ្ទះបេតុង / ឥដ្ឋ | 4.4 | 0.0 | 2.3 | 0.0 |
| ទឹកផឹក (%): | ស្នប់/អណ្តូងខួង | 8.9 | 10.6 | 23.3 | 30.2 |
| | អណ្តូងជីក | 20.0 | 34.0 | 20.9 | 32.6 |
| | ស្រះ/អូរ | 64.4 | 53.2 | 41.9 | 30.2 |
| | ទឹកភ្លៀង | 6.7 | 2.1 | 14.0 | 7.0 |
| ឥន្ធនៈចម្អិនអាហារ (%): | អុសប្រមូលបាន | 91.1 | 93.62 | 83.7 | 95.4 |
| | អុសទិញ | 2.2 | 4.26 | 4.7 | 2.3 |
| | ឧស្ម័ន | 6.7 | 2.13 | 9.3 | 2.3 |
| | ផ្សេងៗ | 0.0 | 0.0 | 2.3 | 0.0 |
| ចម្ងាយពីផ្ទះទៅផ្សារ (គ.ម) | | 1.3 | 1.0 | 1.3 | 1.0 |
| ទ្រព្យសម្បត្តិគ្រួសារ (ម៉ឺនរៀល, ចារឹក) | | 842.6 | 645.9 | 978.9 | 757.9 |

ប្រភព: ការគណនារបស់អ្នកនិពន្ធ

ជាមេគ្រួសារមានច្រើនជាងគេក្នុងក្រុមទាំងពីរ។ ក្នុងអង្កេតគោល និងអង្កេតតាមដានបន្ត ភាគរយគ្រួសារមានស្ត្រីជាមេគ្រួក្នុងក្រុមរងប្រព្រឹត្តិកម្ម (សមាជិក FO) មានចំនួនច្រើនជាងក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។

បើគិតពីចំនួនឆ្នាំសិក្សារបស់មេគ្រួសារវិញ គ្មានការខុសគ្នាទេរវាងក្រុមរងប្រព្រឹត្តិកម្ម នឹងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល ពោលគឺ ពួកគេបានទទួលការអប់រំត្រឹមកម្រិតបឋមសិក្សាចំនួនប្រាំឆ្នាំដូចគ្នា។ គេឃើញមានការខុសគ្នាតិចតួច ក្នុងទំហំគ្រួសារនៃក្រុមរងប្រព្រឹត្តិកម្ម (៤នាក់) និងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល (៥នាក់)។ ហើយតួលេខខុសគ្នានេះនៅដដែល ក្នុងពេលធ្វើការសិក្សាគោល និងការសិក្សាតាមដានបន្ត។ កម្រិតអក្ខរកម្មខ្មែរ (សមត្ថភាពអានអត្ថបទខ្មែរ) ខុសគ្នាបន្តិចរវាងឆ្នាំ២០១១ នឹង ២០១៣៖ នៅឆ្នាំ២០១១ មាន ៧៧,៨% សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម និង ៦៦%សម្រាប់ក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល រីឯនៅឆ្នាំ២០១៣ មាន ៧៤,៤%សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម និង ៦៧,៤% សម្រាប់ក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ មេគ្រួសារច្រើនជាង ៧៦,៧% ទាំងនៅឆ្នាំ២០១១ និងឆ្នាំ២០១៣ បានបញ្ជាក់ថាពួកគេមានប្រពន្ធ/ប្តី។ លទ្ធផលបង្ហាញទៀតថា មានអត្រាស្ត្រីមេម៉ាយ/បុរសពោះម៉ាយខ្ពស់ ក្នុងចំណោមអ្នកចូលរួម គឺមាន មេគ្រួសារ ២០% ក្នុងក្រុមរងប្រព្រឹត្តិកម្ម និង ១៤% ក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។

តួនាទីកសិកម្មជាប្រភពប្រាក់ចំណូលរបស់គ្រួសារ បានប្រែប្រួលខ្លះៗក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល ពី ៧៧,៨% នៅឆ្នាំ២០១១ ដល់ ៦៥,១% នៅឆ្នាំ២០១៣ រីឯក្នុងក្រុមរងប្រព្រឹត្តិកម្ម វាបានថយចុះប្រហែលមួយភាគបី ពី ៩១,៥% នៅឆ្នាំ២០១១ ដល់ ៦០,៥% នៅឆ្នាំ២០១៣។ តួលេខនេះបង្ហាញថា កសិករបាននិងកំពុងគិតគូរធ្វើសកម្មភាពអាជីវកម្មផ្សេងទៀតក្រៅពីការធ្វើកសិកម្ម។ លទ្ធផលអង្កេតពីស្ថានភាពផ្ទះសម្បែង បង្ហាញថា ភាគរយគ្រួសាររងប្រព្រឹត្តិកម្មដែលរស់នៅក្នុងផ្ទះឈើប្រក់ក្បឿង ឬប្រក់ស័ង្កសី ឬហ្វីប្រូស៊ីម៉ង់ត៍ បានកើនឡើងបន្តិច

រវាងអង្កេតគោល នឹងអង្កេតតាមដានបន្ត។ ផ្ទុយទៅវិញ តួលេខលើក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល បានបង្ហាញនូវការប្រែប្រួលថយចុះគុណភាពផ្ទះសម្បែង ដោយ ផ្ទះឈើប្រក់ក្បឿងបានថយចុះ ១៥% ហើយផ្ទះឈើប្រក់ស័ង្កសីបានកើនឡើង ១៩% រវាងអង្កេតគោល នឹងអង្កេតតាមដានបន្ត។ ចំពោះបញ្ហាទឹកផឹក ក្នុងអង្កេតគោល ភាគរយគ្រួសារប្រើទឹកស្រះ/អូរ មានកម្រិតខ្ពស់ដល់ ៦៤,៤% ក្នុងក្រុមរងប្រព្រឹត្តិកម្ម និង ៥៣,២%ក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ ប៉ុន្តែក្នុងអង្កេតតាមដានបន្តនៅឆ្នាំ២០១៣ តួលេខនេះបានថយចុះគួរឱ្យកត់សម្គាល់ ដល់ ៤១,៩% និង ៣០,២% រៀងគ្នា។ ក្នុងពេលជាមួយគ្នា ការប្រើប្រាស់ទឹកភ្លៀងក្នុងក្រុមរងប្រព្រឹត្តិកម្មបានកើនឡើងស្ទើរមួយជាពីរ ដល់ ១៤,០% រីឯក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល វាបានកើនលើសពីមួយជាបី គឺរហូតដល់ ៧,០%។ ការប្រើស្នប់/អណ្តូងខួង បានកើនឡើងច្រើន ប្រហែល ២,៥ដង (២៣,៣%) ក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល និងកើនស្ទើរបីដង (៣០,២%) សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម។ អុសប្រមូលបាន ជាប្រភពឥន្ធនៈដ៏សំខាន់សម្រាប់ចម្អិនអាហារ (ពី ៨៣% ទៅ ៩៥%) ទោះបីវាបានថយចុះអស់ ៧% ក្នុងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល នៅពេលធ្វើអង្កេតតាមដានបន្តក្តី។

ចម្ងាយពីផ្ទះទៅផ្សារធំ វាខុសគ្នាតិចតួចទេរវាងក្រុមរងប្រព្រឹត្តិកម្ម នឹងក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល និងគ្មានប្រែប្រួលទេ រវាងអង្កេតគោល នឹងអង្កេតតាមដានបន្ត ពោលគឺ ១,៣គ.ម សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម និង ១គ.ម សម្រាប់ក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ ទ្រព្យសម្បត្តិគ្រួសារកើនពី ៨៤២,៦ម៉ឺនរៀល ដល់ ៩៧៨,៩ម៉ឺនរៀល សម្រាប់ក្រុមរងប្រព្រឹត្តិកម្ម និងពី ៦៤៥,៩ម៉ឺនរៀល ដល់ ៧៥៧,៩ម៉ឺនរៀល សម្រាប់ក្រុមសម្រាប់ផ្ទៀងផ្ទាត់មើល។ ប៉ុន្តែកំណើននេះមិនមានឥទ្ធិពលខ្លាំង ទៅលើជីវភាពរស់នៅរបស់គ្រួសារទាំងនោះទេ ដោយសារ T-តេស្ត (ការពិនិត្យស្ថិតិ) មានបង្ហាញលទ្ធផលមិនសំខាន់។

លទ្ធផលនៃការប៉ាន់ស្មានតាម DiD មានបង្ហាញក្នុង តារាង ៤។ លទ្ធផលនេះបានពីអថេរសម្រាប់ផ្ទៀងផ្ទាត់មើល ដូចមានចុះក្នុងតារាង ៥ ក្នុងឧបសម្ព័ន្ធនេះ។ ការគណនា DiD ជាផលបូកដកបានពីអថេរនៃស្រូវអង្ករទាំងអស់ - ទិន្នផល ការប្រើប្រាស់ ការលក់ ប្រាក់ចំណូលសរុប និងប្រាក់ចំណេញសុទ្ធ។ ទោះយ៉ាងនេះក្តី ស្ថិតិ T-តេស្ត បង្ហាញថា គ្មានអថេរលទ្ធផលណាមួយមានសារៈសំខាន់ខាងស្ថិតិទេ ដែលមានន័យថា FOs មិនមានផលប៉ះពាល់វិជ្ជមានគួរឲ្យកត់សំគាល់ទៅលើ ផលិតភាពស្រូវរបស់សមាជិក FO នោះទេ។

លទ្ធផលរបស់គ្រួសារចិញ្ចឹមមាន់(៩២គ្រួសារក្នុងអង្កេតគោល និង ៧៨គ្រួសារក្នុងអង្កេតតាមដានបន្ត) បង្ហាញភាពខុសគ្នាអវិជ្ជមានសម្រាប់អថេរ ចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ ការលក់ និងការលក់ក្នុងមនុស្សម្នាក់ ដូចមានបង្ហាញក្នុងជួរឈរ DiD។ តួលេខនេះបញ្ជាក់ថា លទ្ធផលក្នុងអង្កេតតាមដានបន្ត វាទាបជាងលទ្ធផលក្នុងអង្កេតគោល។ លទ្ធផល T-តេស្ត (តម្លៃ P - ប្រូបាប៊ីលីតេដែល លទ្ធផលនៃការសិក្សានេះវាកើតមានឡើង

តារាង ៤: លទ្ធផល Difference-in-Differences (kernel-based propensity score applied)

| អថេរលទ្ធផល | អង្កេតគោល (2011) | | | អង្កេតតាមដានបន្ត (2013) | | | DiD | តម្លៃ-p |
|---|---|---|---|---|---|---|---|---|
| | ផ្ទៀងផ្ទាត់មើល | រងប្រព្រឹត្តិកម្ម | ភាពខុសគ្នា | ផ្ទៀងផ្ទាត់មើល | រងប្រព្រឹត្តិកម្ម | ភាពខុសគ្នា | | |
| **ស្រូវ:** | | | | | | | | |
| ទិន្នផល (គ.ក/ហិកតា) | 1978.4 | 2401.6 | 423.2 | 1891.3 | 1996.8 | 105.4 | -317.8 | (0.46) |
| ចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ (គ.ក) | 1090.5 | 1401.2 | 310.7 | 757.5 | 1016.3 | 258.8 | -51.9 | (0.82) |
| ការលក់ /ហិកតា (គ.ក) | 311.1 | 499.4 | 188.3 | 387.1 | 546.3 | 159.1 | -29.1 | (0.94) |
| ប្រាក់ចំណូលសរុប (ម៉ឺនរៀល) | 31.0 | 50.6 | 19.6 | 31.1 | 35.6 | 4.5 | -15.1 | (0.59) |
| ប្រាក់ចំណេញសុទ្ធ/ហិកតា(ម៉ឺនរៀល) | 117.2 | 200.3 | 83.1 | 119.4 | 129.0 | 9.6 | -73.5 | (0.13) |
| **មាន់:** | | | | | | | | |
| ផលិតកម្មក្នុងមនុស្សម្នាក់ (គ.ក) | 4.7 | 11.5 | 6.8 | 3.0 | 12.4 | 9.3 | 2.6 | (0.55) |
| ចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ (គ.ក) | 1.6 | 3.6 | 2.0 | 0.8 | 2.0 | 1.2 | -0.8 | (0.50) |
| ការលក់ (គ.ក) | 1.4 | 4.2 | 2.8 | 0.6 | 2.4 | 1.9 | -0.9 | (0.56) |
| ការលក់ក្នុងមនុស្សម្នាក់ (ម៉ឺនរៀល) | 1.7 | 5.5 | 3.8 | 0.9 | 3.6 | 2.7 | -1.1 | (0.62) |
| **ជ្រូក:** | | | | | | | | |
| ផលិតកម្មក្នុងមនុស្សម្នាក់ (គ.ក) | 22.7 | 31.8 | 9.2 | 9.0 | 27.6 | 18.7 | 9.5 | (0.58) |
| ចំណាយប្រើប្រាស់/១ក្បាល (គ.ក) | 0.0 | 1.1 | 1.1 | 0.0 | 0.4 | 0.4 | -0.7 | (0.64) |
| ការលក់ (គ.ក) | 14.4 | 18.4 | 4.0 | 5.8 | 22.7 | 16.9 | 12.9 | (0.36) |
| ការលក់ក្នុងមនុស្សម្នាក់ (ម៉ឺនរៀល) | 13.9 | 16.9 | 3.0 | 5.1 | 23.9 | 18.8 | 15.8 | (0.40) |

ប្រភព: ការគណនារបស់អ្នកនិពន្ធ

ដោយចៃដន្យ) បង្ហាញថា ភាពខុសគ្នានេះមិនមានសារៈសំខាន់ខាងស្ថិតិទេ។ តាមលទ្ធផលស្ថិតិ T-តេស្ត យើងអាចដឹងថាការចូលរួម FOs មិនមានឥទ្ធិពលលើផលិតភាពចិញ្ចឹមមាន់របស់កសិករទេ។

សម្រាប់ការចិញ្ចឹមជ្រូក គឺមាន ៧៧គ្រួសារក្នុងអង្កេតគោល និង ៥៥គ្រួសារក្នុងអង្កេតតាមដានបន្ត។ លទ្ធផលក្នុងជួរឈរ DiD មានតួលេខអវិជ្ជមានសម្រាប់ចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ ប៉ុន្តែមានតួលេខវិជ្ជមានសម្រាប់ ការលក់ ផលិតកម្មក្នុងមនុស្សម្នាក់ និងការលក់ក្នុងមនុស្សម្នាក់។ ទោះយ៉ាងនេះក្ដី សម្រាប់អថេរទាំងអស់តួលេខមិនមានសារៈសំខាន់ខាងស្ថិតិទេ។ ដូច្នេះយើងអាចសន្និដ្ឋានថា ការចូលរួមក្នុង FOs មិនមានឥទ្ធិពលអ្វីលើផលិតភាពការចញ្ចឹមជ្រូករបស់កសិករក្នុងអង្កេតទេ។

## សេចក្ដីសន្និដ្ឋាន

លទ្ធផលការសិក្សាគោលរបស់CDRIនៅឆ្នាំ២០១១បង្ហាញថាការចូលរួមក្នុង FO មានផលប៉ះពាល់វិជ្ជមានលើសន្តិសុខស្បៀងគ្រួសារនៅតាមជនបទ ឆ្លងតាមការល្អប្រសើរឡើងក្នុងផលិតភាពស្រូវនិង ផលិតកម្មសត្វចិញ្ចឹម។ ការសិក្សានេះផ្អែកលើអង្កេតធ្វើឡើងនៅចំណុចមួយនៃពេលវេលា។ ប៉ុន្តែតាមការប្រើទិន្នន័យតាមពេលបន្តបន្ទាប់បានពី អង្កេតតាមដានបន្ត និងផ្ដោតលើខេត្តកំពតតែមួយខេត្ត យើងបានរកឃើញថា ការចូលរួមក្នុង FOs មិនមានផលប៉ះពាល់ទៅលើផលិតកម្មស្រូវនិងផលិតភាពសត្វចិញ្ចឹមទេ។ ការសិក្សានេះ ផ្ដល់ការសន្និដ្ឋានថា FOs មិនមានឥទ្ធិពលខ្លាំងលើផលិតភាពស្រូវ និងសត្វចិញ្ចឹមរបស់គ្រួសារនៅជនបទ ក្នុងខេត្តកំពតទេ។ ដោយសារសំណាកមានទំហំតូច ដូច្នេះលទ្ធផលទាំងនេះគួរសិក្សាស្រាវជ្រាវបន្ថែមទៀត។

## ឯកសារយោង:


Abaru, M.B., A. Nyakuni and G. Shone (2006), *Strengthening Farmers Organisations: RELMA's Experience in Eastern and Southern Africa*, ICRAF Working Paper No. 23 (Nairobi: World Agroforestry Centre)

Bachke, M.E. (2010), *Do Farmers' Organizations Enhance the Welfare of Small-Scale Farmers?* Working Paper (As, Norway: Norwegian University of Life Sciences)

Barham, J. and C. Chitemi (2007), *Collective Action Initiatives to Improve Marketing Performance*: Lessons from Farmer Groups in Tanzania, CAPRi Working Paper No. 74 (Washington, DC: IFPRI)

Bingen, J., A. Serrano and J. Howard (2003), "Linking Farmer to Market: Different Approaches to Human Capital Development", *Food Policy,* 28, pp. 405-419

CDRI, Cambodia Development Resource Institute (2012), " Impact Assessment of Farmer Organisations on Food Security for the Rural Poor", unpublished report (Phnom Penh: CDRI)

Couturier, J., S.O. Savun and P. Ham (2006), "Inventory of Farmer Organisations in Cambodia", draft prepared for Office of Farmer Organisation,Department of Agricultural Extension, Ministry of Agriculture, Forestry and Fisheries, Phnom Penh

Chea S. (2010), "Final Report on Policy Analysis for Farmer Organisation Development, Department of Agricultural Extension" (Phnom Penh: MAFF, sponsored by IFAD and FAO)

Chirwa, E., A. Dorward, R. Kachule, I. Kumwenda, J. Kydd, N. Poole, C. Poulton and M. Stockbridge (2005), "Walking Tightropes: Supporting Farmer Organisations for Market Access", *Natural Resource Perspective* (London: Overseas Development Institute)

Keo S. (2013), "Gender Inequality in Agriculture: A Household Survey of Farmer Organisations in Four Provinces", *Cambodia Development Review*, Vol. 17 (Phnom Penh: CDRI) pp. 13-18

Khandker, Shahidure R., Gayatri B. Koolwal and Hussain A. Samad (2010), *Handbook on Impact Evaluation: Quantitative Methods and Practices* (Washington, DC: World Bank)Ngin C. (2010)," Farmers' Associations in Cambodia: Internal Functions and External Relations", RCSD Research Report (Chiang Mai: Regional Center for Social Science and Sustainable Development)

Nou Keosothea (2006), "Emerging Structure of Agricultural Cooperative in Cambodia", *Cambodia Development Review* (Phnom Penh: CDRI)

Peacock, C., A. Jowett, A. Dorward, C. Poulton and I. Urey (2004), "Reaching the Poor: A Call to Action – Investment in Small Agriculture in Sub-Saharan Africa", unpublished report for FARMAfrica (London: Imperial College)

Schlotter, M., G. Schwerdt and L. Woessmann (2011), "Econometric Methods for Causal Evaluation of Education Policies and Practices: A Non-technical Guide" *Education Economics*, 19(2), 109-137

Theng V., Nou K., Keo S., Sum S. and Khiev P. (2011)," Farmer Organisations in Cambodia: Do they Improve Food Security of the Rural Poor?" *Cambodia Development Review*, Vol. 15 (Phnom Penh: CDRI) pp. 13-17

World Bank (2005), *Cambodia Rural Sector Strategy Note: Towards a Strategy for Rural Growth and Poverty Reduction* (Washington, DC: World Bank)

World Bank (2009a), *Poverty Profile and Trend in Cambodia: Findings from the 2007 CSES* (Phnom Penh: World Bank)

## ឧបសម្ព័ន្ធ

តារាង៥. បញ្ជីអថេរសម្រាប់ផ្ទៀងផ្ទាត់មើល (covariates) ក្នុងការប៉ាន់ស្មាន Difference-in-Differences

| អថេរ | ការពិពណ៌នា | 2011 | | | 2013 | | |
|---|---|---|---|---|---|---|---|
| | | ចំនួន (Obs) | មធ្យម (Mean) | គម្លាតស្តង់ដា | ចំនួន (Obs) | មធ្យម (Mean) | គម្លាតស្តង់ដា |
| q1_31 | សកម្មភាពកសិកម្ម (dummy គឺ មាន=១, អត់=0)) | 92 | 0.85 | 0.36 | 86 | 0.63 | 0.49 |
| q1_32 | សកម្មភាពអាជីវកម្ម (dummy) | 92 | 0.04 | 0.21 | 86 | 0.08 | 0.28 |
| q2_1_22 | ផ្ទះឈើប្រក់ក្បឿង (dummy) | 92 | 0.39 | 0.49 | 86 | 0.34 | 0.48 |
| q2_1_23 | ផ្ទះឈើប្រក់ស័ង្កសី/ហ្វីប្រូស៊ីម៉ងត៍ (dummy) | 92 | 0.52 | 0.50 | 86 | 0.63 | 0.49 |
| q2_1_24 | ផ្ទះបេតុង / ឥដ្ឋ (dummy) | 92 | 0.02 | 0.15 | 86 | 0.01 | 0.11 |
| q2_1_42 | អណ្ដូងជីក (dummy) | 92 | 0.27 | 0.45 | 86 | 0.27 | 0.45 |
| q2_1_43 | ស្រះ/អូរ (dummy) | 92 | 0.59 | 0.50 | 86 | 0.36 | 0.48 |
| q2_1_44 | ទឹកភ្លៀង (dummy) | 92 | 0.04 | 0.21 | 86 | 0.10 | 0.31 |
| q2_1_51 | អុសប្រមូលបាន (dummy) | 92 | 0.92 | 0.27 | 86 | 0.90 | 0.31 |
| q2_1_53 | ឧស្ម័ន (dummy) | 92 | 0.04 | 0.21 | 86 | 0.06 | 0.24 |
| q2_1_61 | អគ្គិសនីក្រុង (dummy) | 92 | 0.00 | 0.00 | 86 | 0.07 | 0.26 |
| q2_1_62 | ម៉ាស៊ីនភ្លើង (dummy) | 92 | 0.02 | 0.15 | 86 | 0.00 | 0.00 |
| q2_1_63 | ប្រេងកាត/ប្រេងសាំង (dummy) | 92 | 0.33 | 0.47 | 86 | 0.10 | 0.31 |
| q2_1_64 | ទៀន (dummy) | 92 | 0.01 | 0.10 | 86 | 0.01 | 0.11 |
| q2_1_65 | អាគុយ/ពិល (dummy) | 92 | 0.62 | 0.49 | 86 | 0.74 | 0.44 |
| q2_1_67 | (សូមបញ្ជាក់) (dummy) | 92 | 0.02 | 0.15 | 86 | 0.01 | 0.11 |
| q2_1_71 | បង្គន់ខ្លួនឯង (dummy) | 92 | 0.18 | 0.39 | 86 | 0.22 | 0.42 |
| q1_2_31 | ភេទ (បុរស=1) | 92 | 0.77 | 0.42 | 86 | 0.77 | 0.42 |
| q1_2_61 | អក្ខរកម្ម (មាន=1) | 92 | 0.72 | 0.45 | 86 | 0.71 | 0.46 |
| q1_2_71 | មានប្ដី/ប្រពន្ធ (dummy) | 92 | 0.80 | 0.40 | 86 | 0.80 | 0.40 |
| q1_2_73 | មេម៉ាយ/ពោះម៉ាយ (dummy) | 92 | 0.17 | 0.38 | 86 | 0.17 | 0.38 |
| q1_2_92 | ការងារកសិកម្ម (លក់កម្លាំងពលកម្មក្នុងភូមិ) (dummy) | 92 | 0.01 | 0.10 | 86 | 0.01 | 0.11 |
| q1_2_93 | ធ្វើការក្រៅភូមិក្នុងប្រទេស (dummy) | 92 | 0.04 | 0.21 | 86 | 0.05 | 0.21 |
| q1_2_94 | ចំណាកស្រុកទៅធ្វើការនៅទល់ដែន (dummy) | 92 | 0.01 | 0.10 | 86 | 0.01 | 0.11 |
| q1_2_95 | ធ្វើការនៅប្រទេសដទៃ (dummy) | 92 | 0.02 | 0.15 | 86 | 0.02 | 0.15 |
| q1_2_96 | មន្ត្រីរាជការ/បុគ្គលិក NGOs/បុគ្គលិកក្រុមហ៊ុន (dummy) | 92 | 0.07 | 0.25 | 86 | 0.07 | 0.26 |
| q1_2_97 | អាជីវកម្មខ្នាតតូច/ អាជីវកម្មខ្នាតតូចរួមគ្នា (dummy) | 92 | 0.26 | 0.44 | 86 | 0.28 | 0.45 |
| q1_2_98 | ធនធានប្រមូលបានពីទឹក ឬ ដី(dummy) | 92 | 0.05 | 0.23 | 86 | 0.05 | 0.21 |
| q1_2_99 | ធ្វើការសំណង់ (dummy) | 92 | 0.16 | 0.37 | 86 | 0.14 | 0.35 |
| q1_2_910 | ចងការប្រាក់ (dummy) | 92 | 0.02 | 0.15 | 86 | 0.02 | 0.15 |
| q1_2_911 | សិប្បកម្ម (dummy) | 92 | 0.02 | 0.15 | 86 | 0.02 | 0.15 |
| q1_2_912 | លក់កម្លាំងពលកម្មក្នុងភូមិ(សកម្មភាពមិនមែនកសិកម្ម) (dummy) | 92 | 0.01 | 0.10 | 86 | 0.01 | 0.11 |
| q1_2_4 | អាយុមេគ្រួសារ | 92 | 46.64 | 13.13 | 86 | 47.29 | 13.19 |
| q1_2_8 | កម្រិតអប់រំ (ចំនួនឆ្នាំសិក្សា) របស់មេគ្រួសារ | 92 | 5.23 | 3.72 | 86 | 5.26 | 3.80 |

ប្រភព: ការគណនារបស់អ្នកនិពន្ធ

# ទំនាក់ទំនងរវាងការងារ នឹងភាពក្រីក្រ នៅប្រទេសកម្ពុជា[១]

## សេចក្ដីផ្ដើម

នៅកម្ពុជា គេឃើញមានភាពខុសគ្នាជាខ្លាំង រវាងកំណើនភាពក្រីក្រ នឹងកំណើន ផសស។ ប្រជាជនក្រីក្រពឹងផ្អែកភាគច្រើនលើកម្លាំងពលកម្ម ដើម្បីរកប្រាក់ចំណូល ហើយដោយសាររចនាសម្ព័ន្ធតាមវិស័យនៃទីផ្សារពលកម្ម ពលករក្រីក្រក៏ស្ថិតក្នុងស្ថានភាពចាញ់ប្រៀប។ កន្លងមកពួកគេទទួលបានតែមួយភាគតូចនៃអត្ថប្រយោជន៍សរុបបានពីកំណើន ដោយសារបាតុភូតនៃការជ្រាបចុះខ្លះៗរបស់វា។ ទោះបីជនក្រីក្រមួយភាគធំមានការងារធ្វើក្ដី ប៉ុន្ដែពួកគេស្ថិតក្នុងសេដ្ឋកិច្ចក្រៅផ្លូវការ ដូច្នេះតែងពុំមានប្រាក់ចំណូលគ្រប់គ្រាន់ ឬក៏សុវត្ថិភាពការងារទេ (Bell and Newitt 2010)។ វិស័យកសិកម្មនៅតែចម្បងគេបើគិតពីសមត្ថភាពស្រូបយកយកកម្លាំងពលកម្ម (៦៩% នៃកម្លាំងពលកម្មសរុប) ប៉ុន្ដែបើពិនិត្យតាមអត្រាកំណើនត្រឹម ៤,៨% ក្នុងអំឡុងពេលពីឆ្នាំ ២០០០ ដល់ ២០១១ កសិកម្មមានការលូតលាស់យឺតជាងវិស័យឯទៀត។ វិស័យឧស្សាហកម្មបានរីកចម្រើនយ៉ាងលឿន ប៉ុន្ដែស្រូបយកបានត្រឹម ៩,១% នៃកម្លាំងពលកម្មសរុបប៉ុណ្ណោះ។ ដូច្នេះរចនាសម្ព័ន្ធការងារនៅកម្ពុជា មិនមានការផ្លាស់ប្ដូរខ្លាំងទេ។ កម្លាំងពលកម្មនៅតាមជនបទភាគច្រើន រកបានការងារក្នុងសកម្មភាពផ្សេងៗ ដែលមានផលិតភាពទាប ហើយជាច្រើននាក់គ្មានការងារធ្វើ ឬមានការងារធ្វើមិនពេញលេញ។ អ្នកបម្រើការងារមានប្រាក់ឈ្នួលទាប មានឱកាសតិចតួចណាស់នឹងបានចាកផុតពីភាពក្រីក្រឬធ្វើវិនិយោគដើម្បីពង្រីកឱកាសការងារឬបើកអាជីវកម្មផ្ទាល់ខ្លួន។ ជាលទ្ធផល ក្នុងឆ្នាំ២០១១ ភាពក្រីក្រនៅមានកម្រិតខ្ពស់រហូតដល់ ១៩,៨% (MOP 2012)។

អត្ថបទនេះ[២] ព្យាយាមពិនិត្យស្រាវជ្រាវពីចំណងទាក់ទងរវាងរចនាសម្ព័ន្ធទីផ្សារពលកម្មនិងការងារ ហើយនិងស្ថានភាពក្រីក្រនៅកម្ពុជា។ អ្នកនិពន្ធបានប្រើ ការវិភាគបែបពណ៌នានៃលទ្ធភាពកើនការងារទៅតាមកំណើន សេដ្ឋកិច្ច(Employment elasticity of growth) ផលិតភាពកម្លាំងពលកម្ម និងកំណើនប្រាក់ឈ្នួលពិត ដើម្បីបង្ហាញពីរចនាសម្ព័ន្ធ និងនិន្នាការនៃទីផ្សារពលកម្ម, និងបានប្រើ ការប៉ាន់ស្មាន Probit ដើម្បីបង្ហាញពីចំណងទាក់ទងរវាងការងារក្នុងវិស័យកសិកម្មនិងឧស្សាហកម្ម ហើយនិងវត្តមានភាពក្រីក្រ។

## វិធីសាស្ត្រ

ម៉ូដែល Probit[៣] បានយកចេញមកពីការសិក្សារបស់ Jemio and Choque (2003), Huong *et al.* (2003) និង Krongkaew *et al.* (2006) ដើម្បីពិនិត្យពីទំហំឥទ្ធិពលការងារទៅលើភាពក្រីក្ររបស់គ្រួសារ។ សមីការនៃម៉ូដែលនេះ អាចសរសេរជា:

$$Y = \alpha + \beta E + \sum \pi X + \varepsilon$$

ដែលក្នុងនេះ y គឺ ប្រូបាប៊ីលីតេក្លាយជាអ្នកក្រីក្រ, E តំណាងឲ្យស្ថានភាពការងារគ្រួសារ (ដែលស្មើនឹង ១ ប្រសិនបើមេគ្រួសារមានការងារធ្វើក្នុងវិស័យកសិកម្ម និងស្មើ 0 បើគាត់មានការងារធ្វើក្នុងវិស័យឧស្សាហកម្ម), និង X តំណាងឲ្យជាអាទិ៍ លក្ខណៈនៃមេគ្រួសារ (អាយុ ការអប់រំ ភេទ និងការងារមានប្រាក់ឈ្នួល), តំបន់, ទំហំគ្រួសារ សមាជិកគ្រួសារក្នុងក្រុមអាយុខុសៗគ្នា, ចំនួនម៉ោងធ្វើការជាមធ្យមក្នុងមួយថ្ងៃ, ចំណូលក្នុងកសិដ្ឋាន និងក្រៅកសិដ្ឋាន និងទំហំដី។

របាយការណ៍នេះប្រើប្រាស់ទិន្នន័យម៉ាក្រូ និងមីក្រូចម្រុះគ្នាសម្រាប់ការវិភាគបែបពិពណ៌នា រីឯទិន្នន័យគ្រួសារបានពី អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (CSES) បានយកមកប្រើប្រាស់ក្នុងការធ្វើម៉ូដែល Probit។

## ស្ថានភាពការងារ

សម្រាប់ការស្រាវជ្រាវនេះ ភាពមានការងារធ្វើត្រូវបានកំណត់ជា ការងារមានរយៈពេលយ៉ាងហោចណាស់ មួយម៉ោងក្នុងមួយសប្ដាហ៍ (NIS 2011) ទោះក្នុងមុខងារអ្វីក៏ដោយ។ ជាមធ្យមក្នុងរយៈពេល ១០ឆ្នាំ មកដល់ឆ្នាំ២០១១ មាន ៨៣% នៃកម្លាំងពលកម្មសរុបនៅកម្ពុជាបានចូលរួមក្នុងការងារ គឺស្មើនឹង ៥៤% នៃប្រជាជនសរុប។ ៦០% នៃពលករទាំងនេះធ្វើការក្នុងវិស័យកសិកម្ម, ២៦% ក្នុងសេវាកម្ម និង ១៤% ក្នុងឧស្សាហកម្ម។ ក្នុងចំណោមពលករក្នុងវិស័យឧស្សាហកម្ម មាន ៦២% ធ្វើការក្នុងផ្នែកកម្មន្ដសាល។ កម្លាំងពលកម្មកើនឡើង ៣,៣% ក្នុងមួយឆ្នាំៗ។ ឱកាសការងារជាផ្លូវការថ្មីៗបានកើនឡើងក្នុងអត្រាប៉ុនគ្នានឹងកម្លាំងពលកម្ម ចាប់តាំងពីឆ្នាំ២០០៩ មក ហើយវាកើនឡើងក្នុងអាត្រាខ្ពស់ជាងដល់ ៣,៦% បើសិនគេបូកបញ្ចូលទាំងបណ្ដាឆ្នាំពីមុនឆ្នាំ២០០៩ ផង។ អត្រាបង្កើតការងារ មិនទាន់គ្រប់គ្រាន់ ដើម្បីផ្ដល់ការងារដល់កម្លាំងពលកម្មទាំងមូលនោះទេ។ ទោះយ៉ាងនេះក្ដី អត្រាគ្មានការងារធ្វើជាមធ្យមមានកម្រិតទាបត្រឹម ១,១% ដោយសារការកំណត់និយមន័យធំទូលាយនៃភាពមានការងារធ្វើ ដែលបានយកការងារ ទាំងអស់មកបូកបញ្ចូល សូម្បីការងារដែលគេចាត់ទុកថា "ងាយរងគ្រោះ" ពោលគឺគ្មានស្ថិរភាព ឬគ្មានបទបញ្ញត្តិគ្រប់គ្រង។ ចំនួនស្ត្រីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅមានកម្រិតទាបត្រឹម ៧៨% នៃកម្លាំងពលកម្មស្ត្រីសរុប រីឯអត្រាសម្រាប់បុរសគឺ ៨៦% ។ មូលហេតុមួយនៃស្ថានភាពនេះ គឺស្ត្រីនៅចំណាយពេលច្រើនទៅលើការងារក្នុងផ្ទះ ដែលគេតែងចាត់ទុកជា ភារកិច្ចរបស់ស្ត្រី។

---

[១] រៀបរៀងដោយ ផាន់ ដាលីស ជាអ្នកស្រាវជ្រាវក្នុងកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់។

[២] អត្ថបទនេះផ្អែកលើ លទ្ធផលនៃការសិក្សាមួយ (ចេញផ្សាយក្នុងពេលឆាប់ៗ) ដែលស្ថិតក្នុងគម្រោងស្រាវជ្រាវពីកំណើនសម្រាប់គ្រប់គ្នា ផ្ដល់មូលនិធិដោយ Sida។

[៣] ម៉ូដែល Probit គឺជាប្រូបាប៊ីលីតេដែលអថេរជាផលមួយ (មានតម្លៃតែពីរ: ក្នុងករណីនេះ គឺ គ្រួសារ ធូរធារ ឬក៏ ក្រីក្រ) វាផ្លាស់ប្ដូរ នៅពេលមានការផ្លាស់ប្ដូរក្នុងតម្លៃនៃកត្តាជាដើមហេតុ។

រូបភាព ១៖ ការងារមានប្រាក់ឈ្នួលរបស់បុរស និងស្ត្រី គិតតាមវិស័យ (%)




ប្រភព៖ World Development Indicator

ឱកាសការងារនៅតំបន់ជនបទ មានច្រើនជាងនៅតំបន់ទីក្រុង។ យោងតាម CSES ប្រជាជន មានការងារធ្វើនៅតំបន់ជនបទ តំណាងឲ្យជាមធ្យម ៦៨% នៃកម្លាំងពលកម្មសរុបនៅតាមជនបទក្នុងអំឡុងឆ្នាំ២០០៤ ដល់ ២០១១ ចំណែកឯនៅទីក្រុងមានត្រឹម ៥៧% ។ ក្នុងចំណោមពលករនៅតំបន់ជនបទ មាន ៥៩% ចូលរួមក្នុងវិស័យកសិកម្ម, ៩,៨% ក្នុងកម្មន្តសាល, ៩,៥% ក្នុងពាណិជ្ជកម្ម និងប្រហែល ២១% ក្នុងវិស័យផ្សេងៗទៀត។ ការងារភាគច្រើននៅទីក្រុង ស្ថិតក្នុងវិស័យពាណិជ្ជកម្ម (២៨%), កសិកម្ម (១៦%), កម្មន្តសាល (១១%), រដ្ឋបាលសាធារណៈ និងការពារជាតិ (៨%) និង វិស័យដទៃទៀត (៣៧%)។

## ភាពយឺតការងារ នៃកំណើន

ភាពយឺតការងារ ឬអាំងតង់ស៊ីតេការងារ នៃកំណើន (Employment elasticity or employment intensity of growth) បង្ហាញពី បែបបទដែលការផ្លាស់ប្តូរក្នុងធាតុចេញតាមវិស័យ ធ្វើឲ្យប្រែប្រួលដល់ឱកាសការងារ ពោលគឺ ទំហំដែលឱកាសការងារទទួលរងឥទ្ធិពលពីការផ្លាស់ប្តូរនៃ ផសស តាមវិស័យ និងបញ្ច្រាស់មកវិញ។ ពីឆ្នាំ១៩៩៥ ដល់ ១៩៩៨ ភាពយឺតជារួមគឺខ្ពស់ជាង មួយឯកតា (ការងារ កើនឡើង លឿនជាង ធាតុចេញ ឬ ឱកាសការងារកើនឡើងច្រើនជាង ១០% ប្រសិនបើ ផសស (GDP) កើនឡើង ១០%)។ ក្នុងអំឡុងពេលនោះគេឃើញថា សម្រាប់វិស័យឧស្សាហកម្ម កំណើនការងារមានលក្ខណៈល្អ ប៉ុន្តែ កំណើនផលិតភាពនៅទាប។ វិស័យកសិកម្ម និងសេវាកម្ម ស្រូបយកពលករបានជាច្រើន ហើយពលកម្មក៏មានផលិតភាពខ្ពស់ស្របតាមនោះដែរ (តារាង ១)។

សមីការខាងក្រោមនេះបង្ហាញពី ទំនាក់ទំនងរវាងភាពយឺតការងារនៃធាតុចេញ និងការផ្លាស់ប្តូរក្នុងផលិតភាពការងារ៖

$$\varepsilon_i = \frac{\Delta E}{\Delta Y} = \frac{(E_{it} - E_{i(t-1)})/E_{i(t-1)}}{(Y_{it} - Y_{i(t-1)})/Y_{i(t-1)}}$$

$$\varepsilon_i = 1 - \frac{\Delta P}{\Delta Y}$$

$$\Delta P = (1 - \varepsilon)\Delta Y$$

ដែលក្នុងនោះ ε ជាភាពយឺតការងារនៃធាតុចេញ (Employment elasticity of output), E តំណាងឲ្យការងារ, y តំណាងឲ្យទិន្នផល, i ជាវិស័យ, t ជាពេលវេលា, និង P ជាផលិតភាព។

ចាប់ពីឆ្នាំ២០០៨ ដល់ ២០១១ ភាពយឺតការងារនៃកំណើនធាតុចេញក្នុងវិស័យកសិកម្ម មានលក្ខណៈអវិជ្ជមានខ្លាំងណាស់ ដល់ ៥៥,៨ និង អវិជ្ជមានក្នុងសេវាកម្ម ត្រឹម ៣,៦។ នេះជាលទ្ធផលនៃវិបត្តិហិរញ្ញវត្ថុសកល និងផលអាក្រក់ក្រោយពីនោះ។ តារាង ១ បង្ហាញថា មានតែឧស្សាហកម្មប៉ុណ្ណោះដែលសឹងតែគ្មានរងឥទ្ធិពលអ្វីពីវិបត្តិដោយមានភាពយឺតជាវិជ្ជមានដល់ ២,៤ ។ វិស័យនេះគេចាត់ទុកថា ជំរុញឡើងដោយកម្លាំងពលកម្មជាជាង ជំរុញឡើងដោយផលិតភាព ដូចមានតួលេខនៃភាពយឺតបញ្ជាក់ស្រាប់។ ផ្ទុយទៅវិញ វិស័យកសិកម្ម និងសេវាកម្ម ត្រូវបានជំរុញដោយផលិតភាព ជាជាង ដោយចំនួនប្រជាជនដែលវិស័យទាំងនេះជួលប្រើ។ បុរសមានឱកាសទទួលបានការងារច្រើនជាងស្ត្រី។ យោងតាមនិន្នាការពិនិត្យឃើញពីឆ្នាំ២០០៨ ដល់

តារាង ១៖ ភាពយឺតការងារតាមវិស័យនៃកំណើនធាតុចេញ (Sectoral Employment Elasticity of Output Growth) (ក្នុងអំឡុងពេលជ្រើសរើស)

| | 1995-98 | 1999-2003 | 2004-07 | 2008-11 | 2008-11 (ក្រៅពី 2009) |
|---|---|---|---|---|---|
| កសិកម្ម | 0.78 | 0.44 | 0.09 | -55.76 | 0.34 |
| ឧស្សាហកម្ម | 4.33 | 6.91 | -2.71 | 2.39 | -2.15 |
| សេវាកម្ម | 0.99 | 1.03 | 0.71 | -3.65 | -3.48 |
| សរុប | 1.01 | 0.74 | 0.39 | -0.16 | -0.36 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើ NIS 2011; IMF 2009; World Bank-WDI, 1995-2011

តារាង ២៖ ផលិតភាពពលកម្មតាមវិស័យ (ដុល្លារ/ម៉ោង/ពលករ, គិតតាមឆ្នាំជ្រើសរើស)

| | 1997 | 1998 | 2000 | 2001 | 2004 | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|---|---|---|---|---|
| កសិកម្ម | 0.22 | 0.17 | 0.14 | 0.15 | 0.18 | 0.25 | 0.24 | 0.30 | 0.32 | 0.33 |
| ឧស្សាហកម្ម | 1.19 | 0.94 | 0.75 | 0.53 | 0.61 | 0.62 | 1.36 | 0.68 | 0.70 | 0.75 |
| សេវាកម្ម | 0.82 | 0.40 | 0.64 | 0.49 | 0.43 | 0.46 | 0.94 | 0.64 | 0.57 | 0.65 |
| ជាមធ្យម | 0.37 | 0.26 | 0.28 | 0.27 | 0.32 | 0.39 | 0.50 | 0.48 | 0.48 | 0.51 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើ NIS 2011; IMF 2009; CSES, 2004-2011; World Bank-WDI, 1998-2011

២០១១ បើសិន ផសស កើនឡើង ១០% កំណើនការងារដែលពលករបុរសទំនងទទួលបានគឺ ៧,២% នៃកម្លាំងពលកម្មបុរសសរុប ធៀបនឹង ៦,៥% សម្រាប់ពលករជាស្ត្រី។

## ផលិតភាពពលកម្ម និងកំណើនប្រាក់ឈ្នួលពិត

ពីឆ្នាំ២០០៨ ដល់ ២០១១ ពលកម្មតំណាងឲ្យជាមធ្យម ៦៦% នៃធាតុចូលសម្រាប់វិស័យសេវាកម្ម, ៥៤% នៃធាតុចូលសម្រាប់វិស័យកសិកម្ម, និង ៤៣% នៃធាតុចូលសម្រាប់ឧស្សាហកម្ម។ តួលេខនេះគូសបញ្ជាក់ពី សារៈសំខាន់នៃកំណើនផលិតភាពពលកម្ម ក្នុងលក្ខណៈជាធនធានសេដ្ឋកិច្ចសម្រាប់កំណើនធាតុចេញ ដែលជួយលើកកម្ពស់ភាពប្រកួតប្រជែងរបស់ក្រុមហ៊ុន (Krugman 1994)។

ក្នុងឆ្នាំ២០១១ ការងារកសិកម្មផ្តល់ផល ០.៣៣ដុល្លារក្នុងមួយម៉ោង ឬកើនលើសពីទ្វេដង បើធៀបនឹងឆ្នាំ២០០០ (តារាង ២)។ កំណើននេះទទួលបានជាចម្បងផងដែរមកពី ការផ្លាស់ប្តូរក្នុងធាតុចូល ដូចជា គ្រាប់ពូជល្អជាងមុន និងការប្រើប្រាស់ជីថ្នាំសម្លាប់សត្វចង្រៃ និងគ្រឿងម៉ាស៊ីន។ ផលិតភាពពលកម្មក្នុងសេវាកម្ម គឺ ០,៦៥ដុល្លារក្នុងមួយម៉ោង ឬកើនឡើងបន្តិចបន្តួចធៀបនឹងត្រឹម ០,៦៤ដុល្លារក្នុងឆ្នាំ២០០០។ ផលិតភាពពលកម្មក្នុងវិស័យឧស្សាហកម្មបានខ្ពស់ជាងគេ ដល់ ០,៧៥ដុល្លារក្នុងមួយម៉ោង ប៉ុន្តែពុំបានជំរុញកំណើន ឧស្សាហកម្មនោះទេ ពីព្រោះវាតំណាងឲ្យការប្រើប្រាស់គ្មានប្រសិទ្ធភាពនូវកម្លាំងពលកម្មដែលសមត្ថភាពនៅមានកម្រិតនៅឡើយ។

ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន កម្ពុជាមិនត្រឹមតែត្រូវការឱកាសការងារប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការផងដែរនូវការងារមានប្រាក់ឈ្នួលត្រឹមត្រូវ។ CSES បានរកឃើញថា ប្រាក់ឈ្នួលពិតប្រចាំខែរបស់ពលករក្នុងកសិកម្ម មានជាមធ្យម ២២៨.០៣៦រៀល (៥៦ដុល្លារ) ក្នុងឆ្នាំ២០១១ ក្នុងឧស្សាហកម្មមានជាមធ្យម ៣៧៥.៣៦២រៀល (៩៣ដុល្លារ) និងក្នុងសេវាកម្ម ៥៣៤.៤៦៤រៀល (១៣២ដុល្លារ)។ ប្រាក់ឈ្នួលកើនជាមធ្យម ៤១% ក្នុងវិស័យកសិកម្ម, ១៥% ក្នុងឧស្សាហកម្ម, និង ១១% ក្នុងសេវាកម្ម ក្នុងអំឡុងឆ្នាំ២០០៧ ដល់ ២០១១។ ប្រជាជនរស់នៅក្នុងរាជធានីភ្នំពេញ ពឹងផ្អែកជាខ្លាំងលើ ការងារមានប្រាក់ឈ្នួលដែលតំណាងឲ្យ ៥៧% នៃប្រភពប្រាក់ចំណូលសរុបសម្រាប់គ្រួសារ នៅក្នុងតំបន់នោះ ធៀបនឹងត្រឹម ២៥% សម្រាប់អ្នករស់នៅក្នុងតំបន់ឆ្នេរ។

លទ្ធផលរកឃើញជាក់ស្តែងនៅឆ្នាំ២០០៧ គ្រួសារចូលរួមក្នុងវិស័យកសិកម្មមានឱកាសក្លាយជាអ្នកក្រ ១១% ខ្ពស់ជាងអ្នកចូលរួមក្នុងវិស័យឧស្សាហកម្ម។ ឱកាសក្លាយជាអ្នកក្រនេះបានថយចុះក្នុងឆ្នាំ២០០៩ រហូតនៅត្រឹម ២,៤%។ អត្រាភាពក្រីក្រមិនអាចកំណត់បានដោយផ្អែកលើ ទិន្នន័យសម្រាប់ឆ្នាំ ២០១០ និង ២០១១ នោះទេ។ នៅពេលធ្វើអង្កេត CSES មួយលើកៗ គេអាចមើលឃើញថា បើឆ្នាំសិក្សាអប់រំរបស់មេគ្រួសារកើនឡើងមួយឆ្នាំ ភាពក្រីក្ររបស់គ្រួសារថយចុះអស់ ១,៨%។ ម្យ៉ាងទៀត គ្រួសារដែលមានដីយ៉ាងហោចណាស់ ១,២ហិកតាមិនសូវក្លាយជាអ្នកក្រទេ គឺដូចគ្នានឹង គ្រួសារដែលមានសមាជិកច្រើនក្នុងអាយុពី ១៨ ដល់ ៦៤ឆ្នាំ។ ផ្ទុយទៅវិញ គ្រួសារធំៗ (មានសមាជិក ៤,៧នាក់ ឬលើសពីនេះ និងមានសមាជិកច្រើនមានអាយុក្រោម ១៨ឆ្នាំ) អាចងាយនឹងក្លាយជាអ្នកក្រ។

សេចក្តីសន្និដ្ឋាន ទីផ្សារការងារកម្ពុជានៅមានមូលដ្ឋានតូចចង្អៀត ក្នុងនោះបុរសបានគ្របដណ្តប់លើឱកាសការងារនានា។ ទោះយ៉ាងនេះក្តី ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ចកំពុងកើនឡើងក្នុងគ្រប់វិស័យ។ គេរកឃើញថា វិស័យឧស្សាហកម្មមានកំណើនជំរុញឡើង ដោយកម្លាំងពលកម្ម និងមានផលិតភាពពលកម្មខ្ពស់ជាងក្នុង វិស័យកសិកម្មនិងសេវាកម្មដែលមានកំណើនជំរុញឡើងដោយផលិតភាព។ ពលកម្មក្នុងវិស័យកសិកម្ម និងសេវាកម្ម ងាយទទួលឥទ្ធិពលពីវិបត្តិផ្សេងៗ ដូចបានសង្កេតឃើញក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុ និងផលអាក្រក់តាមក្រោយក្នុងឆ្នាំ២០០៩។ ម្យ៉ាងទៀត អ្នកបម្រើការងារក្នុងវិស័យកសិកម្ម មានប្រូបាបប៊ីលីតេក្លាយជាអ្នកក្រ ខ្ពស់ជាងអ្នកបម្រើការងារក្នុងវិស័យផ្សេងទៀត ហើយកត្តាដែលជួយឲ្យគ្រួសារគេចផុតពីភាពក្រីក្រ មានជាសំខាន់ កម្មសិទ្ធិដីធ្លី និងការអប់រំ។

ដូច្នេះមតិលើកឡើងសម្រាប់គោលនយោបាយម៉ាក្រូ រួមមានការពង្រីកលទ្ធភាពមានដីកសិកម្មប្រើប្រាស់ តាមការចងក្រងឯកសារឲ្យបានត្រឹមត្រូវនិងមានសមធម៌ ការធ្វើផែនទី និងការផ្តល់កម្មសិទ្ធិដីធ្លី។ មធ្យោបាយនេះអាចជួយជំរុញផលិតកម្មដំណាំ និងពង្រីកសកម្មភាពសេដ្ឋកិច្ច ក្នុងការកែច្នៃ ឬលក់រាយ។ សកម្មភាពទាំងនេះជួយបង្កើតការងារក្នុងកសិដ្ឋាន និងនៅក្រៅកសិដ្ឋាន។ ការផ្តល់លទ្ធភាពឲ្យប្រជាជនទទួលបានការអប់រំកាន់តែច្រើនមានសារៈសំខាន់ណាស់ ហើយវិនិយោគសាធារណៈបន្ថែម គួរលៃចែកជាពិសេសសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ ការពង្រីកថវិកា ក៏គួរមានបែងចែកទៅឲ្យកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដូចបានលើកឡើងដោយលោក Tong and Phay (ចេញផ្សាយក្នុងពេលឆាប់ៗ)។

## ឯកសារយោង


Bell, S. and K. Newitt (2010), Decent Work and Poverty Eradication: Literature Review and Two Country Study (London: Ergon Associates)

CSES (2004-2011), Cambodia Socio-Economic Survey (Phnom Penh: Cambodia National Institute of Statistics)

Huong L.P., Tuan Q.B. and Minh H.D. (2003), Employment Poverty Linkages and Policies for Pro-poor Growth in Vietnam (Hanoi: Institute of World Economy)

IMF, International Monetary Fund (2009), Cambodia: Statistical Appendix, IMF Country Report 09/48 (Washington, DC: IMF)

Jemio, C.L and C.M. Choque (2003), Employment-poverty Linkages and Policies: The Case of Bolivia (Geneva: International Labour Office)

Krongkaew, M., S. Chamnivickorn and I. Nitithanprapas (2006), "Economic Growth, Employment and Poverty Reduction Linkages: The Case of Thailand", Issues in Employment and Poverty Discussion Paper 20 (Geneva: ILO)

Krugman, P. (1994), *The Age of Diminished Expectations* (New York: Norton & Company)

MOP, Ministry of Planning (2012), *Annual Progress Report* (Phnom Penh: MOP)

NIS, National Institute of Statistics (2011), *Statistical Yearbook of Cambodia 2011* (Phnom Penh: NIS)

Phann, D. (forthcoming), The *Links between Employment and Poverty: Cambodia*, Working Paper Series (Phnom Penh: CDRI)

Tong K. and Phay S. (forthcoming), "Inclusiveness and Spending on Public Education in Cambodia", *Annual Development Review 2013-14* (Phnom Penh: Cambodia Development Resource Institute)

World Bank (2014), "World Development Indicators", http://data.worldbank.org/data-catalog/-world-development-indicators


# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះរៀបរាប់ពី សូចនាករនៃសេដ្ឋកិច្ចពិភពលោកសំខាន់ៗ និង សេដ្ឋកិច្ចនៅអាស៊ីខាងត្បូង និងខាងកើត។

កំណើនសេដ្ឋកិច្ចនៅអាស៊ី និងប្រទេសឧស្សាហកម្មមួយចំនួន មានស្ថិរភាពឡើងវិញនៅឆ្នាំ២០១២។ ដូច្នេះការងារនៅសល់ត្រូវបន្តដោះស្រាយ គឺការស្តារឡើងវិញនូវទំនុករបស់អ្នកប្រើប្រាស់ និងវិនិយោគិន ឲ្យដល់កម្រិតនៅមុនពេលមានវិបត្តិ និងខ្ពស់ជាងនោះទៀត។ អាស៊ីនៅតែជាកម្លាំងជំរុញកំណើនក្នុងពិភពលោកបន្តទៀត នៅពេលដែលបណ្តាប្រទេសអភិវឌ្ឍន៍ចម្បងៗកំពុងព្យាយាមងើបឡើងវិញ។

នៅឆ្នាំ២០១២ ផសស ពិត នៅឥណ្ឌូនេស៊ី មានកំណើនជាមធ្យម ៦,០% ទោះបីជាមានការធ្លាក់ចុះបន្តិច ក្នុងត្រីមាសទី៤ ឆ្នាំ២០១២ ដល់ ៦,១% ធៀបនឹង កម្រិត ៦,៥% នៅត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ ផសស នៅម៉ាឡេស៊ីកើន ៦,៤% ធៀបនឹងមួយឆ្នាំមុន រីឯ ផសស នៅសិង្ហបុរី ធ្លាក់កំណើនមកត្រឹម ១,៥% ធៀបនឹង ៣,៦% ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ថៃសម្រេចបានកំណើនប្រចាំឆ្នាំខ្ពស់ណាស់ ដល់ទៅ ១៩,៥% នៅត្រីមាសទី៤ ដោយសារចំណាយប្រើប្រាស់ក្នុងស្រុក និងការនាំចេញកើនឡើងយ៉ាងខ្លាំង។ កំណើននៅចិន ថយចុះ ប៉ុន្តែនៅតែខ្ពស់ដល់ ៧,៩% នៅត្រីមាសទី៤ ។ ភាពតានតឹងខាងនយោបាយ និងយោធា រវាងចិន និងជប៉ុន លើបញ្ហាកោះតូចៗមួយចំនួនមិនបានធ្វើឲ្យខូចខាតដល់សេដ្ឋកិច្ចចិនទេ ហើយការតាំងចិត្តរបស់ប្រទេសទាំងពីរក្នុងការដោះស្រាយជម្លោះដោយសន្តិភាព អាចជះឥទ្ធិពលធ្វើឲ្យកំណើនមានស្ថិរភាព។ នៅត្រីមាសទី៤ កំណើន ផសស ប្រចាំឆ្នាំ នៅហុងកុង ធ្លាក់ចុះមកត្រឹម ២,៥% ធៀបនឹងកម្រិត ៣,០% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន រីឯកំណើន ផសស នៅកូរ៉េ គឺ ១,៦%។

កំណើនក្នុងប្រទេសអ្នកមាន ជាពិសេសនៅតំបន់អឺរ៉ូ នៅតែបន្តឡើងចុះ ដោយសារអន្តរាគមន៍សេដ្ឋកិច្ចមិនបានផ្តល់លទ្ធផលគួរជាទីពេញចិត្ត។ នៅត្រីមាសទី៤ សេដ្ឋកិច្ចតំបន់អឺរ៉ូបានធ្លាក់ចុះយ៉ាងខ្លាំង ដោយមានកំណើន ផសស អវិជ្ជមាន (-0,៩%) ដល់ទៅ ៣ត្រីមាសជាបន្តបន្ទាប់ និង កំណើនសូន្យនៅត្រីមាសទី១។ បញ្ហាវិបត្តិធនាគារ បន្តរីករាលដាល ហើយថ្មីៗនេះបានរាលដាលដល់ប្រទេស Cyprus។ កំណើននៅសហរដ្ឋអាមេរិក មានស្ថិរភាពឡើងវិញ ដោយសេដ្ឋកិច្ចមានអត្រាកំណើនប្រចាំឆ្នាំ ១,៦% នៅត្រីមាសទី៤ និងបានបង្កើតការងារជាច្រើនថែមទៀត។ ប៉ុន្តែ អ្នកបង្កើតគោលនយោបាយ និងរដ្ឋាភិបាល នៅតែត្រូវចរចាគ្នាដោះស្រាយឲ្យបាននូវបញ្ហាថវិកាសម្រាប់ឆ្នាំសារពើពន្ធ និងតុល្យភាពថវិកា ដើម្បីរក្សា

[១] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

កំណើនក្នុងរយៈពេលវែង។ ជប៉ុនកំពុងបន្តស្តារ និងកសាងសេដ្ឋកិច្ចឡើងវិញ ប៉ុន្តែកំណើននៅតែបន្តឡើងចុះ។ បញ្ហាបន្ទាន់ៗរួមមាន កំណើនចំណាយរបស់រដ្ឋាភិបាលទៅលើកម្មវិធីសង្គមកិច្ចសម្រាប់មនុស្សចាស់ជរា កម្មវិធីកសាងឡើងវិញសម្រាប់តំបន់រងគ្រោះដោយរលកសមុទ្រយក្សស៊ូណាមី និងជម្លោះដែនដីជាមួយចិន កូរ៉េខាងត្បូង និងរុស្ស៊ី។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

ក្នុងពេញមួយឆ្នាំ២០១២ អត្រាអតិផរណានៅប្រទេសភាគច្រើន ស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។ នៅត្រីមាសទី៤ កំណើនថ្លៃសរុបនៅកម្ពុជាធ្លាក់ចុះដល់ ១,៨% ធៀបនឹងកំណើន ៤,៩% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន។ ប៉ុន្តែថ្លៃប្រេងឥន្ធនៈ និងឧស្ម័ន នៅតែខ្ពស់ដដែល ដែលជះឥទ្ធិពលដល់បន្ទុកចំណាយផលិតកម្មរបស់អាជីវកម្មផ្សេងៗ និងកម្រិតជីវភាពរបស់គ្រួសារនានា។ នៅត្រីមាសទី៤ អតិផរណានៅវៀតណាមធ្លាក់ចុះដល់ ៧,០% ធៀបនឹង អត្រា ១៩,៨% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន។ កំណើនកម្រិតថ្លៃសរុប បណ្តាលជាសំខាន់មកពី ការដាក់អនុវត្តកញ្ចប់លើកទឹកចិត្តរបស់រដ្ឋាភិបាល ដើម្បីសម្រាលការប៉ះទង្គិចពីខាងក្រៅ។ នៅត្រីមាសទី៤ អតិផរណានៅចិន ធ្លាក់ចុះដល់ ២,១% ធៀបនឹង កម្រិត ៤,៦% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន ចំណែកឯនៅហុងកុង វាកើនដល់ ៣,៨%។ នៅត្រីមាសទីបួន ជប៉ុននៅតែបន្តមានបរិត្តផរណា ដែលបានដាក់សម្ពាធបង្កើនអត្រាការប្រាក់ពិត។

នៅត្រីមាសទី៤ ប្រាក់រៀលឡើងថ្លៃ ១,៦% ធៀបនឹងត្រីមាសមុន (១,៩% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារUS និង ០,០៤% (០,៨% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុងវៀតណាម។ ប្រាក់យ៉េនជប៉ុន ធ្លាក់ថ្លៃ ៣,៤% ធៀបនឹងត្រីមាសមុន (៤,៥% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារUS។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៤ ពោត (US No. 2) ធ្លាក់ថ្លៃ ៥,០% (តែឡើងថ្លៃ ១៤,៨% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៣១០,៩ដុល្លារ/តោន សណ្តែកសៀង (US No. 1) ធ្លាក់ថ្លៃ ១១% (ឡើងថ្លៃ ២៧% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៥៧៧,៨ដុល្លារ/តោន ហើយប្រេងម៉ាសូត (low sulphur No. 2) ធ្លាក់ថ្លៃ ១,០% (ឡើងថ្លៃ ៣,៩% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ០,៨០ដុល្លារ/លីត្រ។ នៅត្រីមាសទីបួន កៅស៊ូ (SMR 5) ឡើងថ្លៃ ៥,១% ធៀបនឹងត្រីមាសមុន (ប៉ុន្តែធ្លាក់ថ្លៃ ១៩,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ២៩៤១,៥ដុល្លារ/តោន, ប្រេងឆៅ (OPEC spot) ចុះថ្លៃ ០,៧% (ឡើងថ្លៃ ៧,២% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១០៧,៣ដុល្លារ/ធុង, ហើយសាំងឡើងថ្លៃ ២,៥% (៧,២% ធៀបនឹងមួយឆ្នាំមុន) ដល់ ០,៧៣ដុល្លារ/លីត្រ។ នៅត្រីមាសទី៤ អង្ករថៃ (Thai 100% B) ឡើងថ្លៃ ០,២% ធៀបនឹងត្រីមាសមុន ដល់ ៥៩៧ដុល្លារ/តោន ប៉ុន្តែ ចុះថ្លៃ ២,២% ធៀបនឹងមួយឆ្នាំមុន។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.2 | 6.8 | 0.1 | 6.0 | 6.1 | - | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.3 | 6.1 | 4.2 | 6.2 | 6.5 | 6.3 | 6.4 | 6.2 | 6.1 | 6.0 | 5.8 | 5.6 |
| ម៉ាឡេស៊ី | 6.3 | 4.6 | -2.4 | 9.0 | 4.9 | 4.7 | 5.4 | 5.2 | 6.4 | 4.1 | 4.3 | 5.0 |
| សិង្ហបុរី | 7.7 | 1.1 | -4.5 | 14.7 | 4.7 | 1.6 | 1.9 | 0.3 | 1.5 | 0.2 | 3.7 | 5.8 |
| ថៃ | 4.9 | 2.6 | 3.3 | 7.9 | 0.0 | 0 | 4.2 | 3.3 | 19.5 | 5.4 | 2.6 | 2.6 |
| វៀតណាម | 8.5 | 6.2 | 4.7 | 6.7 | 6.1 | - | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 11.9 | 9.0 | 8.2 | 10.4 | 9.3 | 8.1 | 7.6 | 7.4 | 7.9 | 7.7 | 7.5 | 7.8 |
| ហុងកុង | 6.4 | 2.4 | -3.2 | 6.9 | 4.9 | 4.2 | 3.6 | 1.3 | 2.5 | 2.8 | 3.3 | 2.9 |
| កូរ៉េខាងត្បូង | 4.9 | 2.2 | -1.0 | 6.1 | 3.6 | 3 | 2.4 | 1.5 | 1.6 | 1.5 | 2.3 | 3.3 |
| តៃវ៉ាន់ | 5.2 | 0.1 | -3.6 | 11.1 | 4.2 | 0.4 | -0.2 | 1.0 | 3.7 | 1.7 | 2.3 | 1.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.9 | 0.9 | -3.8 | 1.6 | 1.6 | 0 | -0.4 | -0.6 | -0.9 | 1.1 | -0.7 | -0.4 |
| ជប៉ុន | 2 | -0.7 | -5.4 | 4.1 | -0.8 | 2.8 | 3.5 | 0.1 | 0.5 | 0.4 | 0.9 | 2.7 |
| សហរដ្ឋអាមេរិក | 2.2 | 1.1 | -2.5 | 2.7 | 1.8 | 2.1 | 2.2 | 2.5 | 1.6 | 1.8 | 1.4 | 1.6 |

Sources: International Monetary Fund, Economist and countries' statistic offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 19.7 | 19.7 | -0.5 | 4.1 | 5.5 | 5.5 | 2.9 | 1.6 | 1.8 | 1.5 | 2.2 | 3.8 |
| ឥណ្ឌូណេស៊ី | 10.1 | 10.1 | 4.7 | 5.1 | 5.4 | 3.8 | 4.5 | 4.5 | 4.4 | 5.3 | 5.7 | 8.6 |
| ម៉ាឡេស៊ី | 5.3 | 5.3 | 0.4 | 1.7 | 3.2 | 2.3 | 1.7 | 1.4 | 1.3 | 1.4 | 1.8 | 2.2 |
| សិង្ហបុរី | 6.5 | 6.5 | 0.5 | 2.9 | 5.2 | 4.9 | 5.2 | 4.2 | 4.0 | 3.6 | 1.6 | 1.8 |
| ថៃ | 5.5 | 5.5 | -0.9 | 3.1 | 3.8 | 3.4 | 2.6 | 2.9 | 3.2 | 3.1 | 2.3 | 1.7 |
| វៀតណាម | 23.3 | 23.3 | 7.3 | 9.0 | 18.6 | 16.0 | 8.6 | 5.6 | 7.0 | 6.9 | 6.6 | 7.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 5.9 | 5.9 | -0.8 | 3.2 | 5.4 | 3.8 | 2.9 | 1.9 | 2.1 | 2.4 | 2.4 | 2.8 |
| ហុងកុង | 4.3 | 4.3 | -0.3 | 2.4 | 5.3 | 5.2 | 4.2 | 3.1 | 3.8 | 2.2 | 4.0 | 5.3 |
| កូរ៉េខាងត្បូង | 4.6 | 4.6 | 2.8 | 3.0 | 4.4 | 2.9 | 2.4 | 1.6 | 1.7 | 1.4 | 1.1 | 1.2 |
| តៃវ៉ាន់ | 3.2 | 3.2 | -1.1 | 1.0 | 1.4 | 1.3 | 1.6 | 3.0 | 1.9 | 1.8 | 0.8 | 0.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 3.3 | 3.3 | 0.4 | 1.6 | 2.7 | 2.7 | 2.5 | 2.5 | 2.3 | 1.8 | 1.5 | 1.3 |
| ជប៉ុន | 1.4 | 1.4 | -1.3 | -0.7 | 0.1 | 0.3 | 0.2 | -0.4 | -0.2 | -0.3 | -0.3 | 0.9 |
| សហរដ្ឋអាមេរិក | 3.8 | 3.8 | -0.4 | 1.7 | 3.2 | 2.8 | 1.9 | 1.7 | 1.9 | 1.7 | 1.4 | 1.6 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4062.7 | 4054.2 | 4140.5 | 4187.1 | 4063.6 | 4046.0 | 4054.3 | 4060.2 | 3995.9 | 3995 | 4032.9 | 4062.0 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9419.0 | 9699.0 | 10413.8 | 9089.9 | 4374.0 | 9066.0 | 9281.3 | 9490.3 | 9614.6 | 9681.9 | 9783.6 | 10666.0 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.3 | 3.5 | 3.2 | 1.5 | 3.1 | 3.1 | 3.1 | 3.1 | 3.1 | 3.0 | 3.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.5 | 1.4 | 1.5 | 1.4 | 1.3 | 1.3 | 1.3 | 1.6 | 1.2 | 1.2 | 1.2 | 1.3 |
| ថៃ (បាត) | 32.2 | 33.4 | 34.3 | 31.7 | 30.5 | 31.0 | 31.3 | 31.3 | 30.7 | 29.8 | 29.9 | 31.4 |
| វៀតណាម (ដុង) | 16,030.0 | 16,382.0 | 17,725.2 | 19,200.8 | 20,241.9 | 20891.3 | 20,849.7 | 20,847.5 | 20,839.3 | 20,829.6 | 20,828.0 | 20,908.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 8.0 | 6.9 | 6.8 | 6.76 | 6.3 | 6.3 | 6.3 | 6.4 | 6.2 | 6.2 | 6.2 | 6.1 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.77 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 929.0 | 1137.2 | 1277.8 | 1156.3 | 1108.6 | 1131.2 | 1152.6 | 1132.9 | 1089.9 | 1085.9 | 1123.4 | 1108.8 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.9 | 31.5 | 33.0 | 31.3 | 29.4 | 29.7 | 29.6 | 29.8 | 29.2 | 29.5 | 29.9 | 29.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.7 | 0.8 | 0.7 | 0.8 | 0.8 | 0.8 | 0.8 | 0.8 | 0.8 | 0.8 |
| ជប៉ុន (យ៉េន) | 117.8 | 102.5 | 93.6 | 87.8 | 79.9 | 79.3 | 80.1 | 78.6 | 81.3 | 92.3 | 98.8 | 98.9 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៨-២០១៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No. 2) - USA (USD/តោន) | 149.1 | 218.2 | 167.3 | 167.3 | 291.4 | 277.5 | 270.5 | 327.1 | 310.9 | 305.2 | 291.4 | 246.2 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 707.7 | 912.2 | 686.8 | 834.7 | 1125.4 | 1106.7 | 1083.3 | 993.0 | 809.3 | 852.7 | 850.3 | 827.3 |
| កៅស៊ូ SMR 5 (USD/តោន) | 2202.3 | 2586.3 | 1884.8 | 3152.2 | 4630.6 | 3701.2 | 3361.0 | 2799.2 | 2941.5 | 3029.5 | 2497.2 | 2394.6 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 305.4 | 615.3 | 524.5 | 456.2 | 558.5 | 571.7 | 600.3 | 595.7 | 597.0 | 607.0 | 570.0 | 502.3 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 294.6 | 460.4 | 414.0 | 375.4 | 507.9 | 490.8 | 546.5 | 649.4 | 577.8 | 558.4 | 569.8 | 545.1 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 69.3 | 95.4 | 60.5 | 71.6 | 106.2 | 117.4 | 106.7 | 106.6 | 107.3 | 109.5 | 100.9 | 106.9 |
| សាំង - US Gulf Coast (សេន/លីត្រ) | 53.6 | 62.2 | 42.9 | 49.8 | 71.9 | 73.4 | 74.0 | 71.6 | 73.4 | 74.8 | 71.2 | 73.3 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 55.5 | 76.20 | 43.05 | 51.6 | 75.7 | 83.8 | 77.8 | 81.1 | 80.3 | 81.5 | 75.6 | 79.6 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ដោយហេតុថា នៅត្រីមាសទី៣ ស្ទើរគ្រប់វិស័យនៃសេដ្ឋកិច្ចកម្ពុជាមានដំណើរការល្អជាងត្រីមាសមុនៗ គេគន់គូរថា កម្ពុជានឹងមានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ៧% ក្នុងឆ្នាំ២០១៣ នេះ។ ការប្រឈមមុខដាក់គ្នាផ្នែកនយោបាយរវាងគណបក្សប្រឆាំង និងគណបក្សកាន់អំណាច បានពុះកញ្ជ្រោលឡើង ចាប់តាំងពីការបោះឆ្នោតជាតិក្នុងខែកក្កដា មក។

នៅត្រីមាសទី៣ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធ្លាក់ចុះ ៨៧,៧% ធៀបនឹងត្រីមាសមុន (៣៩,៩% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២៥៧,៩លានដុល្លារ ដែលបណ្តាលជាចម្បងពី ការថយចុះវិនិយោគក្នុងវិស័យឧស្សាហកម្ម។ វិនិយោគក្នុងវិស័យកាត់ដេរ ធ្លាក់ចុះ ១៤,៧% ធៀបនឹងត្រីមាសមុន (៣៩,២% ធៀបមួយឆ្នាំមុន) មកត្រឹម ៦៥,២លានដុល្លារ។ ភាពមិនប្រាកដប្រជាផ្នែកអាជីវកម្មបណ្តាលមកពី ការធ្វើបាតុកម្មដោយគណបក្សប្រឆាំង និងកម្មករ ដើម្បីទាមទារតម្លើងប្រាក់ខែ អាចជាមូលហេតុមួយនៃការធ្លាក់ចុះនេះ។ មានការប្រមើលជាមុនថា វិនិយោគក្នុងវិស័យកាត់ដេរនឹងប្តូរទិសដៅទៅកាន់ប្រទេសដទៃ ហើយក្នុងនោះ ភូមា ជាគូប្រជែងប្រកបដោយសក្តានុពលមួយ ប្រសិនបើប្រាក់ខែអប្បបរមារបស់កម្ពុជា នៅតែបន្តកើនឡើង។ តម្រូវការប្រាក់ខែអប្បបរមា ១៦០ដុល្លារ/ខែ ជាបន្ទុកដ៏ធ្ងន់ធ្ងរសម្រាប់ ម្ចាស់រោងចក្រ។ កំណើននេះចាំបាច់ត្រូវធ្វើឡើងជាដំណាក់កាល។ លើសពីនេះទៀត ត្រូវតែលុបបំបាត់ថ្លៃសេវា ក្រៅផ្លូវការ។ ការវិនិយោគក្នុងវិស័យកសិកម្មកើនឡើងដល់ ១៣៣,១លានដុល្លារ ធៀបនឹងមួយត្រីមាសមុន ប៉ុន្តែធ្លាក់ចុះ ២៦,៥% ធៀបនឹងមួយឆ្នាំមុន។ ទោះបីជារដ្ឋាភិបាល បានពង្រឹងការប្រកួតប្រជែង និងផលិតភាពនៃវិស័យកសិកម្មក្តី ក៏វិស័យនេះមិនទទួលបានទំនុកចិត្តពេញលេញពីវិនិយោគិនឡើយ។ ការឡើងចុះនៃវិនិយោគនៅតែជាបញ្ហាប្រឈមមួយ ចំពោះគោលដៅនាំចេញអង្ករ ១លានតោន។ វិនិយោគក្នុងផ្នែកសេវាកម្ម មានការធ្លាក់ចុះ បើធៀបនឹងត្រីមាសមុន ប៉ុន្តែវាកើនដល់ ៥,៣លានដុល្លារ ធៀបនឹងមួយឆ្នាំមុន។ មិនមានការវិនិយោគលើវិស័យសណ្ឋាគារ និងសកម្មភាពទាក់ទងវិស័យទេសចរណ៍ទេ។ នៅត្រីមាសទី៣ ចំនួនភ្ញៀវទេសចរមកដល់ កើន ៤,៨% ធៀបនឹងត្រីមាសមុន (១៧,៥% ធៀបមួយឆ្នាំមុន) ដោយភ្ញៀវមកតាមផ្លូវអាកាស កើន ៧,៥% (១៥,៥% ធៀបនឹងមួយឆ្នាំមុន) និងតាមផ្លូវគោក និង ផ្លូវទឹក កើន ២,៧% (១៩,២% ធៀបនឹងមួយឆ្នាំមុន)។ ភាពជាប់គាំងនយោបាយ មិនបានប៉ះពាល់ជាអវិជ្ជមានដល់ចំនួនភ្ញៀវទេសចរមកដល់ទេ។

វិស័យសំណង់បានរើបឡើងវិញជាបន្តបន្ទាប់។ តម្លៃការសាងសង់សរុបនៅត្រីមាសទីបី កើន ៦០,០% ធៀបនឹង ត្រីមាសមុន ដល់ ៤៥០,៣លានដុល្លារ។ តម្លៃគម្រោងសាងសង់វីឡា និងផ្ទះកើនដល់ ៥១,៦លានដុល្លារ ធៀបនឹង ១០,៣លានដុល្លារ កាលពីត្រីមាសមុន និង ១៨,៣លានដុល្លារ កាលពីមួយឆ្នាំមុន ហើយសម្រាប់ការសាងសង់ផ្ទះល្វែង កើនដល់ ៦២,៧លានដុល្លារ ធៀបនឹង ៦១,៦លានដុល្លារ កាលពីមួយឆ្នាំមុន។

បើទោះបីមានការប្រឈមមុខដាក់គ្នា និងការខ្វែងគំនិតគ្នារវាងនិយោជិក នឹងម្ចាស់រោងចក្រ ពិសេសលើប្រាក់ខែអប្បបរមា និងការរំពឹងទុកថា វិនិយោគិនអាចប្តូរទិសដៅទៅកាន់មីយ៉ាន់ម៉ាក្តី ក៏ការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភណ្ឌមានការកើនឡើង ដោយរួមចំណែកប្រហែល ៨០% នៃតម្លៃនាំចេញសរុបនៅត្រីមាសទីបី។ ការនាំចេញសរុប កើន ២២% ធៀបនឹងត្រីមាសមុន (២៣,៤% ធៀបមួយឆ្នាំមុន) ដល់ ២,០ ពាន់លានដុល្លារ ដែលក្នុងនោះ ការនាំចេញសម្លៀកបំពាក់ កើន ២៤,៦%(១៨,០%ធៀបមួយឆ្នាំមុន)ដល់១,៦ពាន់លានដុល្លារ។ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប នៅតែជាទីផ្សារដ៏សំខាន់ពីរ ដោយរួមចំណែក ៣៨,១% និង ៣៦,៥% រៀងគ្នា នៃការនាំចេញសម្លៀកបំពាក់សរុប។ ការរើបឡើងវិញសន្សឹមៗនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ជាកត្តាខាងក្រៅដ៏សំខាន់សម្រាប់សេដ្ឋកិច្ចកម្ពុជា។ គំនិតផ្តួចផ្តើមធ្វើពិពិធកម្មទីផ្សារ ក៏មានសារៈសំខាន់ផងដែរ។ ការនាំចេញផលិតផលកសិកម្ម ដែលមានអង្ករ និង កៅស៊ូ ជាមុខទំនិញសំខាន់នោះ បានកើនឡើងយ៉ាងរហ័ស ដល់ ៣៦២,៤លានដុល្លារ ឬ កើន ៨៦,១លានដុល្លារ បើធៀបនឹងមួយឆ្នាំមុន។

នៅត្រីមាសទី៣ ការនាំចូលសរុប ធ្លាក់ចុះ ៦,៩% ធៀបនឹងត្រីមាសមុន មកត្រឹម ២,១ពាន់លានដុល្លារ ប៉ុន្តែ កើន ២,២% ធៀបនឹងមួយឆ្នាំមុន។ ការនាំចូលប្រេងសាំង ធ្លាក់ចុះ ៧,៦% ធៀបនឹងត្រីមាសមុន(៨,៦%ធៀបនឹងមួយឆ្នាំមុន)ឯប្រេងម៉ាស៊ូត កើន ៩,៨% (៩,១% ធៀបនឹងមួយឆ្នាំមុន) និងសម្ភារៈសាងសង់ កើន ១,៤% (៩,១% ធៀបនឹងមួយឆ្នាំមុន)។ ឱនភាពពាណិជ្ជកម្មនៅត្រីមាសទីបី ធ្លាក់ចុះ ៨៥% ធៀបនឹងត្រីមាសមុន (៧៨,៥% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៨៩,៨លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទីបី ប្រាក់ចំណូលសរុប ធ្លាក់ចុះ ៧៣,១% ធៀបនឹងត្រីមាសមុន (៦៨,៨% ធៀបមួយឆ្នាំមុន) មកត្រឹម ៥៩២,៨ពាន់លានរៀល។ ចំណូលចរន្ត ធ្លាក់ចុះ ៧៣,៣% (៦៧,៤% ធៀបមួយឆ្នាំមុន)។ ចំណូលពន្ធ ដែលមានចំណែក ៨៧,៣% នៃចំណូលសរុបនោះ បានធ្លាក់ចុះ ៧៤,៧% ធៀបនឹងត្រីមាសមុន (៦៧,២% ធៀបមួយឆ្នាំមុន) មកត្រឹម ៥១២,២ ពាន់លានរៀល។ ចំណូលពន្ធក្នុងស្រុក ធ្លាក់ចុះ ៧៥,២% (៦៦,៧% ធៀបមួយឆ្នាំមុន) មកត្រឹម ៤០៩,២ពាន់លានរៀល ហើយចំណូលពន្ធពាណិជ្ជកម្មអន្តជាតិ ធ្លាក់ចុះ ៧២% (៦៨,៨% ធៀបមួយឆ្នាំមុន) មកត្រឹម ១០៤ពាន់លានរៀល។ ការធ្លាក់ចុះនេះប្រហែលបណ្តាលមួយផ្នែកមកពី បញ្ហានយោបាយ តាំងពី

[១] អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

ការបោះឆ្នោតថ្នាក់ជាតិខែកក្កដារួចមក។ កូដកម្ម និងបាតុកម្មជាញឹកញាប់ដោយកម្មកររោងចក្រកាត់ដេរ ដែលមួយចំនួនត្រូវបានបង្ក្រាបនោះ ក៏ប៉ះពាល់ដល់ផលិតកម្ម និងធ្វើឲ្យថយចុះប្រាក់ចំណូលជាប់ពន្ធពីរោងចក្រផងដែរ។ នៅត្រីមាសដដែល ចំណាយសរុបរបស់រដ្ឋាភិបាល ធ្លាក់ចុះ ៦៧,២% ធៀបនឹងត្រីមាសមុន (៧៨,៦% ធៀបមួយឆ្នាំមុន) មកត្រឹម ៦៣១,៧ ពាន់លានរៀល ដែលក្នុងនោះ ចំណាយចរន្ត ធ្លាក់ចុះ ៧៤,៨% (៧៥,៨% ធៀបមួយឆ្នាំមុន) មកត្រឹម ៤២៤,៧ពាន់លានរៀល។ ការធ្លាក់ចុះនេះ អាចឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តជាបន្តរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់ចំណាយមិនចាំបាច់នានាប៉ុន្តែការថយចុះនៃមូលនិធិសម្រាប់ផ្នែកសំខាន់ៗ ដូចជា បៀវត្សរ៍មន្ត្រីរាជការ ឧបត្ថម្ភធន និងជំនួយសង្គមផ្សេងទៀត អាចធ្វើឱ្យអន្តរាយដល់កំណើនសេដ្ឋកិច្ចរយៈពេលវែង និងប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងភ្ជិតគម្លាតវិសមភាពសង្គម និងសេដ្ឋកិច្ច។ ចំណាយលើបៀវត្សរ៍ ធ្លាក់ចុះ ៧០,៩% ធៀបនឹងត្រីមាសមុន (៧៣,៩% ធៀបមួយឆ្នាំមុន) មកត្រឹម ១៧១,៨ពាន់លានរៀល ហើយចំណាយឧបត្ថម្ភធន និងជំនួយសង្គមផ្សេងទៀត ធ្លាក់ចុះ ៨៤,៩% (៧៩,១% ធៀបមួយឆ្នាំមុន) មកត្រឹម ៩៦,៧ពាន់លានរៀល។

## អតិផរណានិងអត្រាប្តូរប្រាក់

អតិផរណាមានកម្រិតអាចគ្រប់គ្រងបាន ប៉ុន្តែវាមាននិន្នាការកើនឡើងសម្រាប់រយៈពេលបីត្រីមាសកន្លងទៅ។ នៅត្រីមាសទីបី អត្រាអតិផរណា កើន ៣,៧% ធៀបនឹង ២.៣% នៅត្រីមាសមុន និង ១,៦% នៅឆ្នាំមុន ។ ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើនដល់ ៤,៨% ធៀបនឹង ១,៣% នៅឆ្នាំមុន។ ចំណុចនេះអាចប៉ះពាល់ខ្លាំង លើជីវភាពគ្រួសារក្រីក្រ និងគ្រួសារមានប្រាក់ចំណូលមធ្យមកម្រិតទាប ប្រសិនបើប្រាក់ខែចារឹក របស់គាត់នៅគាំងទ្រឹង។ មាស ធ្លាក់ថ្លៃ ៧,១% ធៀបនឹងត្រីមាសមុន (១៨,៨% ធៀបមួយឆ្នាំមុន) មកត្រឹម ១៦១,១ដុល្លារ/ជី ហើយប្រេងសាំង ធ្លាក់ថ្លៃ ០,៦% (០,១% ធៀបមួយឆ្នាំមុន) មកត្រឹម ៥២៤៥,២រៀល/លីត្រ។ នៅត្រីមាសទីបី ប្រេងម៉ាស៊ូត ធ្លាក់ថ្លៃ ០,៦% ធៀបនឹងត្រីមាសមុន (០,៨% ធៀបមួយឆ្នាំមុន) មកត្រឹម ៥០២២,៥រៀល/លីត្រ។

## ការវិវត្តិរូបិយវត្ថុ

នៅត្រីមាសទីពីរ ឆ្នាំ២០១៣ សាច់ប្រាក់ងាយស្រួលសរុប កើន ៣,៩% ធៀបនឹងត្រីមាសមុន (១៨,៨% ធៀបមួយឆ្នាំមុន) ដល់ ៣១.៦៥៩,១ពាន់លានរៀល។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៩% ធៀបនឹងត្រីមាសមុន (១៦,២% ធៀបមួយឆ្នាំមុន) ដល់ ២១.៧៧២,៩ពាន់លានរៀល។ អំឡុងពេលដដែលនេះ រូបិយវត្ថុ កើន ១,៩% ធៀបនឹងត្រីមាសមុន (១៨,៤% ធៀបមួយឆ្នាំមុន) ហើយរូបិយវត្ថុផ្សេងៗ កើន ៤,២% (១៨,៨% ធៀបមួយឆ្នាំមុន)។ កំណើនសាច់ប្រាក់ងាយស្រួលជាសញ្ញាល្អ សម្រាប់សេដ្ឋកិច្ច។ ទោះយ៉ាងណាក្តី រដ្ឋាភិបាលត្រូវធានារក្សាកំណើននេះកុំឲ្យមានកម្រិតខ្ពស់ហួសពេក។ កំណើនការផ្គត់ផ្គង់ប្រាក់ ជាទិដ្ឋភាពមួយផ្សេងទៀតដែលទាមទារការត្រួតពិនិត្យល្អិតល្អន់ ពីសំណាក់ធនាគារជាតិនៃកម្ពុជា។ ទោះបីជាអតិផរណាប្រចាំឆ្នាំ មិនមានការកើនឡើងជាដុំកំភួនក្តី ក៏ការផ្គត់ផ្គង់រូបិយវត្ថុច្រើនពេក អាចបណ្តាលឱ្យទំនិញឡើងថ្លៃខ្ពស់ក្នុងរយៈពេលវែង។នៅត្រីមាសទីបី ថ្លៃទំនិញកសិកម្មពិភពលោកភាគច្រើន បានធ្លាក់ចុះ ទោះបីប្រេងនៅ ឡើងថ្លៃបន្តិចក្តី ប៉ុន្តែថ្លៃទំនិញជារួមមានការកើនឡើង។

## ស្ថានភាពក្រីក្រ

នៅខែវិច្ឆិកា ចំណូលប្រចាំថ្ងៃពិតរបស់ក្រុមងាយរងគ្រោះទាំងអស់ កើនឡើង បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ចំណូលរបស់អ្នកលីសែង, អ្នករត់ម៉ូតូឌុប, អ្នកបំរើគុភោជនីយដ្ឋាន និងអ្នកស៊ីឈ្នួលធ្វើស្រែ ធ្លាក់ចុះ ខណៈចំណូលក្រុមផ្សេងទៀត កើនឡើង បើធៀបនឹងខែសីហា។

ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែ ធ្លាក់ចុះ ១៨% ពី ៧៧៧០,៩រៀល កាលពីខែសីហា។ ៧០% នៃអ្នកឆ្លើយសម្ភាសន៍បានឲ្យដឹងថា ចំនួនកម្មករបានធ្លាក់ចុះ ដោយសារអ្នកខ្លះរកបានការងារធ្វើក្នុងជំនាញផ្សេងទៀត ខណៈអត្រាប្រាក់ខែមិនកើនឡើង។ កម្មករ ៣៥% ធ្វើការយ៉ាងតិច ១៤ថ្ងៃ/ខែ។ ចំណូលប្រចាំថ្ងៃរបស់ពួកគេ អាចត្រឹមទ្រទ្រង់គ្រួសារមួយផ្នែកប៉ុណ្ណោះ។ ភាគច្រើន ពួកគេខ្ចីប្រាក់ ឬសុំជំនួយពីសាច់ញាតិ ប្រសិនបើចំណូលពួកគេមិនអាចបំពេញតំរូវការចំណាយប្រចាំថ្ងៃ ដែលចំណាយមួយភាគធំ គឺលើម្ហូបអាហារ។

ស្ទើរតែ ៩៨% នៃអ្នកជាក់ស៊ីក្លូ ដែលបានជ្រើសរើសដោយចៃដន្យសម្រាប់អង្កេតនេះ មកពីខេត្តផ្សេងៗ ពិសេស ខេត្តស្វាយរៀង (២៨%)។ អ្នកជាក់ស៊ីក្លូ ៨៥% មកភ្នំពេញតែម្នាក់ឯង។ ពួកគេរកចំណូលបាន ១,៩% ច្រើនជាង កាលពីអង្កេតលើកមុន គឺកើនដល់ ១០.៨៤១,៦រៀល/ថ្ងៃ ជាចំបងដោយសារចំនួនអ្នកជាក់ស៊ីក្លូមានការថយចុះ។ ពួកគេត្រូវផ្ញើប្រាក់ទៅផ្ទះ ព្រោះពួកគេជាប្រភពចំណូលតែមួយគត់នៅក្នុងគ្រួសារ។ អ្នកជាក់ស៊ីក្លូ ៦៨% ស្នាក់នៅតាមចិញ្ចើមថ្នល់ ឬក្នុងវត្ត។

ផ្អែកតាមព័ត៌មានបានអ្នកឆ្លើយសម្ភាសន៍ ៨៨% បានឲ្យដឹងថា ចំណូលប្រចាំថ្ងៃរបស់កម្មករលីសែង ធ្លាក់ចុះ ៦,៣% ធៀបនឹងការអង្កេតលើកមុន ដោយសារជាចំបងមកពីមានកំណើនកម្មករ។ ប្រាក់ចំណូលពួកគេមិនអាចបំពេញតំរូវការគ្រួសារបានទេ។ ជាមធ្យម ប្រាក់ចំណូល ៨៨% របស់ពួកគេ ត្រូវបានចំណាយលើម្ហូបអាហារ និងជិត ១០% លើការជួលផ្ទះ។

អ្នកលក់បន្លែរកចំណូលបាន ៨,៣% ច្រើនជាងកាលពីខែសីហា។ អ្នកលក់បន្លែ ៤០% មកពីខេត្តកណ្តាល ហើយត្រូវធ្វើដំណើរទៅមកជារៀងរាល់ថ្ងៃ។ ចំណាយប្រចាំថ្ងៃរបស់ពួកគេ ៨,៧% គឺទៅលើការដឹកជញ្ជូន និង ៨៨% លើម្ហូបអាហារ។ ប្រាក់ចំណូលនេះ មិនអាចឲ្យពួកគេសន្សំទុកដើម្បីពង្រីកអាជីវកម្មរបស់ខ្លួនបានទេ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ កម្មករសំណង់គ្មានជំនាញ កើន ៣,១%។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់មកពីតាមបណ្តាខេត្តនានា ហើយក្នុងនោះ ៤៨% មកពីស្វាយរៀង។ ពួកគេ ៧០% ជួលផ្ទះគេ ហើយស្នាក់នៅ រួមគ្នា ដោយជាមធ្យមមានគ្នា ៩នាក់ និងចែកគ្នាជួយចេញថ្លៃជួលផ្ទះ។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់ជា

មេគ្រួសារ តែមិនអាចទ្រទ្រង់គ្រួសារបានទាំងស្រុងទេ។

ស្រដៀងគ្នានឹងអ្នកលីសែងដែរ ប្រាក់ចំណូលពិតរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ៣,៤% ធៀបនឹងកាលពីខែសីហា មកត្រឹម ១៣.១៨៩,២រៀល/ថ្ងៃ។ អ្នករត់ម៉ូតូឌុប ២៥% មកពីខេត្តព្រៃវែង ១៧% មកពីស្វាយរៀង និង ១២% មកពីភ្នំពេញ។ ចំនួនអ្នករត់ម៉ូតូឌុប កើនឡើង ព្រោះពួកគេមិនអាចរកការងារផ្សេងបាន។ អ្នកឆ្លើយសម្ភាន៍ជាងពាក់កណ្ដាលជួលផ្ទះស្នាក់នៅរួមគ្នាយ៉ាងតិចបួននាក់។ ពួកគេចំណាយប្រាក់ចំណូលជិត ៩៦% ទៅលើម្ហូបអាហារ។

នៅខែវិច្ឆិកា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកបម្រើតុភោជនីយដ្ឋាន ធ្លាក់ចុះ ១,០% មកត្រឹម ៦៧២២,៧រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់ ទទួលបានការស្នាក់នៅពីភោជនីយដ្ឋានដែលពួកគេធ្វើការនោះ។ ចំណាយលើម្ហូបអាហារជាមធ្យមមានចំណែក ៤១% នៃចំណាយប្រចាំថ្ងៃរបស់ពួកគេ។ អ្នកឆ្លើយសម្ភាសន៍ ៧៨% អាចមានប្រាក់សល់ផ្ញើទៅផ្ទះ។ ពួកគេកម្រទុកប្រាក់សម្រាប់ខ្លួនគេផ្ទាល់ ឬមុខរបរទៅថ្ងៃអនាគតណាស់។

កម្មករកាត់ដេរ រកចំណូលបាន ១០.៤៤១,៥រៀល/ថ្ងៃ ឬកើន ០,២% ធៀបនឹងកាលពីអង្កេតលើកមុន។ ពួកគេអាចទ្រទ្រង់គ្រួសារខ្លួនបានមួយផ្នែកប៉ុណ្ណោះ និងមិនអាចសន្សំប្រាក់ទុកឡើយ។ កម្មករ ៥៥% គ្មានបំណងផ្លាស់ប្ដូរការងារទេ និងចង់ធ្វើការនេះឲ្យយូរតាមដែលអាចធ្វើទៅបាន ព្រោះពួកគេគ្មានជំនាញផ្សេងទេ។ ជាមធ្យមកម្មកររៀនចប់ត្រឹមថ្នាក់ទី៦។ កម្មករ ៨២% ត្រូវបានបណ្ដុះបណ្ដាល បន្ទាប់ពីបានជ្រើសរើសឲ្យបំរើការងារ។

# តាមដានសេដ្ឋកិច្ច-សូចនាករ

## តារាង ១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៧-១៣*

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 135.6 | 92.0 | 615.0 | 530.68 | 725 | 154.73 | 81.2 | 181.1 | 114.6 | 2.3 | 56.8 | 133.1 |
| ឧស្សាហកម្ម | 709.1 | 724.9 | 818.5 | 403.66 | 2860.1 | 211 | 173.7 | 245.6 | 196.5 | 195.4 | 1928.3 | 119.5 |
| *កាត់ដេរ* | *170.7* | *142.8* | *90.1* | *122.81* | *393.9* | *139.4* | *97.5* | *107.2* | *152.9* | *109.5* | *76.4* | *65.15* |
| សេវាកម្ម | 1742.5 | 10,003.2 | 4432.0 | 1337.34 | 3425.4 | 50.9 | 18.0 | 2.1 | 845.6 | 21.2 | 106.0 | 5.3 |
| *សណ្ឋាគារ និងទេសចរណ៍* | *1048.3* | *8758.1* | *3980.1* | *1105.14* | *2850.9* | *50.9* | *0.0* | *0.0* | *640.6* | *0.0* | *106.0* | *0.0* |
| សរុប | 2587.2 | 10,570.9 | 5865.5 | 2271.7 | 7010.42 | 416.59 | 273.0 | 428.8 | 1156.6 | 218.9 | 2091.1 | 257.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 68.9 | -33.9 | 55.6 | 169.8 | -81.1 | 855.5 | -87.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 246.6 | 308.6 | -44.5 | -61.3 | 209 | 48.4 | -89.6 | -84.4 | -13.6 | -47.5 | 666.0 | -39.9 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង ២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៧-១៣

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 79.1 | 154.7 | 64.3 | 36.2 | 185.5 | 64.8 | 66.6 | 18.3 | 8.5 | 145.2 | 10.3 | 51.6 |
| ផ្ទះល្វែង | 297.2 | 221.6 | 149.6 | 183.8 | 219.6 | 60.8 | 219.3 | 61.6 | 10.2 | 114.1 | 33.0 | 62.7 |
| ផ្សេងៗ | 259.6 | 740.9 | 227.3 | 269.7 | 199.9 | 197.2 | 47.8 | 94.9 | 41.2 | 154.4 | 238.3 | 336.0 |
| សរុប | 635.8 | 1117.0 | 441.2 | 489.8 | 605.0 | 322.8 | 333.6 | 174.9 | 59.9 | 443.7 | 281.6 | 450.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 117.1 | 3.3 | -47.6 | -65.8 | 590.9 | -36.5 | 59.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 96.7 | 75.7 | -60.5 | 11 | 23.5 | 145.5 | 331.1 | -29.3 | -59.7 | 28.1 | -15.6 | 157.5 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង ៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៧-១៣

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 79.1 | 1239.4 | 1111.7 | 1304.3 | 1480.4 | 5137.6 | 317.1 | 370.5 | 500.7 | 611.2 | 398.1 | 428.0 |
| តាមផ្លូវគោក និងទឹក | 297.2 | 881.9 | 999.7 | 1094.6 | 14014.6 | 4814.5 | 424.3 | 450.3 | 506.1 | 560.9 | 522.5 | 536.6 |
| សរុប | 259.6 | 2121.3 | 2111.5 | 2398.9 | 28818.6 | 9952.1 | 761.4 | 820.9 | 1006.8 | 1172.1 | 920.5 | 964.6 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | 24.9 | -23.5 | 7.8 | 22.6 | 16.4 | -21.5 | 4.8 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 96.7 | 5.3 | 0.5 | 13.6 | 20.1 | 27.8 | 25.5 | 17.3 | 26.3 | 17.8 | 20.9 | 17.5 |

Source: Ministry of Tourism

## តារាង ៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៧-១៣*

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 3161.6 | 3097.8 | 2901.6 | 3630.2 | 4929.5 | 1280.1 | 1775.9 | 1595.8 | 1454.7 | 1576.9 | 1620.1 | 1969.9 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 3050.2 | 2986.2 | 2565.3 | 3223.4 | 4259.6 | 1070.78 | 1474.7 | 1329.1 | 1140.83 | 1225.2 | 1258.95 | 1568.5 |
| - *សហរដ្ឋអាមេរិក* | 1959.9 | 1908.3 | 1512.6 | 1853.9 | 2055.3 | 493.31 | 627.3 | 566.6 | 456.07 | 526.8 | 474.62 | 597.86 |
| - *សហភាពអឺរ៉ុប* | 660.9 | 689.0 | 644.7 | 809.5 | 1322.2 | 328.4 | 504.1 | 462.7 | 421.82 | 397.5 | 477.47 | 572.76 |
| - *អាស៊ាន* | 90.3 | 10.76 | 6.9 | 9.9 | 17.63 | 6.43 | 11.7 | 11.4 | 9.76 | 13.0 | 12.66 | 17.36 |
| - *ជប៉ុន* | 30.1 | 25.2 | 44.5 | 86.5 | 146.97 | 50.11 | 48.9 | 47.1 | 42.47 | 57.6 | 51.39 | 98.13 |
| - *ប្រទេសផ្សេងៗ* | 309.0 | 352.9 | 356.5 | 463.6 | 717.5 | 192.53 | 282.7 | 241.3 | 210.71 | 230.3 | 242.81 | 282.39 |
| កសិកម្ម | 55.6 | 44.5 | 73.1 | 164.9 | 362.05 | 80.52 | 101.3 | 86.1 | 108.77 | 123.8 | 128.9 | 362.4 |
| - *កៅស៊ូ* | 41.0 | 35.8 | 51.6 | 89.1 | 197.63 | 40.27 | 46.4 | 46.1 | 43.84 | 36.6 | 38.67 | 282.39 |
| - *ឈើ* | 8.7 | 3.4 | 3.5 | 34.1 | 48.79 | 8.9 | 12.4 | 4.1 | 11.6 | 14.5 | 8.88 | 16.86 |
| - *ត្រី* | 3.2 | 2.3 | 3.9 | 2.8 | 3.12 | 0.5 | 0.7 | 0.4 | 0.4 | 0.3 | 0.5 | 0.18 |
| - *ស្រូវ* | 2.7 | 2.6 | 10.9 | 34.7 | 106.56 | 27.1 | 37.5 | 31.7 | 50.2 | 65.8 | 56.47 | 57.29 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 55.8 | 0.5 | 3.0 | 4.1 | 5.95 | 3.9 | 4.4 | 3.9 | 2.8 | 6.6 | 24.41 | 5.7 |
| ផ្សេងៗ | 554.8 | 67.1 | 263.22 | 242.0 | 307.86 | 128.8 | 199.9 | 180.6 | 205.1 | 274.9 | 232.24 | 272.59 |
| ការនាំចូលសរុប | 58.7 | 4272.5 | 4331.5 | 5190.6 | 6375.9 | 1609.2 | 1885.4 | 2015.2 | 1938.2 | 2192.1 | 2211.4 | 2059.7 |
| ក្នុងនេះ៖ សាំង | | | | | | | | | | | | |
| ម៉ាស៊ូត | 122.8 | 84.8 | 91.13 | 108.6 | 294.4 | 70.7 | 76.7 | 78.0 | 78.8 | 1225.2 | 77.19 | 71.3 |
| សម្ភារៈសំណង់ | 69.0 | 19.5 | 180.67 | 203.8 | 447 | 139.4 | 126.6 | 138.3 | 139.9 | 526.8 | 137.44 | 150.9 |
| ផ្សេងៗ | 304.3 | 56.3 | 49.74 | 57.6 | 48.09 | 13.5 | 14.1 | 16.5 | 16.6 | 397.5 | 17.75 | 18.0 |
| ជញ្ជីងពាណិជ្ជកម្ម | 2606.8 | 4011.8 | 4010 | 4820.6 | 5586.4 | 1385.7 | 1668.0 | 1782.4 | 1703.0 | 13.0 | 1979 | 1819.4 |
| | 3161.6 | -1174.7 | -1429.9 | -1560.5 | -1446.4 | -326.12 | 109.5 | -419.4 | -483.5 | -615.2 | -591.24 | -89.8 |
| ការនាំចេញសម្លៀកបំពាក់សរុប | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| ការនាំចេញសរុប | - | - | - | - | - | -5.2 | 37.7 | -9.9 | -14.2 | 7.4 | 2.8 | 24.6 |
| ការនាំចូលសរុប | - | - | - | - | - | -3.3 | 38.7 | -10.1 | -8.8 | 8.4 | 2.7 | 21.6 |
| | - | - | - | - | - | -6.0 | 17.2 | 6.9 | -3.8 | 13.1 | 0.9 | -6.9 |
| ការនាំចេញសម្លៀកបំពាក់សរុប | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសរុប | 8.5 | 1.6 | -14.1 | 25.7 | 32.1 | 21.6 | 53.0 | 3.4 | 1.0 | 14.4 | -14.6 | 18.0 |
| ការនាំចូលសរុប | 8.2 | 1.6 | -6.3 | 25.1 | 35.8 | 25.8 | 56.9 | 9.6 | 9.9 | 23.2 | -8.8 | 23.4 |
| Total imports | 8.3 | 1.3 | 1.4 | 19.8 | 22.8 | 10.6 | 11.6 | 32.7 | 13.2 | 36.2 | 17.8 | 2.6 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៧-១៣ ( ពាន់លានរៀល )

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 1146.1 | 5290.0 | 5988.99 | 2805.83 | 6251.4 | 1728.9 | 2045.1 | 1900.8 | 2017.0 | 1820.2 | 2204.8 | 1868.9 |
| ចំណូលចរន្ត | 1141.6 | 5210.7 | 5859.08 | 2786.12 | 6179.3 | 1725.8 | 1928.6 | 1796.4 | 1993.1 | 1814.3 | 2193.3 | 1858.1 |
| ចំណូលពន្ធ | 965.2 | 4409.9 | 4692.96 | 2457.02 | 5277.5 | 1403.8 | 1721.8 | 1560.7 | 1648.5 | 1575.3 | 2024.1 | 1646.0 |
| ពន្ធក្នុងស្រុក | 661.8 | 3248.4 | 3533.57 | 1727.10 | 4071.6 | 1092.3 | 1403.4 | 1230.0 | 1277.2 | 1253.1 | 1653.0 | 1300.6 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 303.5 | 1161.5 | 1159.39 | 639.00 | 1205.9 | 311.3 | 318.4 | 330.7 | 371.4 | 322.3 | 371.1 | 345.4 |
| ចំណូលមិនមែនពន្ធ | 176.4 | 800.8 | 1166.13 | 507.13 | 901.8 | 331.0 | 206.9 | 235.7 | 344.6 | 239.0 | 169.2 | 212.2 |
| ចំណូលលើទ្រព្យសម្បត្តិ | 13.6 | 78.0 | 291.13 | 4.87 | 63.8 | 91.3 | 13.1 | 22.5 | 16.2 | 8.2 | 18.1 | 24.3 |
| លក់ទំនិញ និងសេវា | 124.3 | 424.7 | 460.07 | 268.08 | 588.7 | 166.9 | 171.4 | 132.8 | 196.3 | 152.8 | 137.0 | 178.8 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 38.5 | 298.2 | 408.91 | 391.70 | 249.3 | 63.8 | 22.4 | 80.5 | 132.1 | 78.0 | 14.0 | 9.0 |
| ចំណូលជាមូលធន | 4.5 | 79.3 | 129.92 | 2019.39 | 72.1 | 3.1 | 116.4 | 104.4 | 23.9 | 5.9 | 11.5 | 10.7 |
| ចំណាយសរុប | 1689.7 | 6297.8 | 8784.65 | 4259.67 | 9032.4 | 1532.5 | 2425.6 | 2951.3 | 2751.5 | 925.9 | 1925.7 | 2229.7 |
| ចំណាយជាមូលធន | 807.4 | 2574.4 | 2853.23 | 1495.19 | 3546.9 | 699.9 | 716.2 | 1194.5 | 1017.7 | 146.3 | 239.8 | 802.8 |
| ចំណាយចរន្ត | 882.3 | 3809.0 | 4773.07 | 2848.81 | 5341.2 | 988.4 | 1709.4 | 1756.7 | 1733.9 | 879.6 | 1685.8 | 1740.9 |
| បៀវត្សរ៍ | 362.6 | 1397.0 | 2048.81 | 1208.81 | 2170.6 | 508.9 | 725.2 | 657.5 | 595.0 | 395.3 | 590.2 | 825.3 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 194.2 | 927.1 | 1099.42 | 613.31 | 1518.8 | 189.6 | 514.6 | 462.1 | 420.5 | 247.4 | 642.5 | 285.3 |
| ចំណាយចរន្តផ្សេងទៀត | 325.5 | 1384.9 | 1624.84 | 1067.07 | 1651.8 | 289.9 | 469.7 | 637.1 | 718.4 | 236.9 | 453.2 | 630.3 |
| សមតុល្យជាទូទៅ | -543.6 | -1007.8 | -2795.66 | -1453.83 | -1271.4 | 196.5 | -380.6 | -1050.5 | -734.5 | 0.0 | 144.2 | -360.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 741.5 | 2055.10 | 1845.21 | 772.81 | -2781.0 | 577.8 | 491.5 | 959.3 | 429.2 | 894.4 | 502.8 | 484.5 |
| ហិរញ្ញប្បទានក្នុងស្រុក | -185.8 | -127.00 | 938.64 | 567.96 | 2379.2 | -565.7 | 148.4 | 22.1 | 62.4 | -44.2 | 136.5 | 286.2 |

Source: MEF website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស ( មធ្យមភាគតាមការិយបរិច្ឆេទ ) ២០០៧-១៣

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ( តុលា-ធ្នូ ២០០៦:១០០ ) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ( បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន ) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 19.7 | -0.7 | 4.1 | 5.4 | 2.9 | 2.9 | 1.6 | 1.8 | 1.5 | 2.3 | 3.7 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 9.9 | 33.1 | -0.3 | 4.4 | 6.5 | 3.4 | 3.4 | 1.3 | 1.4 | 1.6 | 3.3 | 4.8 |
| - ដឹកជញ្ជូន | 5.8 | 19.4 | -10.7 | 7.0 | 6.9 | 7.8 | 3.0 | 1.1 | 1.2 | -0.7 | -1.0 | -0.1 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ ( តាមអត្រាទីផ្សារនៅភ្នំពេញ ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4062.7 | 4058.2 | 4140.5 | 4187.1 | 4063.6 | 4046 | 4054.3 | 4060.7 | 3995.9 | 3995 | 4033.1 | 4062 |
| រៀលក្នុង ១ បាតថៃ | 122.8 | 123.5 | 121.1 | 133.13 | 133.2 | 130.2 | 129.0 | 129.3 | 131.3 | 134.7 | 135.74 | 131.35 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.0 | 24.8 | 23.4 | 21.725 | 19.7 | 19.3 | 19.4 | 19.5 | 19.2 | 19.3 | 19.34 | 19.26 |
| ថ្លៃមាស ( ដុល្លារក្នុង១ជី ) | 83.2 | 105.9 | 113.1 | 147.58 | 184.5 | 204.1 | 194.5 | 198.3 | 206.5 | 197.3 | 173.4 | 161.1 |
| ថ្លៃម៉ាស៊ូត ( រៀល/លីត្រ ) | 3262.3 | 4555.2 | 3170.9 | 3859.3 | 4761.2 | 5193.9 | 4458.3 | 4983.9 | 5128.8 | 5134.39 | 4992 | 5022.5 |
| ថ្លៃសាំង ( រៀល/លីត្រ ) | 4005.0 | 4750.8 | 3593.1 | 4368.1 | 5044.5 | 5395.8 | 5308.3 | 5251.3 | 5295.4 | 5410.52 | 5274.5 | 5245.2 |

Sources: NIS, NBC and CDRI

### តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៦-១៣ ( តួលេខនៅចុងការិយបរិច្ឆេទ )

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 7224.0 | 10,735.0 | 10,345.0 | 14,655.0 | 16,697.9 | 17.893.9 | 19.976.7 | 18,729.6 | 18,463.8 | 18,154.5 | 19,976.7 | 21.772.9 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -282.0 | 576.0 | 1513.3 | 1573.0 | 2778.9 | 5760.8. | 7931.8 | 7922.3 | 8400.3 | 10.437.4 | 10,504.1 | 9886.1 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -953.0 | -1816.0 | -2987.0 | -2252.0 | -2126.6 | -2123.1 | -2991.6 | -2399.9 | -2440.6 | -2486.4 | -2991.6 | -3012.6 |
| ឥណទានដល់ផ្នែកឯកជន | 3630.0 | 6386.0 | 9894.0 | 10,532.0 | 13,331.2 | 17.552.8 | 24.820.2 | 20,081.4 | 21,398.2 | 23,536.6 | 24,820.2 | 25.146 |
| រូបិយវត្ថុទូទៅ M2 | 6942.0 | 11,311.0 | 11,858.0 | 16,228.0 | 19,476.8 | 23.654.7 | 30.480.8 | 26,651.9 | 26,864.1 | 28,591.9 | 30,480.8 | 31.659.1 |
| រូបិយវត្ថុ M1 | 1658.0 | 2052.0 | 2399.0 | 3120.0 | 3220.9 | 3956.2 | 4500.6 | 3871.8 | 3818.2 | 4045.7 | 4500.6 | 4585.9 |
| រូបិយវត្ថុផ្សេងៗ | 5285.0 | 9259.0 | 9459.0 | 13,108.0 | 16,255.9 | 19.698.5 | 25.980.2 | 22,780.1 | 23,046.0 | 24,546.2 | 25,980.2 | 27.073.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 38.1 | 62.9 | 4.8 | 36.9 | 20.0 | 17.8 | 22.4 | 21.1 | 18.6 | 20.9 | 22.6 | 18.8 |
| រូបិយវត្ថុ M1 | 25.3 | 23.8 | 16.9 | 30.1 | 3.2 | 16.9 | 12.9 | 9.4 | 3.7 | 2.3 | 12.9 | 18.4 |
| រូបិយវត្ថុផ្សេងៗ | 42.8 | 75.2 | 2.2 | 38.6 | 24.0 | 17.9 | 24.4 | 23.4 | 21.5 | 44.6 | 24.4 | 18.8 |

Source: National Bank of Cambodia

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | 2009 | 2010 | 2011 | 2012 | | 2013 | | | 2013 | | |
| | | | | | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 12,628 | 8091 | 9055 | 9532 | 10.690 | 10.454 | 10.681 | 10.636 | 10.842 | -0.0 | -0.5 | 3.7 |
| អ្នកលីសែង | 9005 | 9549 | 9964 | 10,785 | 12,479 | 12,574 | 12.823 | 14.157 | 13.260 | 0.9 | 13.4 | 5.5 |
| អ្នកលក់បន្លែតូចតាច | 9926 | 8273 | 8266 | 8337 | 10,347 | 10,542 | 11.571 | 11.490 | 12.449 | 16.9 | 11.0. | 18.1 |
| អ្នករើសអេតចាយ | 4652 | 5857 | 6698 | 8388 | 9139 | 9328 | 10.440 | 9620 | 9732 | 26.3 | 5.3 | 4.3 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 4327 | 4646 | 5607 | 5986 | 5569 | 6436 | 6744 | 6791 | 6723 | 7.7 | 22.0 | 4.4 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 8697 | 6197 | 5691 | 5695 | 8483 | 5000 | 6427 | 7771 | 6388 | -0.1 | -8.4 | 27.8 |
| កម្មកររោងចក្រកាត់ដេរ | 6554 | 7085 | 7746 | 8409 | 9599 | 8989 | 9776 | 10.420 | 10.442 | 13.6 | 8.6 | 16.4 |
| អ្នករត់ម៉ូតូឌុប | 15,691 | 10,685 | 10,623 | 11,568 | 12,807 | 13,042 | 12.522 | 13.656 | 13.189 | -8.0 | 6.6 | 1.1 |
| កម្មករសំណង់គ្មានជំនាញ | 8779 | 8343 | 8790 | 10,307 | 10,690 | 11,375 | 13.728 | 13.023 | 13.431 | 18.5 | 21.8 | 18.1 |
| កម្មករសំណង់មានជំនាញ | 12,710 | 12,487 | 11,952 | 13,159 | 14,029 | 14,270 | 14.136 | 15.822 | 16.647 | 10.0 | 12.8 | 16.7 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the incomes of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI

## *តពីទំព័រ ២៨* **ព័ត៌មានថ្មីៗ...**

នៅថ្ងៃទី១៦-១៨ខែធ្នូCDRIបានធ្វើការប្រជុំបូកសរុបនិងរៀបចំផែនការប្រចាំឆ្នាំ នៅក្រុងព្រះសីហនុ ដើម្បីពិនិត្យលើសមិទ្ធផលក្នុងឆ្នាំ២០១៣ និងបទពិសោធន៍រៀនសូត្របាន ព្រមទាំងកំណត់អាទិភាពសម្រាប់ឆ្នាំ២០១៤ និងទៅអនាគត។ ក្នុងការប្រជុំពីរវគ្គចុងក្រោយ មានការចូលរួមពី ឯកឧត្តមបណ្ឌិត សុក ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាលនៃ CDRI ដើម្បីគិតគូរពិចារណាថា តើការផ្លាស់ប្ដូរក្នុងបរិយាកាសអភិវឌ្ឍន៍របស់កម្ពុជាមានន័យយ៉ាងដូចម្ដេចសម្រាប់ការងាររបស់ CDRI, ការផ្លាស់ប្ដូរថ្នាក់ដឹកនាំរបស់ CDRI, និងអាទិភាពរបស់ស្ថាប័នទៅអនាគត។

## ផ្នែកស្រាវជ្រាវ

### កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ (DGPSR)

គម្រោងស្រាវជ្រាវចំនួនប្រាំបួន កំពុងដំណើរការទៅមុខ។ គម្រោងស្រាវជ្រាវប្រាំ បានចប់សព្វគ្រប់ និងកំពុងរៀបចំបោះពុម្ពផ្សាយជាឯកសារពិភាក្សា និងអត្ថបទសម្រាប់ របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១៣-១៤ (ADR 2013-14)។ គម្រោងទី១ មានឈ្មោះថា "សង្គមស៊ីវិលថ្នាក់ក្រោមជាតិនៅកម្ពុជា៖ ការវិភាគតាមទស្សនៈ Gramsci"។ គម្រោងទី២ គឺ "រឿងល្អទាំងអស់ មិនមែនសុទ្ធតែដើរស្របគ្នានោះទេ៖ ការវិភាគពីភាពប្រទាំងប្រទើសគ្នារវាង ការកសាងសន្តិភាព និងប្រជាធិបតេយ្យភាវូបនីយកម្ម" ដែលជាគម្រោងអនុវត្តឡើង ក្រោមកិច្ចសហការជាដៃគូជាមួយសាកលវិទ្យាល័យ Gothenburg ដើម្បីកំណត់ពីបែបបទ និងមូលហេតុដែលទំនាស់ផុសឡើងក្នុងរយៈពេលខ្លី និងវែង។ គម្រោងទី៣ គឺ "ឥទ្ធិពលនៃវិមជ្ឈការទៅលើអភិបាលកិច្ចតំបន់ទីក្រុង"។ គម្រោងពីរទៀត បានបញ្ចូលជាជំពូកពីរនៅក្នុង ADR ក្រោមចំណងជើងថា "ទំនាក់ទំនងរវាងក្រុមប្រឹក្សា ស្រុក/ក្រុង/ខណ្ឌ នឹងឃុំ/សង្កាត់៖ ការតំណាង និងគណនេយ្យភាព ក្នុងអភិបាលកិច្ចមូលដ្ឋាន"និង"ឥទ្ធិពលនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការទៅលើលទ្ធិប្រជាធិបតេយ្យថ្នាក់មូលដ្ឋាន៖ ទស្សនៈពីភូមិវិទ្យានយោបាយផ្អែកលើការសិក្សាពីគម្រោងបោះព្រំទន្លេសាប"។

គម្រោង "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការចូលរួមរបស់យុវវ័យក្នុងសកម្មភាពនយោបាយ" ស្ថិតក្នុងដំណាក់កាលប្រមូលទិន្នន័យ និងចងក្រងអត្ថបទព្រាងដំបូង។ ការធ្វើសម្ភាសន៍នៅថ្នាក់ជាតិ បានអនុវត្តរួចហើយសម្រាប់គម្រោង "ការតភ្ជាប់អភិបាលកិច្ចមូលដ្ឋាន ទៅនឹង ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម" ហើយក្រុមស្រាវជ្រាវកំពុងចងក្រងអត្ថបទព្រាងលើកទី២ ។ សម្រាប់គម្រោង "រដ្ឋកម្ពុជា៖ តើមានលក្ខណៈល្អយ៉ាងណាសម្រាប់ការអភិវឌ្ឍ?" ក្រុមស្រាវជ្រាវ បានចុះសិក្សាដល់កន្លែង និងវិភាគទិន្នន័យនៅកម្រិតមូលដ្ឋាន។ ការស្រាវជ្រាវនេះប្រើប្រាស់នូវ ម៉ូដែលរដ្ឋសម្រាប់ការអភិវឌ្ឍ ដើម្បីធ្វើការវាយតម្លៃពី ផលប៉ះពាល់នៃកំណែទម្រង់អភិបាលកិច្ចទៅលើសមត្ថភាពស្ថាប័នរបស់រដ្ឋក្នុងការជំរុញការអភិវឌ្ឍ។ គម្រោង "ដំណោះស្រាយនយោបាយ និងកំណើនសម្រាប់គ្រប់គ្នានៅកម្ពុជា" ដែលជាផ្នែកមួយនៃការសិក្សាពហុប្រទេសនោះ បាន

ប្រើប្រាស់ការវិភាគពីដំណោះស្រាយនយោបាយ ដើម្បីស្វែងយល់ពីល្បឿន លក្ខណៈសម្រាប់គ្រប់គ្នា និងចីរភាពនៃការអភិវឌ្ឍរបស់ប្រទេសនីមួយៗ។

### កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ (ETRC)

"អង្កេតប្រចាំត្រីមាសលើពលករងាយរងគ្រោះ" និង "អង្កេតប្រចាំខែលើថ្លៃទំនិញតាមខេត្ត" មានដំណើការល្អ។

របាយការណ៍គម្រោង "អាស៊ានឆ្នាំ២០៣០ ដំណាក់កាលទី២៖ កំណើនទាំងអស់គ្នាដើម្បីវិបុលភាពសេដ្ឋកិច្ច - បញ្ហាប្រឈមៈ ព័ត៌មានទូទៅពីប្រទេសកម្ពុជា" ដែលទទួលបានមូលនិធិពីវិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (ADBI) កំពុងចងក្រងបញ្ចប់សម្រាប់បោះពុម្ពផ្សាយជា ឯកសារពិភាក្សារបស់ CDRI។ លេខបន្ទាប់នៃកម្រងការសិក្សារបស់ បណ្ដាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គ (GMS-DAN) មានចំណងជើងថា "ការវាយតម្លៃពីស្ថានភាពកំណើនសម្រាប់គ្រប់គ្នានៅប្រទេសកម្ពុជា ឡាវ ថៃ វៀតណាម និងខេត្តយូណានប្រទេសចិន" និងរបាយការណ៍សំយោគនៃគម្រោងនេះ កំពុងចងក្រងឡើង។ ការសិក្សាចំនួនបីដែលនៅសល់ ក្នុងគម្រោងស្រាវជ្រាវ ដែលទទួលបានជំនួយទ្រទ្រង់រយៈពេលប្រាំឆ្នាំ ពី Sida ស្ដីពី "កំណើនសម្រាប់គ្រប់គ្នា" កំពុងស្ថិតក្នុងដំណាក់កាលខុសៗគ្នា៖ អត្ថបទសង្ខេបនៃការសិក្សាពី "ភាពអំណោយផលដល់ជនក្រីក្រនៃគោលនយោបាយហិរញ្ញវត្ថុ-ចំណាយលើការអប់រំ" កំពុងចងក្រងបញ្ចប់សម្រាប់ការបោះពុម្ពផ្សាយនៅក្នុង ADR ហើយអត្ថបទពេញលេញកំពុងរៀបចំបោះពុម្ពផ្សាយជាឯកសារពិភាក្សារបស់ CDRI។ របាយការណ៍ព្រាង ស្ដីពី "កំណើនសេដ្ឋកិច្ច វិសមភាព និងការកាត់បន្ថយភាពក្រីក្រ" និង "គោលនយោបាយទីផ្សារពលកម្ម" រំពឹងថានឹងចងក្រងរួចរាល់នៅត្រឹមត្រីមាសទី១ ឆ្នាំ២០១៤។ របាយការណ៍បណ្ដោះអាសន្ន ស្ដីពី "ចំណាកស្រុកកម្លាំងពលកម្មនៅកម្ពុជា៖ មូលហេតុ និង ផលប៉ះពាល់លើភាពក្រីក្រ វិសមភាព និងផលិតភាព" បានទទួលការឯកភាពពី អង្គការភាពជាដៃគូដើម្បីសិក្សាពីគោលនយោបាយសេដ្ឋកិច្ច (PEP) និងកំពុងចងក្រងបង្ហើយ បន្ទាប់ពីការឆ្លើយតបនឹងមតិយោបល់ទទួលបាន។ របាយការណ៍បឋមស្ដីពី "ទំនាក់ទំនងរវាង គោលនយោបាយសាធារណៈរបស់ប្រទេសជាដៃគូ ចំណាកស្រុក និងការអភិវឌ្ឍ៖ ករណីសិក្សា និងអនុសាសន៍ផ្នែកគោលនយោបាយ" ដែលទទួលបានមូលនិធិពី អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ (OECD) បានចងក្រងរួចរាល់។ សិក្ខាសាលាដើរតួនាទីជាវេទិកាសន្ទនាមួយ សម្រាប់ឲ្យអ្នកពាក់ព័ន្ធទាំងឡាយនៅកម្ពុជា ពិភាក្សាពីទំនាក់ទំនងរវាងចំណាកស្រុកនឹងការអភិវឌ្ឍ ព្រមទាំងគោលនយោបាយនិងអាទិភាពពាក់ព័ន្ធនានា ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី ២៦ វិច្ឆិកា ២០១៣។

កម្មវិធី ETRC ទទួលបានកិច្ចព្រមព្រៀងអនុវត្តគម្រោងស្រាវជ្រាវមួយ ស្ដីពី "គោលនយោបាយជំរុញសហគ្រាសធុនតូច និងមធ្យម" ដែលផ្ដល់មូលនិធិដោយ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។ ការចុះសិក្សាដល់កន្លែងសម្រាប់គម្រោងនេះ បាននិងកំពុងចាប់ផ្ដើមដំណើរការ។

### កម្មវិធីធនធានធម្មជាតិ និង បរិស្ថាន (NRE)

ក្រុមស្រាវជ្រាវទើបបញ្ចប់គម្រោងបី ស្ដីពី "យេនឌ័រ និងអភិបាលកិច្ចទឹក", "ភាពជាដៃគូក្នុងការបែងចែកទឹក" និង "ការកាត់បន្ថយភាពងាយរងគ្រោះពីទឹកជំនន់ និងការរាំងស្ងួត និង ការបង្កើនផលិតភាពកសិកម្ម"។ ឯកសារពិភាក្សា ស្ដីពី "សមត្ថភាពបន្សាំរបស់ប្រជាជនជនបទក្នុងតំបន់កសិអេកូឡូស៊ីចម្រុះៗ" កំពុងចងក្រងបញ្ចប់។

លទ្ធផលបានពីការសិក្សាដល់កន្លែងនៃគម្រោង "ប្រទេសចិនឈានឡើងកម្រិតសកល" ដែលទទួលមូលនិធិពី ក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ចនិងសង្គម (ESRC) កំពុងចងក្រងជាលាយលក្ខណ៍អក្សរ។ សម្រាប់គម្រោងទទួលមូលនិធិពី IDRC ស្ដីពី "ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹកនៅកម្ពុជា" របាយការណ៍បណ្ដោះអាសន្នទី២ បានផ្ញើជូនទៅម្ចាស់ជំនួយរួចរាល់ ហើយឯកសារពិភាក្សាដំបូង កំពុងចងក្រងបញ្ចប់។ ក្រៅពីនេះ ក្រុមស្រាវជ្រាវបានរៀបចំសិក្ខាសាលាកម្រិតឃុំចំនួនបី ហើយលទ្ធផលបានពីសិក្ខាសាលា កំពុងចងក្រងសម្រាប់បោះពុម្ពផ្សាយក្នុង ADR ។ គម្រោងនេះ ក៏បានជ្រើសរើសបេក្ខជនសម្រាប់ទទួល អាហារូបករណ៍ថ្នាក់អនុបណ្ឌិតចំនួន ៥កន្លែង និងថ្នាក់បរិញ្ញាប័ត្រចំនួន ១៣ កន្លែង នៅសាកលវិទ្យាល័យ ភូមិន្ទកសិកម្ម (RUA) និង វិទ្យាស្ថានបច្ចេកទេសនៃកម្ពុជា (ITC) ។

នៅខែតុលា ក្រុមស្រាវជ្រាវបានចាប់ផ្ដើមអនុវត្តគម្រោង ស្ដីពី "ការបញ្ជ្រាបនូវភាពធន់នឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ ជាមួយក្រុមប្រឹក្សាយោបល់ Hatfield Consultants។ សំណើគម្រោង "ការប្រែប្រួលអាកាសធាតុនិងការរក្សានិរន្តរភាពទឹក៖ ទំនាក់ទំនងផ្នែកធារាសាស្ត្រ, សេវាអេកូឡូស៊ី និងភាពបន្សាំផ្នែកសេដ្ឋកិច្ចសង្គមកិច្ច នៅក្នុងប្រព័ន្ធវាលទំនាបតាមដងទន្លេមេគង្គក្រោម នៃប្រទេសកម្ពុជា" កំពុងរង់ចាំចម្លើយតប។ គម្រោងនេះត្រៀមអនុវត្តជាមួយ University of Chicago និងបានផ្ញើជូន National Science Foundation's Water Sustainability and Climate Programme។

### កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD)

ក្រុមស្រាវជ្រាវ បាននិងកំពុងដំណើរការគម្រោងចំនួន ៩ ក្នុងនោះគម្រោងបីជាកិច្ចសហការណ៍ជាមួយកម្មវិធី SD, ETRC និងក្រុមការងារផ្នែកយេនឌ័រ។ គម្រោងប្រាំមួយផ្សេងទៀតមានដូចតទៅ៖ ដំណាក់កាលទី២ នៃគម្រោងទទួលមូលនិធិពីមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ចែកជា ២ ករណីសិក្សា គឺមួយផ្ដោតលើការចិញ្ចឹមសត្វ និងមួយទៀតផ្ដោតលើសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម។ ការប្រមូលទិន្នន័យដល់កន្លែងបានចប់សព្វគ្រប់សម្រាប់ករណីសិក្សាស្ដីពី ការចិញ្ចឹមសត្វ ហើយលទ្ធផលស្រាវជ្រាវបឋម បានយកទៅធ្វើជាបទបង្ហាញក្នុងសិក្ខាសាលាថ្នាក់តំបន់មួយ នៅរាជធានីភ្នំពេញ។ លទ្ធផលសំខាន់ៗនៃករណីសិក្សាពី សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម បានយកទៅធ្វើ

ជាបទបង្ហាញក្នុងសិក្ខាសាលាថ្នាក់តំបន់មួយ នៅរាជធានីភ្នំពេញ ហើយអត្ថបទមួយអំពីករណីសិក្សានេះ ត្រូវបានចងក្រងឡើងសម្រាប់បោះពុម្ពផ្សាយក្នុង ADR ។ ការសិក្សាដល់កន្លែង បានចប់រួចរាល់សម្រាប់គម្រោង "ផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យាទៅលើជីវភាពរស់នៅរបស់ម្ចាស់ដីតូចៗ" ដែលទទួលមូលនិធិពី Sida ហើយរបាយការណ៍ព្រាងដំបូងជិតចងក្រងបានរួចរាល់។ គម្រោងទទួលមូលនិធិពី USAID តាមរយៈវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI) ស្ដីពី "ការអភិវឌ្ឍឧស្សាហកម្មជីនៅកម្ពុជា" ជិតចប់សព្វគ្រប់៖ របាយការណ៍ចុងក្រោយបានបញ្ជូនទៅ IFPRI រួចរាល់។ ផ្នែកមួយនៃរបាយការណ៍នេះ បានសរសេរសង្ខេបជាអត្ថបទមួយសម្រាប់ ADR ហើយរបាយការណ៍ពេញលេញកំពុងកែសម្រួលសម្រាប់បោះពុម្ពផ្សាយជាឯកសារពិភាក្សារបស់ CDRI។ របាយការណ៍ព្រាងដំបូងនៃគម្រោងទទួលមូលនិធិពី Sida ស្ដីពី "យន្តកម្មនៅតាមកសិដ្ឋាន និងនិន្នាការទីផ្សារពលកម្មក្នុងវិស័យកសិកម្ម" កំពុងចងក្រងឡើង ហើយរំពឹងថានឹងបានរួចរាល់ក្នុងពេលឆាប់ៗ។

ថ្មីៗនេះ PARD បានចុះកិច្ចសន្យាអនុវត្តគម្រោង២ដែលទ្រទ្រង់ដោយកម្មវិធីស្បៀងអាហារពិភពលោកនៅកម្ពុជា។ គម្រោងទី១ គឺ "ការកសាងក្របខ័ណ្ឌវាយតម្លៃ និងការត្រួតពិនិត្យលើអង្កេតគោល និងអង្កេតចុងបញ្ចប់ ដើម្បីការជួយទ្រទ្រង់ជីវភាព និងទ្រព្យផលិតកម្ម" គម្រោងមួយទៀតគឺ "អង្កេតគោលសម្រាប់គម្រោងផ្ដល់អាហារនៅសាលា និងរបបអាហារយកទៅផ្ទះ របស់ McGovern-Dole នៅកម្ពុជា"។ គម្រោងទាំងពីរកំពុងស្ថិតក្នុងដំណាក់កាលរចនារៀបចំឡើង។

ដំណើរការជឿនលឿននៃគម្រោងស្រាវជ្រាវរួមគ្នាបី គឺ "ReBUILD", "ចំណាកស្រុកកម្លាំងពលកម្មនៅកម្ពុជា៖ មូលហេតុ និងផលប៉ះពាល់លើភាពក្រីក្រ វិសមភាព និងផលិតភាព" និង "ការពិនិត្យមើលពីទស្សនៈរបស់ស្ត្រី និងដំណើរការវិវត្តផ្នែកវិជ្ជាជីវៈនៅ CDRI" មានរាយការណ៍នៅក្នុងផ្នែកផ្សេងទៀតនៃអត្ថបទនេះ។

### កម្មវិធីអភិវឌ្ឍន៍សង្គម (SD)

គម្រោងធំៗពីរ កំពុងដំណើរការទៅមុខ។ ទី១ គឺគម្រោង "ReBUILD" ដែលទទួលមូលនិធិពី DFID និងចែកជា ៣ អនុគម្រោង ស្ដីពីហិរញ្ញប្បទានផ្នែកសុខភាព, ធនធានមនុស្សផ្នែកសុខាភិបាល និងការចុះកិច្ចសន្យាផ្នែកសុខាភិបាល។ ការសិក្សាដល់កន្លែង និងការកត់ត្រាជាលាយលក្ខណ៍អក្សរ បានអនុវត្តរួចរាល់ ហើយការវិភាគលេខកូដ ក៏បានចាប់ផ្ដើមសម្រាប់អនុគម្រោងទាំងបី។ គម្រោងធំទី២ "ការសិក្សាពីពលកម្មកុមារ" រួមមាន ៤ អនុគម្រោង សម្រាប់រយៈពេល ២ឆ្នាំ។ អនុគម្រោង២ ដែលគ្រោងចប់រួចរាល់ ក្នុងឆ្នាំនេះ គឺ "កុមារបម្រើការងារតាមផ្ទះ" និង "ផលប៉ះពាល់នៃចំណាកស្រុករបស់មនុស្សពេញវ័យ ទៅលើសុខុមាលភាពរបស់កុមារ"។ ការសិក្សាពីពលកម្មកុមារ គឺជាផ្នែកមួយនៃគម្រោង Cambodian-EXCEL របស់អង្គការទស្សនៈពិភពលោកកម្ពុជា (World Vision Cambodia) និងទទួលមូលនិធិពី ក្រសួងការងារសហរដ្ឋអាមេរិក (USDOL) ។ កម្មវិធី SD បានបញ្ចប់គម្រោងសិក្សាមួយ អំពី "ការវាយតម្លៃបែបបរិមាណ លើស្ថានភាពអាហារូបត្ថម្ភរបស់កុមារ" ដែលទទួលមូលនិធិពី UNICEF។ បច្ចុប្បន្ន ក្រុមស្រាវជ្រាវ កំពុងចងក្រងរបាយការណ៍មួយស្ដីពី ការវាយតម្លៃឥទ្ធិពលនៃមូលនិធិស្រាវជ្រាវកសិកម្មនៅកម្ពុជា ដែលទទួលជំនួយហិរញ្ញវត្ថុពី ACIAR ។ របាយការណ៍ព្រាងសម្រាប់ការសិក្សានេះ បានចងក្រងរួចរាល់។


## Cambodia Development Review—2013 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

កាលពីថ្ងៃទី ១៦-១៧ ខែតុលា សន្និសីទវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជាប្រចាំឆ្នាំ (DRF) បានប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ ក្រោមប្រធានបទ៖ *កម្ពុជានៅថ្ងៃស្អែក: អាទិភាពស្រាវជ្រាវការអភិវឌ្ឍសម្រាប់ប្រទេសមានចំណូលមធ្យម* ដោយមានការគាំទ្រពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា និងក្រោមកិច្ចសហការជាដៃគូរវាង វិទ្យាស្ថាន CDRI, សមាគមសេដ្ឋកិច្ចកម្ពុជា, វិទ្យាស្ថានសិក្សាស្រាវជ្រាវនិងបណ្តុះបណ្តាល, វិទ្យាស្ថានជាតិសុខភាពសាធារណៈ, សាកលវិទ្យាល័យភូមិន្ទកសិកម្ម, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។ លោកជំទាវបណ្ឌិតអ៊ឹងកន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងលោក Enrique Aldaz-Carroll អ្នកសេដ្ឋកិច្ចជាន់ខ្ពស់ប្រចាំធនាគារពិភពលោកនៅកម្ពុជា បានថ្លែងសុន្ទរកថាបើកសន្និសីទ ហើយបន្ទាប់មក មានបទបង្ហាញរបស់អ្នកស្រាវជ្រាវវ័យក្មេងលើ ប្រធានបទរបស់ក្រុមចាប់អារម្មណ៍ស្រាវជ្រាវរបស់ DRF ទាំង៦ គឺការអភិវឌ្ឍកសិកម្ម, កម្ពុជានិងតំបន់ជុំវិញ, អភិបាលកិច្ចធនធានធម្មជាតិ, កំណើនសម្រាប់គ្រប់គ្នា, គោលនយោបាយសង្គមលើការអប់រំ, និង គោលនយោបាយសង្គមលើសុខភាព (សូមមើលគេហទំព័ររបស់ DRF នៅ www.drfcambodia.net សម្រាប់ព័ត៌មានបន្ថែម)។

នៅដើមខែតុលា នាយកផ្នែកសិក្សាស្រាវជ្រាវនៃវិទ្យាស្ថាន CDRI បានធ្វើបទឧទ្ទេសនាមបង្រៀន ចំនួនពីរដង នៅក្នុងកម្មវិធីបណ្តុះបណ្តាលមួយដែលរៀបចំរួមគ្នាដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង វិទ្យាស្ថានធនាគារកូរ៉េ សម្រាប់មន្ត្រីរដ្ឋាភិបាលថ្នាក់កណ្តាល មកពីបណ្តាប្រទេសអាស៊ី លើប្រធានបទ: *សមាហរណកម្មផលិតកម្មក្នុងតំបន់ និងការវិវត្តន៍នៃរោងចក្រនៅអាស៊ី* និង *និន្នាការនិងបញ្ហាចោទនៅក្នុងសមាហរណកម្មរូបិយវត្ថុនិងហិរញ្ញវត្ថុនៅអាស៊ី*។ នៅខែធ្នូ លោកបានធ្វើបទបង្ហាញក្នុងសិក្ខាសាលាមួយ នៅទីស្នាក់ការកណ្តាលរបស់ ADB នៅក្រុងម៉ានីល លើប្រធានបទ *សក្តានុពលអភិវឌ្ឍន៍របស់កម្ពុជា: ព័ត៌មាននៅក្រៅទំព័រមុខ*។

នៅថ្ងៃទី ២៤ តុលា, វិទ្យាស្ថាន CDRI បានរួមសហការរៀបចំសិក្ខាសាលាស្តីពី *ការពង្រឹងសហប្រតិបត្តិការសេដ្ឋកិច្ច និងសមាហរណកម្មក្នុងតំបន់ក្នុងកាលៈទេសៈ មិនប្រាកដប្រជា* ដើម្បីចាប់ដំណើការគម្រោងថ្មីបំផុតរបស់ ADB នៅកម្ពុជាស្តីពី *ការពិនិត្យតាមដានសមាហរណកម្មសេដ្ឋកិច្ចនៅអាស៊ីឆ្នាំ២០១៣*។នៅចុងខែតុលា នាយកប្រតិបត្តិរបស់CDRI បានទៅចូលរួមវេទិកាក្រុមផ្តល់គំនិតអភិវឌ្ឍន៍អាស៊ីរបស់ ADB លើកទី១ នៅក្រុងប៉េកាំង លើប្រធានបទ *គំនិតអនុវត្តបែបថ្មី និងភាពសម្រាប់គ្រប់គ្នា ដើម្បីការរីកចម្រើននៅអាស៊ី* ដែលមានសម័យប្រជុំពេញអង្គស្តីពី *បញ្ហាប្រឈមរបស់អាស៊ី និងឱកាសក្នុងការពង្រីក គំនិតអនុវត្តបែបថ្មី*។

នៅខែវិច្ឆិកា-ធ្នូ វិទ្យាស្ថាន CDRI បានទទួលទស្សនកិច្ចពីរលើករបស់គណៈប្រតិភូជាន់ខ្ពស់ មកពី បណ្ឌិតសភាវិទ្យាសាស្ត្រសង្គមនៃប្រទេសចិន។ គណៈប្រតិភូលើកទី១ ដឹកនាំដោយសាស្ត្រាចារ្យ Zhang Yunling នាយកវិទ្យាស្ថានសិក្សាអន្តរជាតិ ហើយកម្មវិធីទស្សនកិច្ចរួមមាន ការពិភាក្សាតុមូលជាមួយក្រុមអ្នកស្រាវជ្រាវជាន់ខ្ពស់របស់ CDRI ស្តីពី អាទិភាពអភិវឌ្ឍន៍របស់កម្ពុជា និងទំនាក់ទំនងកម្ពុជា-ចិន, ការជួបពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងអប់រំ នឹងតំណាងជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងការបរទេស។ គណៈប្រតិភូទី២ ដឹកនាំដោយសាស្ត្រាចារ្យ Guo Jiguang នាយកវិទ្យាស្ថានជាតិសិក្សាយុទ្ធសាស្ត្រអន្តរជាតិ នៃបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមនៃប្រទេសចិន ហើយកម្មវិធីទស្សនកិច្ចមានការជួបពិគ្រោះយោបល់អំពីការអភិវឌ្ឍប្រទេសកម្ពុជា និងទំនាក់ទំនងក្នុងតំបន់។

*(តទៅទំព័រ ២៥)*

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១៧ លេខ៤ ខែធ្នូ ឆ្នាំ២០១៣

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន។ លិខិត ត្រូវចុះហត្ថលេខាអាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
☒ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ (fax) (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួល: ខេង សេង
សហគ្រាសបោះពុម្ព សាលាបច្ចេកទេសដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ វិទ្យាស្ថាន CDRI ទេ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh